ខុមហ្វ្រែល COMFREL

# សហការជាមួយ

## របាយការណ៍

# ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖
# សភា និងតំណាងរាស្ត្រស្ត្រី និងការផ្តល់អំណាចឲ្យស្ត្រី
# ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន



សិទ្ធិពលរដ្ឋ
នយោបាយ
សេដ្ឋកិច្ច
សង្គម
វប្បធម៌
បរិស្ថាន
អភិវឌ្ឍន៍

ខែមីនា ឆ្នាំ២០១៩

របាយការណ៍




# ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖ សភា និងតំណាងរាស្ត្រស្ត្រី និងការផ្តល់អំណាចឲ្យស្ត្រី ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន




ខែមីនា ឆ្នាំ២០១៩

## បុព្វកថា

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា ហៅកាត់ថា "ខុមហ្វ្រែល"** ធ្វើការដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋតាមគោលការណ៍ កសាងសមត្ថភាពរបស់បណ្ដាញទូទាំងប្រទេស និងសហប្រតិបត្តិការជាមួយអង្គការជាសមាជិក និងជាដៃគូ ។ ប្រជាធិបតេយ្យមិនមែនត្រឹមតែការបោះឆ្នោតប៉ុណ្ណោះទេ ក៏ប៉ុន្តែជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌ជាលក្ខខណ្ឌចាំបាច់នៃលទ្ធិប្រជាធិបតេយ្យ ។ បន្ថែមពីលើនេះទៀត ការមានគណនេយ្យភាពរបស់គណបក្សជាប់ឆ្នោត និងមន្ត្រីជាប់ឆ្នោតក្នុងការបំពេញតាមការសន្យារបស់ខ្លួន ការលើកស្ទួយ ការការពារការចូលរួមក្នុងការសម្រេចចិត្តខាងនយោបាយ និងការដឹកនាំ ការបំពេញនូវតួនាទី ភារកិច្ច និងការទទួលបានសិទ្ធិអំណាចពេញលេញរបស់ស្ត្រីជារឿងសំខាន់បំផុតក្នុងអភិក្រមប្រជាធិបតេយ្យ ។

របាយការណ៍ស្ដីពី « ***ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ ៖ សភា និងតំណាងរាស្ត្រស្ត្រី និងការផ្ដល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន*** » គឺជាទម្រង់នៃការវិភាគទៅលើទិន្នន័យ និងមតិយោបល់របស់តំណាងជាប់ឆ្នោតស្ត្រីចូលរួមក្នុងកិច្ចការនយោបាយ និងក្នុងដំណើរការសម្រេចចិត្ត ជាពិសេស ការតាមដាន និងការពិនិត្យមើលលើស្ថានភាពការងាររបស់ តំណាងជាប់ឆ្នោតស្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានក្នុងរយៈពេល ១ឆ្នាំ កន្លងទៅនេះ។

របាយការណ៍នេះ បង្ហាញការវាយតម្លៃលើការផ្ដល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ សភា និងតំណាងរាស្ត្រស្ត្រីក្នុងអំឡុងពេលបំពេញការងារទាក់ទងនឹង ការបញ្ចេញមតិយោបល់ជាបរិមាណ និងគុណភាពរបស់សមាជិកសភាជាស្ត្រីនៅក្នុងពេលប្រជុំពេញអង្គរដ្ឋសភា សកម្មភាព និងគោលបំណងរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋានតាមមណ្ឌលខេត្ត ក្រុងនានា ចំនួនតំណាងរាស្ត្រស្ត្រីធៀបនឹងតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម ភាគរយអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មធៀបនឹងអ្នកតំណាងរាស្ត្របុរសនៃគណបក្សនីមួយៗ សកម្មភាពរបស់អ្នកតំណាងរាស្ត្រ ស្ត្រីនៅថ្នាក់ជាតិ និងការចុះដោះស្រាយបន្ទាន់នៅតាមមណ្ឌល ។ បន្ថែមលើនេះទៀត របាយការណ៍នេះក៏បានបង្ហាញផងដែរអំពីសមិទ្ធផលចម្បងៗ និងការប្រឈមក្នុងការបំពេញការសន្យារបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមាររួមទាំងតំណែងសមាជិកសភាស្ត្រីនៅក្នុងរដ្ឋសភា ។ម្យ៉ាងទៀត របាយការណ៍នេះ ក៏ផ្ដល់នូវលទ្ធផលនៃការសិក្សាលើក្រុមគោលដៅស្ដីពី ការផ្ដល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែល និងករណីសិក្សា៣ ព្រមទាំងចំនួនស្ត្រីក្នុងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ផងដែរ។ ជាចុងក្រោយ របាយការណ៍នេះមានអនុសាសន៍សំខាន់ៗក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការផ្ដល់អំណាចឲ្យតំណាងជាប់ឆ្នោតស្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននៅក្នុងប្រទេសកម្ពុជា ។

**ខុមហ្វ្រែល** សង្ឃឹមថា របាយការណ៍ឃ្លាំមើលយេនឌ័រផ្នែកនយោបាយនេះ ជាឯកសារដ៏សំខាន់ និងមានប្រយោជន៍សម្រាប់អ្នកអនុវត្តន៍សកម្មភាព ជាពិសេសមន្ត្រីរដ្ឋាភិបាល សមាជិកសភា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយ បុគ្គលិកសមាគម អង្គការមិនមែនរដ្ឋាភិបាល តំណាងរបស់ដៃគូអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ ដើម្បីជួយលើកស្ទួយស្ត្រីចូលរួមកាន់តែច្រើនក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត ។

របាយការណ៍នេះរៀបរៀង និងផលិតដោយខុមហ្វ្រែលសហការជាមួយគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ(គ.ស.ន) ។

តាំងនាមឲ្យខុមហ្វ្រែល យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយដូចជា៖ **Norwegian People's Aid (NPA), Oxfam, Daikonia, Foundation Open Society Institute (FOSI) especially British Embassy** ។

ជាពិសេស សូមថ្លែងអំណរគុណចំពោះក្រុមការងាររបស់ខុមហ្វ្រែល ដូចជា **លោកស្រី សឺនកេត សិរីលក្ខណ៍** ដែលជាអ្នកសរសេររបាយការណ៍វិភាគនេះ ។ លោកស្រីក៏ជាអ្នកដឹកនាំក្រុមការងារ ដូចជា **លោក នាង សុវណ្ណ** និង**អ្នកសង្កេតការណ៍ស្ត្រី** ដែលខិតខំអនុវត្តតាមផែនការសកម្មភាពដើម្បីប្រមូលទិន្នន័យ និងរចនាបថរបាយការណ៍នេះ**គាំទ្រដោយក្រុមការងារស្នូលរបស់ខុមហ្វ្រែល ផ្នែកអង្កេត និងលេខាធិការខុមហ្វ្រែលទាំង២៥ខេត្ត ក្រុង រាជធានី** ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ**គណៈកម្មាធិការដឹកនាំនៃគ.ស.ន ជាពិសេស លោកស្រី ធីដា ឃឹះ លោក គល់ បញ្ញា លោកស្រី ជា ស៊ុនដាណែត លោកស្រី រួន សុរិរីយ៍** ដែលបានផ្តល់មតិយោបល់ល្អៗធ្វើឲ្យរបាយការណ៍នេះកាន់តែមានភាពល្អប្រសើរថែមទៀត ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥

**នាយកប្រតិបត្តិខុមហ្វ្រែល**

**គល់ បញ្ញា**

# មាតិកា


សេចក្តីផ្តើម ....4

I. ការឃ្លាំមើលសភា និងតំណាងរាស្ត្រស្ត្រី....7

១. ដំណើរការសម័យប្រជុំសភា....7

១.១. ការបញ្ចេញមតិយោបល់ជាបរិមាណរបស់សមាជិកសភាជាស្ត្រីនៅក្នុងពេលប្រជុំពេញអង្គរដ្ឋសភា ....8

តារាងទី១៖ ចំនួនតំណាងរាស្ត្រស្ត្រី ឡើងបញ្ចេញមតិធៀបនឹងគណបក្សរបស់ខ្លួន និងតំណាងរាស្ត្រប្រុស....8

ភាគរយនៃអ្នកតំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិយោបល់ធៀបនឹងគណបក្សរបស់ខ្លួន ....9

ចំនួននៃអ្នកតំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិយោបល់ធៀបនឹងតំណាងរាស្ត្រប្រុស ....9

១.២. គុណភាពមតិពិភាក្សារបស់អ្នកតំណាងរាស្ត្រស្ត្រី ....10

តារាងទី២៖ ការបង្ហាញពីអ្នកតំណាងរាស្ត្រស្ត្រីឡើងសំដែងមតិ....10

១.៣. មតិយោបល់របស់តំណាងរាស្ត្រស្ត្រី និងប្រុសដែលបានលើកឡើងទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ....11

២. សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋាន....11

តារាងទី៣ ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រទាំងស្ត្រី និងប្រុស ....11

២.១. ការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី ....13

តារាងទី៤ ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី....13

តារាងទី៥ ៖ ចំនួនតំណាងរាស្ត្រស្ត្រីធៀបនឹងតំណាងរាស្ត្រប្រុសដែលបានចុះបេសកកម្មគិតជាភាគរយ ....15

តារាងទី៦ ៖ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មធៀបនឹងអ្នកតំណាងរាស្ត្រប្រុសនៃគណបក្សនីមួយៗ15

តារាងទី៧៖ ចំនួនចុះបេសកកម្មនៃតំណាងរាស្ត្រស្ត្រីម្នាក់ៗ ....16

៣. សកម្មភាពតំណាងរាស្ត្រស្ត្រីនៅថ្នាក់ជាតិ និងតាមមណ្ឌល....17

៤. ការបំពេញការសន្យារបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ....20

សមិទ្ធផលចម្បងៗ និងការប្រឈម....21

ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ....21

ការអប់រំសម្រាប់ស្ត្រី និងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ....22

យេនឌ័រ និងសុខភាព ....23

យេនឌ័រ និងមេរោគអេដស៍ ....24

អំពើហិង្សាលើស្រ្តី និងក្មេងស្រី ....25
ស្រ្តីក្នុងការធ្វើសេចក្តីសម្រេច ក្នុងវិស័យសាធារណៈ និងនយោបាយ ....26
ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងវិស័យពាក់ព័ន្ធ ....26
៥. តំណែងសមាជិកសភាស្រ្តី ....29
II. ការសិក្សាលើក្រុមគោលដៅ ស្តីពី ការផ្តល់អំណាចឲ្យស្រ្តីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការ ....33
បំពេញកិច្ចការនៅក្នុងតំបន់គោលដៅរបស់ខុមហ្វ្រេល ....33
១. ព័ត៌មានទូទៅទាក់ទងនឹងការចូលរួមនយោបាយរបស់ស្រ្តីក្រុមប្រឹក្សាឃុំ សង្កាត់ ....34
១.១. ព័ត៌មានទូទៅរបស់ស្រ្តីក្រុមប្រឹក្សាឃុំ សង្កាត់ ....34
១.២. ចំនួនអាណត្តិរបស់ស្រ្តីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ ....34
១.៣. តួនាទីរបស់ស្រ្តីក្រុមប្រឹក្សាឃុំ សង្កាត់ ....35
១.៤. មូលហេតុនៃការចូលប្រឡូកក្នុងកិច្ចការនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ ....35
២. ស្ថានភាពស្រ្តីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន ....36
២.១. ការរើសអើងស្រ្តី ....36
២.១.១. អារម្មណ៍របស់អ្នកជិតខាង អ្នកស្គាល់ មិត្តភក្តិ និងគ្រួសារចំពោះស្រ្តីក្រុមប្រឹក្សាឃុំ សង្កាត់ ....36
២.១.២. អាកប្បកិរិយាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបុរសដែលបំពេញកិច្ចការជាមួយស្រ្តី ....36
២.២. ការទទួលបានភារកិច្ចការងារ សិទ្ធិអំណាចពេញលេញរបស់ស្រ្តីតាមច្បាប់ ....37
២.២.១ . ការប្រគល់តួនាទី ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ទៅសមាជិកស្រ្តីរបស់ខ្លួន ....37
២.២.២. តើនៅតំបន់របស់លោកស្រី នាងកញ្ញា ធ្លាប់ដឹងថា មានគេបញ្ឈប់សមាជិកស្រ្តីក្រុមប្រឹក្សាឃុំដែរឬទេ? ....38
២.៣. ការបំពេញការងារទាក់ទងនឹងស្រ្តី និងកុមារ និងភាពសកម្មរបស់ស្រ្តី ....38
២.៤. ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត ....38
២.៤.១. ស្រ្តីក្រុមប្រឹក្សាឃុំ សង្កាត់ និងកិច្ចប្រជុំប្រចាំខែ ....38
២.៤.២. ការបញ្ចេញមតិយោបល់ ឬ សំណើររបស់ស្រ្តីក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំ ....39
២.៤.៣. ការឆ្លើយតបទៅលើយោបល់ ឬសំណើររបស់ស្រ្តីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអង្គប្រជុំ ....40
សំណើ និងយោបល់ស្រ្តីក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានសម្រេចក្នុងអង្គប្រជុំ និងដោះស្រាយ ៖ ....40
៣. ឥទ្ធិភាពឱកាសសម្រាប់កិច្ចការស្រ្តី និងកុមារនៅឃុំ សង្កាត់ ....41
៤. ករណីសិក្សា ....42

៤.១. «សកម្មភាពលេចធ្លោរបស់ស្ត្រីនៅថ្នាក់មូលដ្ឋាន» ........ 42
ករណីសិក្សាទី១ ........ 42
ករណីសិក្សាទី២ ........ 45
៤.២ .« ភាពបរាជ័យរបស់ស្ត្រីបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន» ........ 48
ករណីសិក្សាទី៣ ........ 48
III. ចំនួនស្ត្រីក្នុងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ (ស្ថិតិ និងតួនាទី) ........ 51
១. ព្រឹទ្ធសភា ........ 51
២. រដ្ឋសភា ........ 51
៣. រដ្ឋាភិបាល ........ 52
៤. តុលាការ ........ 52
៥. ថ្នាក់ក្រោមជាតិ ........ 53
៦. ក្រុមប្រឹក្សាឃុំ សង្កាត់ ........ 54
IV. សេចក្តីសន្និដ្ឋាន និងសង្ខេប ........ 54
V. អនុសាសន៍ ........ 57
រដ្ឋសភា ........ 57
ក្រុមប្រឹក្សាឃុំ សង្កាត់ ........ 58
ផ្នែកឧបសម្ព័ន្ធ ........ 59

# របាយការណ៍

## ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖ សភា និងតំណាងរាស្ត្រស្ត្រី និងការផ្តល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន

## សេចក្តីផ្តើម

ក្រៅពីការបន្តបញ្ហាវិសមភាពនៃតំណាង និងការអនុវត្តសិទ្ធិរវាងស្ត្រី និងបុរសនៅកម្ពុជានៅគ្រប់លំដាប់ថ្នាក់ ការតាមដាន និងការពិនិត្យមើលលើស្ថានភាពការងាររបស់តំណាងជាប់ឆ្នោតស្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានថាតើមានភាពប្រឈមយ៉ាងណា តើស្ត្រីទាំងនោះធ្វើការមានលទ្ធផលយ៉ាងណាខ្លះ? មានការរើសអើងដែរឬទេ? តើអ្វីជាការបរាជ័យរបស់ពួកគាត់? គឺជារបៀបវារៈសំខាន់បំផុតដែលត្រូវស្វែងយល់ និងឃ្លាំមើលដោយយកចិត្តទុកដាក់ពីគ្រប់ភាគីពាក់ព័ន្ធ ប្រយោជន៍លើកស្ទួយ ការការពារ ការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តខាងនយោបាយ និងការដឹកនាំ ការបំពេញ និងទទួលបាននូវតួនាទីភារកិច្ច និងសិទ្ធអំណាចពេញលេញរបស់ស្ត្រី ។

សម្រាប់នីតិកាលទី៥(ឆ្នាំ២០១៣-២០១៨)នៃរដ្ឋសភា មានគណបក្សនយោបាយចំនួនពីរជាប់ឆ្នោតមានអាសនៈនៅក្នុងរដ្ឋសភាជាតិគឺ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ។ នៅឆ្នាំទី១(ចន្លោះឆ្នាំ២០១៣-ឆ្នាំ២០១៤)នេះមានអ្នកតំណាងរាស្ត្រស្ត្រីចំនួន២៥នាក់ ស្មើនឹង ២០,៣៣% ក្នុងចំណោមសមាជិកសភា១២៣នាក់ ក្នុងនោះគណបក្សប្រជាជនកម្ពុជាចំនួន១៨នាក់ ស្មើនឹង ១៤,៦៣% និងគណបក្សសង្គ្រោះជាតិចំនួន៧នាក់ ស្មើនឹង ៥,៦៩% ។ ដោយឡែក អាណត្តិទី៣ (ឆ្នាំ២០១២-២០១៧) នៃក្រុមប្រឹក្សាឃុំ សង្កាត់ មានគណបក្សចំនួន៥បានជាប់ឆ្នោតគឺ គណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី គណបក្សនរោត្តម រណឫទ្ធិ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសិទ្ធិមនុស្ស ដែលស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់មានចំនួន ២០៣៨នាក់ ស្មើនឹង ១៧,៧៨%នៃចំនួនសរុប ១១ ៤៥៩នាក់ ។

បន្ទាប់ពីជាប់គាំង និងខ្វះនីត្យានុកូលភាពនៃការបង្កើតរដ្ឋសភារយៈពេលពីក្រោយការបោះឆ្នោតខែកក្កដា ឆ្នាំ២០១៣ ដល់ខែកក្កដា ឆ្នាំ២០១៤ នៅក្នុងឆ្នាំទី១នៃនីតិកាលទី៥ រចនាសម្ព័ន្ធដឹកនាំនៃរដ្ឋសភា ប្រធាន អនុប្រធានទាំង២នៃរដ្ឋសភា រួមទាំងគណៈកម្មការអចិន្ត្រៃយ៍ ប្រធាន និងអនុប្រធានទាំង១០នៃគណៈកម្មការជំនាញនានារបស់រដ្ឋសភាគឺត្រូវបានបង្កើត និងបែងចែកអំណាចក្នុងចំណោមគណបក្សទាំងពីរដែលមានអាសនៈក្នុងរដ្ឋសភា នៅខែសីហា ឆ្នាំ២០១៤ ជាពិសេសប្រធាន និងអនុប្រធានទី២រដ្ឋសភា ត្រូវបានដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ចំណែកឯអនុប្រធានទី១នៃរដ្ឋសភា ដឹកនាំដោយគណបក្សសង្គ្រោះជាតិ ។

ការផ្លាស់ប្តូរតំណាងរាស្ត្រនៅក្នុងបញ្ជីរបស់គណបក្សនយោបាយ និងថ្នាក់ដឹកនាំរដ្ឋសភា (អនុប្រធានរដ្ឋសភា) ធ្វើឡើងដោយមិនមានតម្លាភាព និងមិនមាននីតិវិធីច្បាស់លាស់នៅខណៈដែលអ្នកតំណាងរាស្ត្រមិនមានអំណាច ប៉ុន្តែបានផ្តល់អំណាចយ៉ាងធំធេងដល់ប្រធានគណបក្សនយោបាយ ។ ការមិនមាននីតិវិធីច្បាស់លាស់នេះ បានធ្វើឲ្យប៉ះពាល់ដល់តួនាទីរបស់ស្ត្រីមុនគេ ដូចជាករណីលោកជំទាវ **ឃួន សុដារី**ត្រូវបានសមាជិកសភាកម្ពុជាដកតំណែងជាអនុប្រធានទី២ឲ្យទៅបុរសវិញ ដែលជាផ្លែផ្កានៃកិច្ចព្រមព្រៀង[1]បញ្ចប់ជំលោះនយោបាយរវាងបុរស និងបុរសមកពីគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា ដែលនេះគឺជាការបន្ថយតួនាទីដ៏សំខាន់របស់ស្ត្រីនៅក្នុងរដ្ឋសភា ។

តំណាងរាស្ត្រស្ត្រីដែលបានឡើងបញ្ចេញមតិក្នុងកិច្ចប្រជុំសភាពេញអង្គមានចំនួន៤នាក់ (១៦%) ក្នុងចំណោមតំណាងរាស្ត្រស្ត្រីចំនួន២៥នាក់ ជាភាគរយប្រហាក់ប្រហែលនឹងតំណាងរាស្ត្របុរសដែលបានឡើងបញ្ចេញមតិមានចំនួន១៩នាក់ (១៩,៣៨%)ក្នុងចំណោមតំណាងរាស្ត្របុរសចំនួន៩៨នាក់ ។

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានអំពី សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ បង្ហាញថា ក្នុងរយៈពេលចាប់ពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែតុលា ឆ្នាំ២០១៤ មានតំណាងរាស្ត្រចំនួន**៩៦នាក់** (៥០នាក់មកពីគណបក្សប្រជាជនកម្ពុជា ក្នុងនោះមាន**ស្ត្រី១៥នាក់** និង៤៦នាក់មកពីគណបក្សសង្គ្រោះជាតិ ក្នុងនោះមាន**ស្ត្រី៦នាក់**)ក្នុងចំណោមតំណាងរាស្ត្រ១២៣នាក់ បានចុះមូលដ្ឋានចំនួន១២៧៤លើក ។

ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្ម ច្រើនជាងភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម គឺ **៨៤%** ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី**២១នាក់** ក្នុងចំណោមសមាជិកសភាស្ត្រី២៥នាក់ ខ្ពស់ជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសដែលមានចំនួនតែ **៧៦,៥៣%** ស្មើនឹង **៧៥នាក់** ក្នុងចំណោមសមាជិកសភាបុរស៩៨នាក់ ។

បើប្រៀបធៀបពីគោលបំណងមួយទៅគោលបំណងមួយនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី ក៏បង្ហាញឲ្យឃើញដែរថា មានការខុសគ្នាឆ្ងាយរវាងតួលេខនៃការចុះ*សំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលមានចំនួន១២២លើក (៥១,២៦%) ជាមួយនឹងចំនួន១២លើក (៥,០៤%)នៃការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ ខណៈដែលសកម្មភាពគ្រាន់តែអមដំណើរអ្នកដឹកនាំសោះ មានចំនួនរហូតដល់ទៅ៧២លើក (៣០,២៥%) ។*

[1] លទ្ធផលនៃកិច្ចព្រមព្រៀងនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ នៃថ្នាក់ដឹកនាំកំពូលគណបក្សជាប់ឆ្នោតទាំងពីរ តំណែងដឹកនាំកំពូលរួមមានប្រធានសភា និងអនុប្រធានទី២នៃអាណត្តិទី៥នឹងត្រូវគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា ។ ចំណែកឯអនុប្រធានទី១នៃរដ្ឋសភាគ្រប់គ្រងដោយគណបក្សសង្គ្រោះជាតិ

សកម្មភាពតំណាងរាស្ត្រស្ត្រីនៅថ្នាក់ជាតិ និងតាមមណ្ឌលនៅអាណត្តិទី៥នេះ មានភាពសកម្មគួរឲ្យកត់សម្គាល់ទាំងតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រឆាំង និងគណបក្សកាន់អំណាច ជាពិសេសការចេញមកទទួលញត្តិពីក្រុមបាតុករដែលទាមទារដោះស្រាយបញ្ហារបស់ពួកគេ ការចូលរួមវេទិកានានា និងការចុះទៅផ្ទាល់តំបន់ដែលមានបញ្ហាដើម្បីដោះស្រាយជូនប្រជាពលរដ្ឋ ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី៧ មាត្រា៧៧ ចែងថា *«តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ»* ។

នៅក្នុងការអនុវត្តនារីរតនៈទី៣ (២០០៩-២០១៣)[2] រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធនានាទទួលបានជោគជ័យគួរជាទីកត់សម្គាល់ក្នុងការចូលរួមចំណែកលើកកម្ពស់គោលនយោបាយ ច្បាប់ និងកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យឆ្លើយតបនឹងយេនឌ័រ មានដូចជា ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី ការចូលរួមធ្វើឲ្យប្រសើរឡើងនូវសុខភាព និងអាហារូបត្ថម្ភសម្រាប់ស្ត្រី និងក្មេងស្រី ការទប់ស្កាត់ការរីករាលដាលជំងឺអេដស៍ ការលើកកម្ពស់ការចូលរួមរបស់កុមារី និងស្ត្រីក្នុងការអប់រំសិក្សា និងការបង្កើនការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយនៅគ្រប់កម្រិត និងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងវិស័យពាក់ព័ន្ធ ។

ទន្ទឹមនឹងភាពរីកចម្រើនគួរកត់សម្គាល់ ក៏នៅមានបញ្ហាប្រឈមជាច្រើនក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅប្រទេសកម្ពុជា ។ ជាក់ស្តែង ប្រាក់ឈ្នួលរបស់ស្ត្រីនៅមានកម្រិតទាបនៅឡើយ ស្ត្រីកាន់តែច្រើនកំពុងចំណាកស្រុកពីជនបទមកទីក្រុង និងទៅក្រៅប្រទេសដើម្បីស្វែងរកការងារ និងជួបហានិភ័យច្រើនជាងបុរសរួមទាំងអំពើហិង្សាលើរាងកាយផងដែរ ។ នៅមានវិសមភាពយេនឌ័រនៅឡើយនៅមធ្យមសិក្សាទុតិយភូមិ និងកម្រិតឧត្តមសិក្សា ការខ្វះខាតអ្នកផ្តល់សេវាដែលមានជំនាញនៅតំបន់ដាច់ស្រយាល ការខ្វះខាតឱសថ និសម្ភារៈបរិក្ខាទំនើបនៅក្នុងមូលដ្ឋានសុខាភិបាល ។ ស្ត្រី និងក្មេងស្រីមួយចំនួនទទួលរងគ្រោះខ្លាំងនូវអំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងការរំលោភសេពសន្ថវៈ ។ បច្ចុប្បន្នពុំទាន់មានការយកចិត្តទុកដាក់លើការបង្ការ ការចម្លងមេរោគអេដស៍ទៅលើស្ត្រីក្នុងករណីដែលមានការបំពានផ្លូវភេទ និងក្នុងចំណោមស្ត្រីដែលប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍ ។ កិច្ចគាំពារដល់កុមារនៅមានកម្រិតជាពិសេសសម្រាប់កុមារីទាក់ទងនឹងការធ្វើដំណើរទៅមកដោយសុវត្ថិភាព និងសុខភាពអនាម័យ ។ ទិន្នន័យដែលផ្តល់ដោយជនរងគ្រោះទាក់ទងនឹងអំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទនៅមានកម្រិត ខណៈដែលករណីកើតឡើងជាក់ស្តែងគឺមានការកើនឡើងច្រើន ។ ជនល្មើសមួយចំនួនធំមិនប្រឈមនឹងការផ្តន្ទាទោសចំពោះបទល្មើសរបស់ពួកគេ ។ ការរើសអើងចំពោះស្ត្រីនៅបន្តកើតមាន និងជាឧបសគ្គដល់ការទទួលបានការតែងតាំងក្នុងមុខតំណែងនានា ។ មិនទាន់មានវិធានការវិជ្ជមានបណ្តោះ

[2] របាយការណ៍របស់ក្រសួងកិច្ចការនារី ស្តីពី «សមិទ្ធផលចម្បងៗ និងបញ្ហាប្រឈម» នៅក្នុងឯកសារនារីរតនៈទី៤ ទំព័រទី២

អាសន្នសមស្របនៅឡើយ ដើម្បីពន្លឿនការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ ។ ថវិកាសម្រាប់អនុវត្តការបញ្ជ្រាបយេនឌ័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ។ គោលនយោបាយ និងកម្មវិធីយេនឌ័រតាមក្រសួង ស្ថាប័នពុំសូវមានការត្រួតពិនិត្យ តាមដានវាយតម្លៃទៅតាមតម្រូវការបញ្ជ្រាបយេនឌ័រជាក់ស្តែង ។ល។ និង។ល។

ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ចាប់ផ្តើមប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន មានភាពជឿជាក់លើខ្លួនឯង និងក្លាហានក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំនានាបើទោះបីជួបនូវឧបសគ្គខ្លះៗក៏ដោយ ។ កិច្ចការ និងមតិយោបល់របស់ស្ត្រីភាគច្រើនផ្តោតលើផលប្រយោជន៍ស្ត្រី និងកុមារជាសំខាន់ ខណៈដែលបុរសភាគច្រើនរួមទាំងផ្នត់គំនិតសង្គម មានការប្តូរឥរិយាបថមកឲ្យតម្លៃស្ត្រីយល់ថាការចូលរួមរបស់ស្ត្រីពិតជាមានសារៈសំខាន់ ជាពិសេសការចូលរួមនៅថ្នាក់សម្រេចចិត្តជាមួយនឹងការគាំទ្រយ៉ាងពេញទំហឹងពីក្រុមគ្រួសារ និងប្រជាពលរដ្ឋ ។ លើសពីនេះ បញ្ហាស្ត្រី និងកុមារ ក៏ត្រូវបានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងបុរស ទាំងស្ត្រីចាត់ជាបញ្ហាចម្បង និងត្រូវយកចិត្តទុកដាក់ដោះស្រាយជាបន្តបន្ទាប់ ។

ទោះជាយ៉ាងនេះក្តី ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅតែបន្តមាននៅឡើយដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ដោះស្រាយជាចាំបាច់ ។ រីឯថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារនៅមានការលំបាកក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវការនៃការងារព្រមទាំងតម្លាភាពថវិកាក៏នៅមានកម្រិត ។

## I. ការឃ្លាំមើលសភា និងតំណាងរាស្ត្រស្ត្រី

### ១. ដំណើរការសម័យប្រជុំសភា

ការសង្កេតឃ្លាំមើលសភារបស់អង្គការ**ខុមហ្វ្រែល** ក្នុងចន្លោះពេលពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែតុលា ឆ្នាំ២០១៤ ឆ្នាំទី១នៃដើមនីតិកាលទី៥នេះ រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គសាមញ្ញរបស់ខ្លួនចំនួន៣លើក និងបើកកិច្ចប្រជុំវិសាមញ្ញ ចំនួន៣លើក ។

**ការប្រជុំពេញអង្គរដ្ឋសភាឯកបក្ស និងខ្វះនីត្យានុកូលភាព៖** រដ្ឋសភានីតិកាលទី៥ ក្នុងឆ្នាំទី១នេះពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែកក្កដា ឆ្នាំ២០១៤ បានបើកសម័យប្រជុំពេញអង្គសាមញ្ញរបស់ខ្លួនចំនួន២លើក និងប្រជុំពេញអង្គវិសាមញ្ញចំនួន ១លើក ។ សម័យប្រជុំពេញអង្គលើកទី១ចន្លោះពេលពីខែតុលាដល់ខែធ្នូ ឆ្នាំ២០១៣ និងលើកទី២ចន្លោះខែមេសា ដល់ខែមិថុនា ឆ្នាំ២០១៤។ រដ្ឋសភាឯកបក្សដែលមានតែគណបក្សប្រជាជនកម្ពុជាបានអនុម័តច្បាប់ដ៏ចម្រូងចម្រាសចំនួនបីទាក់ទងនឹងវិស័យតុលាការ និងច្បាប់ថវិកាជាតិគ្រប់គ្រងឆ្នាំ២០១៤ ។

**ការប្រជុំពេញអង្គរដ្ឋសភាដែលមានទម្រង់ពេញលេញ** គឺនៅពេលដែលគណបក្សទទួលអាសនៈក្នុងរដ្ឋសភាទាំងពីរបានចូលរួមក្នុងដំណើរការរបស់រដ្ឋសភាពីខែសីហា ដល់ខែតុលា ឆ្នាំ២០១៤ ។ ការសង្កេតឃើញថា មានកិច្ចប្រជុំពេញអង្គចំនួន៣លើក ដែលក្នុងនោះប្រជុំវិសាមញ្ញចំនួន២លើក (ទី១ ពិភាក្សា និងអនុម័តវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងទី២ ការបោះឆ្នោតជ្រើសតាំងអនុប្រធានទី១ និងអនុប្រធានទី២នៃរដ្ឋសភា និងការបោះឆ្នោតជ្រើសតាំងជំនួស និងបំពេញបន្ថែមសមាជិកគណៈកម្មការនានានៃរដ្ឋសភា) និងប្រជុំសាមញ្ញចំនួន១លើក ដោយបានពិភាក្សា និងអនុម័តរបៀបវារៈចំនួន៤ ដែលក្នុងនោះ វិសោធនកម្មច្បាប់ចំនួនពីរ និងផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងចំនួនពីរ ។

រដ្ឋសភាមានរបៀបវារៈចំនួន៣៦ ដែលតម្រូវយកមកពិភាក្សា រួមទាំងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ។ ក្នុងរបៀបវារៈទាំង៣៦ រដ្ឋសភាយកមកពិភាក្សា និងអនុម័តនោះរួមមាន *សេចក្តីព្រាងច្បាប់ចំនួន១៤ ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងចំនួន១៨ច្បាប់ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន៤លើក វិសោធនកម្មច្បាប់ចំនួន៣ច្បាប់ និងការឆ្លើយបំភ្លឺផ្ទាល់មាត់នៅក្នុងសភាចំនួន១លើក* ។ ក្នុងឆ្នាំទី១ នីតិកាលទី៥នេះ សភាជាតិមិនសូវមមាញឹកក្នុងការប្រជុំពិភាក្សា និងអនុម័តច្បាប់នោះទេក្នុងអំឡុងរយៈពេលរបាយការណ៍ខុមហ្វ្រែល រដ្ឋសភាបានដំណើរការកោះអញ្ជើញតំណាងរាស្ត្រចូលរួមកិច្ចប្រជុំបានចំនួន១១លើក ដំណើរការកិច្ចប្រជុំ២០កិច្ចប្រជុំ។ តែបើគិតជាមធ្យមក្នុង១កិច្ចប្រជុំ ចំណាយពេលវេលាត្រឹមតែ១ព្រឹកប៉ុណ្ណោះក្នុងការពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់/ស្នើច្បាប់នានាដែលចូលរដ្ឋសភា ។[3]

### ១.១. ការបញ្ចេញមតិយោបល់ជាបរិមាណរបស់សមាជិកសភាជាស្ត្រីនៅក្នុងពេលប្រជុំពេញអង្គរដ្ឋសភា

តារាងទី១៖ ចំនួនតំណាងរាស្ត្រស្ត្រី ឡើងបញ្ចេញមតិធៀបនឹងគណបក្សរបស់ខ្លួន និងតំណាងរាស្ត្រប្រុស

| គណបក្ស | ចំនួនតំណាងរាស្ត្រក្នុងគណបក្ស | | | | តំណាងរាស្ត្របានឡើងបញ្ចេញមតិតាមភេទ | |
|---|---|---|---|---|---|---|
| | ៦៨នាក់ | | | | ១៩ នាក់ | |
| | ស្ត្រី | % | ប្រុស | % | ស្ត្រី | ប្រុស |

---
[3] របាយការណ៍ឃ្លាំមើលសភា និងតំណាងរាស្ត្រ ឆ្នាំទី១ នីតិកាលទី៥ របស់ខុមហ្វ្រែល ចេញផ្សាយ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥

| | | | | | | |
|---|---|---|---|---|---|---|
| **ប្រជាជនកម្ពុជា** | ១៨នាក់ | ២៦,៤៧% | ៥០នាក់ | ៧៣,៥២% | ៤នាក់ | ១៥នាក់ |
| **សង្គ្រោះជាតិ** | **៥៥នាក់** | | | | **៤នាក់** | |
| | ស្ត្រី | % | បុរស | % | ស្ត្រី | បុរស |
| | ៧នាក់ | ១២,៧២% | ៤៨នាក់ | ៨៧,២៧% | ០ | ៤នាក់ |

ការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រគិតជាបរិមាណសរុបចំនួន២៣នាក់ ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភាសម្រាប់របាយការណ៍ឆ្នាំទី១នៃនីតិកាលទី៥នេះឃើញថា ការឡើងបញ្ចេញមតិយោបល់ភាគច្រើនជាអ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា ខណៈដែលការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សសង្គ្រោះជាតិមានចំនួនតិចតួច **នេះក៏ព្រោះតែតំណាងរាស្ត្រគណបក្សជំទាស់នេះ ទើបតែសម្រេចចូលរដ្ឋសភានៅចុងឆ្នាំទី១នៃឆ្នាំសង្កេតការណ៍**[4] ។

## ភាគរយនៃអ្នកតំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិយោបល់ធៀបនឹងគណបក្សរបស់ខ្លួន

ក្នុងចំណោមតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា មាន៦៨អាសនៈនៅក្នុងរដ្ឋសភា មានតំណាងរាស្ត្រតែ១៩នាក់ប៉ុណ្ណោះបានឡើងបញ្ចេញមតិសរុបចំនួន៦៣២នាទី ស្មើនឹង ១០ម៉ោង និង៣២នាទី ដែលក្នុងនោះ មានតំណាងរាស្ត្រស្ត្រីចំនួន៤នាក់ ស្មើនឹង ២២,២២%ក្នុងចំណោមតំណាងរាស្ត្រស្ត្រី១៨នាក់បានឡើងបញ្ចេញមតិ។ រីឯតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិដែលមានអាសនៈ៥៥នាក់ នៅក្នុងរដ្ឋសភា មានតំណាងរាស្ត្របុរសចំនួនតែ៤នាក់បានឡើងបញ្ចេញមតិសរុបចំនួន៦១នាទី ស្មើនឹង ១ម៉ោង និង១នាទី ដែលក្នុងនោះមិនមានតំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិទេ ។

## ចំនួននៃអ្នកតំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិយោបល់ធៀបនឹងតំណាងរាស្ត្របុរស

ខណៈដែលតំណាងរាស្ត្របុរសមានចំនួនដល់ទៅ៩៨នាក់ក្នុងនីតិកាលទី៥នេះក៏ដោយ តំណាងរាស្ត្របុរសដែលបានឡើងបញ្ចេញមតិមានចំនួនតែ១៩នាក់ប៉ុណ្ណោះ ។ ដោយឡែកតំណាងរាស្ត្រស្ត្រីដែលបានឡើងបញ្ចេញមតិមានចំនួន៤នាក់ ក្នុងចំណោមតំណាងរាស្ត្រស្ត្រីចំនួន២៥នាក់ ។

មិនមានសម្លេងរបស់សមាជិកសភាស្ត្រីមកពីគណបក្សសង្គ្រោះជាតិ ដោយសារតែក្នុងអំឡុងពេលនៃកិច្ចប្រជុំសភាធ្វើឡើងមុនខែកញ្ញា ឆ្នាំ២០១៤នោះមានតែសមាជិកសភាស្ត្រីចំនួន៤នាក់មកពីគណបក្សប្រជាជនកម្ពុជាចូលរួមប៉ុណ្ណោះ និងបានឡើងបញ្ចេញមតិចំនួន១២លើក ដោយចំណាយរយៈពេលសរុបចំនួន៨៦នាទីស្មើនឹង១២,៤០%នៃរយៈពេលបញ្ចេញមតិសរុប ៦៩៣នាទី ។

[4] ការចូលប្រជុំសភាពហុបក្សដំបូងថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤

### ១.២. គុណភាពមតិពិភាក្សារបស់អ្នកតំណាងរាស្ត្រស្ត្រី

ខ្លឹមសារមតិរបស់អ្នកតំណាងរាស្ត្រដែលបានបញ្ចេញនៅក្នុងអំឡុងពេលប្រជុំពេញអង្គ ត្រូវបានវិភាគដោយបែងចែកជា**បីសូរ (Tone)** គឺៈ អព្យាក្រឹត្យ វិជ្ជមាន និងអវិជ្ជមានចំពោះស្ថាប័ន របៀបវារៈ ឬតួអង្គ/ស្ថាប័នរដ្ឋាភិបាលណាមួយដែលអ្នកតំណាងរាស្ត្រនិយាយសំដៅទៅ ។ ខ្លឹមសារ**អព្យាក្រឹត្យ***គឺសំដៅលើមតិធម្មតាទៅលើតួអង្គ ឬស្ថាប័នណាមួយ* ។ ចំណែកឯ**វិជ្ជមាន** *គឺផ្តោតលើការលើកសរសើរពីគុណសម្បត្តិសេចក្តីព្រាងច្បាប់គោលនយោបាយ ឬតួអង្គ ឬស្ថាប័នណាមួយ* ។ រីឯ **អវិជ្ជមាន**វិញ *គឺនិយាយពីគុណវិបត្តិរបស់តួអង្គ ឬស្ថាប័នណាមួយ*។

**<u>តារាងទី២៖</u> ការបង្ហាញពីអ្នកតំណាងរាស្ត្រស្ត្រីឡើងសំដែងមតិ**

| ល.រ | ឈ្មោះ តំណាងរាស្ត្រ ស្ត្រី | គណបក្ស | ចំនួនឡើង សំដែងមតិ | ការសំដែងមតិក្នុងន័យ (គិតជានាទី) | | | ចំនួននាទី ឡើង សំដែង មតិសរុប |
|---|---|---|---|---|---|---|---|
| | | | | អព្យាក្រិត្យ | វិជ្ជមាន | អវិជ្ជមាន | |
| ១ | ឡោក ខេង | ប្រជាជនកម្ពុជា | ៨ | ៣៩ | ២៧ | ០ | ៦៦ |
| ២ | និន សាផុន | ប្រជាជនកម្ពុជា | ២ | ៧ | ៨ | ០ | ១៥ |
| ៣ | អ៊ុន សុគន្ធា | ប្រជាជនកម្ពុជា | ១ | ០ | ៣ | ០ | ៣ |
| ៤ | ហ៊ូ ណូន | ប្រជាជនកម្ពុជា | ១ | ០ | ២ | ០ | ២ |
| សរុប | | | ១២ | ៤៦ | ៤០ | ០ | ៨៦ |

តារាងខាងលើបង្ហាញថា អ្នកតំណាងរាស្ត្រស្ត្រីទាំង៤នាក់ដែលបានឡើងសំដែងមតិមាន១២លើក ចំណាយពេលសរុបអស់ ៨៦នាទី ស្មើនឹង១ម៉ោង និង២៦នាទី ។ ការសំដែងមតិក្នុងន័យ**អព្យាក្រិត្យ** មានចំនួន៤៦នាទី និង**ខ្លឹមសារវិជ្ជមាន**បានចំនួន៤០នាទីនៃរយៈពេលសរុប *ដោយផ្តោតទៅលើខ្លឹមសារមួយចំនួនដូចជា សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល ដោយចាប់អារម្មណ៍ជាពិសេសលើវិស័យធនធានមនុស្ស វិស័យអគ្គីសនីក្នុងឆ្នាំ២០២០ដោយធ្វើឲ្យមានអគ្គីសនីប្រើប្រាស់គ្រប់ៗគ្នា ការគាំទ្រលើការកែទម្រង់គ្រប់ជ្រុងជ្រោយក្នុងការបង្កើតក្រសួងមុខងារសាធារណៈ សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការសុំចូលរួមជាភាគីហត្ថលេខីរបស់ព្រះរាជាណាចក្រកម្ពុជានៅក្នុងពិធីសារនៃវិសោធនកម្មលើអនុសញ្ញាអន្តរជាតិ ស្តីពីសាមញ្ញកម្ម និងសុខដុមនីយកម្មនីតិវិធីគយ សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើលិខិតសន្យាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះ*

*រាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនស៊ីធីលុម**អេសអេ**សម្រាប់គម្រោងវិនិយោគសាងសង់ ផ្ទេរ និងប្រតិបត្តិការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សេវាបំភ្លឺសាធារណៈនៅរាជធានីភ្នំពេញ សារាចរបស់រាជរដ្ឋាភិបាលអនុញ្ញាតិឲ្យវិនិយោគផ្ទេរ និងប្រតិបត្តិការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សេវាបំភ្លឺសាធារណៈនៅរាជធានីភ្នំពេញ និងសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ។*

### ១.៣. មតិយោបល់របស់តំណាងរាស្ត្រស្ត្រី និងបុរសដែលបានលើកឡើងទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ

ការសង្កេតបង្ហាញឲ្យឃើញថា ក្នុងឆ្នាំទី១នៃនីតិកាលទី៥នេះ ***បញ្ហាស្ត្រី និងកុមារ*** មិនត្រូវបានលើកយកមកដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំទេ ។ បន្ថែមទៅលើនោះទៀត រាល់កិច្ចពិភាក្សាពុំបានឆ្លុះបញ្ចាំងពីផលប្រយោជន៍ និងផលប៉ះពាល់ដល់ស្ត្រី និងកុមារទេ នេះរួមទាំងអ្នកតំណាងរាស្ត្រស្ត្រីទាំងបុរសផងដែរ ។ លើសពីនេះទៀត ពួកគាត់ក៏មិនបានលើកឡើងអំពីស្ត្រី និងកុមារដែលបាន និងកំពុងរងគ្រោះនូវគ្រប់ទម្រង់នៃការរើសអើង ការរំលោភបំពានជារៀងរាល់ថ្ងៃ ជាពិសេសកើតចេញពីផែនការអភិវឌ្ឍន៍ ទោះបីជាគណបក្សជាប់ឆ្នោតទាំងពីរបានសន្យាថា នឹងដោះស្រាយបញ្ហាស្ត្រី និងកុមារនៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក៏ដោយ ។

នេះបង្ហាញឲ្យឃើញថា ការដោះស្រាយបញ្ហាស្ត្រី និងកុមារ ពុំបានស្ថិតនៅក្នុងការចាប់អារម្មណ៍របស់អ្នកតំណាងរាស្ត្រឡើយ ហើយក៏ជាប្រធានបទដែលស្ថិតក្នុងការតម្កល់ទុកលើធ្នើចោលផងដែរ ថ្វីបើប្រជាពលរដ្ឋស្ត្រីមានចំនួនជាង៥២% និងចំនួនកុមារមាន៧០%នៃប្រជាពលរដ្ឋសរុបក៏ដោយ ។

## ២. សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋាន

<u>តារាងទី៣</u> ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រទាំងស្ត្រី និងបុរស

| គោលបំណង នៃការចុះមូលដ្ឋាន ទាំង១២៧៤លើក របស់អ្នកតំណាងរាស្ត្រ ទាំងស្ត្រី-បុរសចំនួន៩៦នាក់ | គណបក្សនយោបាយ | | | | សរុប |
|---|---|---|---|---|---|
| | ៥០នាក់ | | ៤៦នាក់ | | ៩៦នាក់ |
| | ស្ត្រី ១៥ នាក់ | បុរស ៣៥ នាក់ | ស្ត្រី ៦ នាក់ | បុរស ៤០ នាក់ | ស្ត្រី ២១នាក់ ប្រុស ៧៥នាក់ |

| | | | | | |
|---|---|---|---|---|---|
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា | ១០១ លើក | ២៥៨ លើក | ២១ លើក | ៣២៨ លើក | ៧០៨ លើក ៥៥,៥៧% |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ១២ លើក | ៩៥ លើក | ២០ លើក | ២០៩ លើក | ២៦៦ លើក ២០,៨៧% |
| ការចុះអមដំណើរជាក្រុម ឬ អមដំណើរថ្នាក់ដឹកនាំ | ៦២ លើក | ១០៦ លើក | ១០ លើក | ៦៧ លើក | ២៤៥ លើក ១៩,២៣% |
| ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល | ០ | ៥ លើក | ០ | ៣ លើក | ៨ លើក ០,៦២% |
| ការអន្តរាគមន៍ និង ដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ | ៧ លើក | ១៤ លើក | ៥ លើក | ២១ លើក | ៤៧ លើក ៣,៦៨% |
| **សរុបគោលបំណងតាមគណបក្ស** | **១៨២ លើក** | **៤២៨ លើក** | **៥៦ លើក** | **៦០៨ លើក** | **១២៧៤ លើក ១០០%** |
| សរុបរួម | **៦១០ លើក ៤៧,៨៨%** | | **៦៦៤ លើក ៥២,១១%** | | |

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានអំពី សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ តាមរយៈការចុះសង្កេតដោយផ្ទាល់ ប្រព័ន្ធផ្សព្វផ្សាយ ការិយាល័យអ្នកតំណាងរាស្ត្រតាមមណ្ឌលខេត្ត និងតាមរយៈស្នាក់ការគណបក្សនយោបាយនៅតាមបណ្តាខេត្តឃើញថា ក្នុងរយៈពេលចាប់ពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែតុលា ឆ្នាំ២០១៤ មានតំណាងរាស្ត្រចំនួន**៩៦នាក់** (៥០នាក់មកពីគណបក្សប្រជាជនកម្ពុជា ក្នុងនោះមាន**ស្ត្រី១៥នាក់** និង៤៦នាក់មកពីគណបក្សសង្គ្រោះជាតិ ក្នុងនោះមាន**ស្ត្រី៦នាក់**)ក្នុងចំណោមតំណាងរាស្ត្រ១២៣នាក់ បានចុះមូលដ្ឋានចំនួន១២៧៤លើក ។ គ្រប់សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គឺបានធ្វើឡើងក្នុងគោលបំណងសំខាន់ៗចំនួន**៥** រួមមាន *ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយជូនប្រជាពលរដ្ឋ និងសម្ពោធសមិទ្ធិផលនានា ការចុះពង្រឹងផ្ទៃក្នុង*

*និងបណ្តាញគណបក្ស ការចុះអមដំណើរថ្នាក់ដឹកនាំ ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការស៊ីវិល និងការចុះជួយអន្តរាគមន៍ ដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ។*[5]

គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ បង្ហាញថា ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយជូនប្រជាពលរដ្ឋ និងសម្ពោធសមិទ្ធិផលនានាមានចំនួនដល់ទៅ*៧០៨លើក (៥៥,៥៧%)ជាតួលេខខ្ពស់ជាងគេបំផុត* ខណៈដែលការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមាន*ចំនួន២៦៦លើក (២០,៨៧%)* និងការចុះអមដំណើរថ្នាក់ដឹកនាំមាន*ចំនួន២៤៥លើក (១៩,២៣%) ជាតួលេខខ្ពស់បន្ទាប់* ។ ផ្ទុយទៅវិញ ការ*ចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋដែលជាសកម្មភាពរបស់អ្នកតំណាងរាស្ត្របានធ្វើនោះ នៅមានកម្រិតទាបបំផុតចំនួនតែ៣,៦៨%(៤៧លើក) ប៉ុណ្ណោះ ។*

## ២.១. ការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី

<u>តារាងទី៤</u> ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី

| គោលបំណងនៃការចុះមូលដ្ឋានទាំង២៣៨លើក របស់អ្នកតំណាងរាស្ត្រស្ត្រី ចំនួន២១នាក់ | គណបក្សនយោបាយ | | សរុប |
|---|---|---|---|
| | ១៥ នាក់ | ៦ នាក់ | ២១ នាក់ |
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ និង ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា | ១០១ លើក | ២១ លើក | ១២២ លើក ៥១,២៦%) |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ១២ លើក | ២០ លើក | ៣២ លើក ១៣,៤៥% |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ៦២ លើក | ១០ លើក | ៧២ លើក ៣០,២៥% |
| ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល | ០ | ០ | ០ ០% |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ | ៧ លើក | ៥ លើក | ១២ លើក ៥,០៤% |

[5] របាយការណ៍ឃ្លាំមើលសភា និងតំណាងរាស្ត្រ ឆ្នាំទី១ នីតិកាលទី៥ របស់ ខុមហ្វ្រែល ចេញផ្សាយ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥

| សរុបគោលបំណងតាមគណបក្ស | ១៨២ លើក ៧៦,៤៧% | ៥៦លើក ២៣,៥២% | ២៣៨ លើក (១០០%) |
|---|---|---|---|

ក្នុងរយៈពេលនេះ អ្នកតំណាងរាស្ត្រស្ត្រីទាំង២១នាក់នៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភាបានធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន ២៣៨លើក ក្នុងនោះ *ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាមានចំនួន ១២២លើក ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំមានចំនួន ៧២លើក ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សចំនួន៣២លើក និងការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា មាន១២លើក* ។ រីឯការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិលមិនឃើញមានអ្នកតំណាងរាស្ត្រស្ត្រីបានចូលរួមឡើយ ។

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបាន តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចុះធ្វើសកម្មភាពនៅមូលដ្ឋាន បានច្រើនជាងតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ ។ តំណាងរាស្ត្រស្ត្រីពីគណបក្សប្រជាជនកម្ពុជាចំនួន១៥នាក់ បានធ្វើសកម្មភាពក្នុងមូលដ្ឋានចំនួន ១៨២លើក ហើយតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិចំនួន៦នាក់ បានធ្វើសកម្មភាពចំនួន ៥៦ លើក ។

ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាទាំង១៥នាក់នោះ ផ្តោតទៅលើគោលបំណងចុះ*សំណេះសំណាលសួរសុខទុក្ខចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាបានចំនួន ១០១លើក ចុះអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួនបានចំនួន៦២លើក ចុះអន្តរាគមន៍បញ្ហានានារបស់ម្ចាស់ឆ្នោតចំនួន៧លើក និងការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សបានចំនួន១២លើក*។

ដោយឡែក តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិទាំង៦នាក់នេះ បានចុះមូលដ្ឋានផ្តោតលើគោលបំណងចុះសួរសុខទុក្ខប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតបានចំនួន២១លើក ចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សបានចំនួន២០លើក ចុះអមដំណើរថ្នាក់ដឹកនាំចំនួន១០លើក និងចុះអន្តរាគមន៍ ដោះស្រាយបញ្ហានានារបស់ម្ចាស់ឆ្នោតចំនួន៥លើក។

បើប្រៀបធៀបពីគោលបំណងមួយទៅគោលបំណងមួយនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី ក៏បង្ហាញឲ្យឃើញដូចគ្នាដែរថា មានការខុសគ្នាឆ្ងាយរវាងតួលេខនៃការចុះ*សំណេះសំណាលសួរសុខទុក្ខចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលមានចំនួន១២២លើក (៥១,២៦%) ជាមួយនឹងចំនួន ១២លើក (៥,០៤%)នៃការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ ខណៈដែលសកម្មភាពគ្រាន់តែអមដំណើរអ្នកដឹកនាំសោះ មានចំនួនរហូតដល់ទៅ៧២លើក (៣០,២៥%)* ។

**តារាងទី៥ ៖** ចំនួនតំណាងរាស្ត្រស្ត្រីធៀបនឹងតំណាងរាស្ត្របុរសដែលបានចុះបេសកកម្មគិតជាភាគរយ

| តំណាងរាស្ត្របានចុះបេសកកម្ម៩៦នាក់ | | | |
|---|---|---|---|
| ស្ត្រី | % | បុរស | % |
| ២១នាក់ | ៨៤% | ៧៥នាក់ | ៧៦,៥៣% |

របាយការណ៍នេះក៏បានបង្ហាញដែរថា ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្មច្រើនជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម គឺ ៨៤% ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី២១នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៥នាក់ ខ្ពស់ជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសដែលមានចំនួនតែ ៧៦,៥៣% ស្មើនឹង៧៥នាក់ក្នុងចំណោមសមាជិកសភាបុរស៩៨នាក់ ។ នេះបង្ហាញឲ្យឃើញថា សមាជិកសភាស្ត្រីគឺមានភាពសកម្មក្នុងការចុះមូលដ្ឋានជាងសមាជិកសភាបុរស ។

**តារាងទី៦ ៖** ភាគរយអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មធៀបនឹងអ្នកតំណាងរាស្ត្របុរសនៃគណបក្សនីមួយៗ

| គណបក្ស | តំណាងរាស្ត្របានចុះបេសកកម្មធៀបនឹងចំនួនអាសនៈនៅក្នុងបក្សតាមភេទ | | | |
|---|---|---|---|---|
| ប្រជាជនកម្ពុជា | ៥០នាក់(៧៣,៥២%) | | | |
| | ស្ត្រី | %នៃសមាជិកសភាស្ត្រី | បុរស | %នៃសមាជិកសភាបុរស |
| | ១៥នាក់ | ៨៣,៣៣% | ៣៥នាក់ | ៧០% |
| សង្គ្រោះជាតិ | ៤៦នាក់(៨៣,៦៣%) | | | |
| | ស្ត្រី | %នៃសមាជិកសភាស្ត្រី | បុរស | %នៃសមាជិកសភាបុរស |
| | ៦ | ៨៥,៧១% | ៤០ | ៨៣,៣៣% |

ដោយធ្វើការប្រៀបធៀបនៅក្នុងគណបក្ស របាយការណ៍ឃ្លាំមើលរបស់ខុមហ្វ្រែលរកឃើញថា ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជា បានចុះបេសកកម្មមានចំនួន ៨៣,៣៣% (១៥នាក់ក្នុងចំណោម១៨នាក់) ច្រើនជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួនដែលមានចំនួនតែ៧០% (៣៥នាក់ក្នុងចំណោម៥០នាក់) ប៉ុណ្ណោះ ។ ដូចគ្នាផងដែរ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិក៏មានចំនួនច្រើនជាង ភាគរយរបស់អ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួនដែលបានចុះបេសកកម្ម គឺ ភាគរយស្ត្រីស្មើនឹង ៨៥,៧១% (៦នាក់ ក្នុងចំណោម៧នាក់) និងភាគរយបុរសមានចំនួនតែ៨៣,៣៣% (៤០នាក់ ក្នុងចំណោម ៤៨នាក់) ។

តារាងទី៧៖ ចំនួនចុះបេសកកម្មនៃតំណាងរាស្ត្រស្ត្រីម្នាក់ៗ

**អក្សរកាត់គោលបំណងនៃបេសកកម្មទាំង៥គឺ ៖**

(ក) ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា

(ខ) ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស

(គ) ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ

(ឃ) ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល

(ង) ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា

| ល.រ | ឈ្មោះតំណាងរាស្ត្រ ស្ត្រី | គណបក្ស | គោលបំណងនៃបេសកកម្ម | | | | | |
|---|---|---|---|---|---|---|---|---|
| | | | (ក) | (ខ) | (គ) | (ឃ) | (ង) | សរុប |
| ១ | លី គឹមលៀង | ប្រជាជនកម្ពុជា | ២៩ | ០ | ៩ | ០ | ២ | ៤០ |
| ២ | កែ ច័ន្ទមុនី | ប្រជាជនកម្ពុជា | ២៣ | ៣ | ២ | ០ | ២ | ៣០ |
| ៣ | ម៉ែន សំអន | ប្រជាជនកម្ពុជា | ៦ | ០ | ២០ | ០ | ០ | ២៦ |
| ៤ | មួរ សុខហួរ | សង្គ្រោះជាតិ | ១៣ | ៤ | ៥ | ០ | ១ | ២៣ |
| ៥ | ត្រឹង ថារី | ប្រជាជនកម្ពុជា | ៨ | ៣ | ៥ | ០ | ០ | ១៦ |
| ៦ | ស៊ុន សាភឿន | ប្រជាជនកម្ពុជា | ៩ | ៣ | ១ | ០ | ០ | ១៣ |
| ៧ | និន សាផុន | ប្រជាជនកម្ពុជា | ៥ | ០ | ៨ | ០ | ០ | ១៣ |
| ៨ | ជូឡុង សូមូរ៉ា | សង្គ្រោះជាតិ | ២ | ៧ | ២ | ០ | ០ | ១១ |
| ៩ | នួម សុភ័ណ | ប្រជាជនកម្ពុជា | ៩ | ០ | ០ | ០ | ០ | ៩ |
| ១០ | ពត ពៅ | សង្គ្រោះជាតិ | ៣ | ២ | ២ | ០ | ២ | ៩ |
| ១១ | ឃួន សុដារី | ប្រជាជនកម្ពុជា | ៤ | ០ | ៥ | ០ | ០ | ៩ |
| ១២ | កែ សុវណ្ណរតន៍ | សង្គ្រោះជាតិ | ២ | ៤ | ១ | ០ | ២ | ៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៣ | ហូ ណូន | ប្រជាជនកម្ពុជា | ១ | ០ | ៦ | ០ | ០ | ៧ |
| ១៤ | ឡោក ខេង | ប្រជាជនកម្ពុជា | ៣ | ០ | ១ | ០ | ៣ | ៧ |
| ១៥ | បាន ស្រីមុំ | ប្រជាជនកម្ពុជា | ៣ | ១ | ០ | ០ | ០ | ៤ |
| ១៦ | អ៊ុន សុគន្ធា | ប្រជាជនកម្ពុជា | ១ | ១ | ១ | ០ | ០ | ៣ |
| ១៧ | លី ស្រីវីណា | សង្គ្រោះជាតិ | ១ | ២ | ០ | ០ | ០ | ៣ |
| ១៨ | ចែម សាវ៉ៃ | ប្រជាជនកម្ពុជា | ០ | ១ | ១ | ០ | ០ | ២ |
| ១៩ | ដួង វណ្ណា | ប្រជាជនកម្ពុជា | ០ | ០ | ២ | ០ | ០ | ២ |
| ២០ | គ្រួច សំអាន | ប្រជាជនកម្ពុជា | ០ | ០ | ១ | ០ | ០ | ១ |
| ២១ | តៃ ច័ន្ទមនី | សង្គ្រោះជាតិ | ០ | ១ | ០ | ០ | ០ | ១ |
| សរុប | | | ១២២ | ៣២ | ៧២ | ០ | ១២ | ២៣៨ |

តារាងទី៧ បង្ហាញថា តំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្ម**ច្រើនជាងគេបំផុត** នៅក្នុងឆ្នាំសង្កេតទី១ នេះ គឺ **លោកជំទាវ លី គឹមលៀង** តំណាងរាស្ត្រមណ្ឌលបាត់ដំបងមកពីគណបក្សប្រជាជនកម្ពុជាមានចំនួន ៤០លើក ។ អ្នកដែល**ច្រើនបន្ទាប់**មានចំនួន ៣នាក់ ក្នុងនោះ ២នាក់មកពីគណបក្សប្រជាជនកម្ពុជា និង១នាក់មកពីគណបក្សសង្គ្រោះជាតិ ។ រីឯអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មក្នុង**កម្រិតមធ្យម**មានចំនួន១០នាក់ ក្នុងនោះ៧នាក់មកពីគណបក្សប្រជាជនកម្ពុជា និង៣នាក់មកពីគណបក្សសង្គ្រោះជាតិ ។ ដោយឡែកអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មក្នុង**កម្រិតទាប**ជាងគេមានចំនួន៧នាក់ ក្នុងនោះគណបក្សប្រជាជនកម្ពុជាមានចំនួន៥នាក់ និងគណបក្សសង្គ្រោះជាតិមានចំនួន២នាក់ ។

## ៣. សកម្មភាពតំណាងរាស្ត្រស្ត្រីនៅថ្នាក់ជាតិ និងតាមមណ្ឌល

ខុសពីអាណត្តិមុនៗ[6] តំណាងរាស្ត្រស្ត្រីអាណត្តិទី៥នេះមានភាពសកម្មគួរឲ្យកត់សម្គាល់ទាំងតំណាងរាស្ត្រមកពីគណបក្សប្រឆាំង និងគណបក្សកាន់អំណាច ជាពិសេសការចេញមកទទួលញត្តិពីក្រុមបាតុករដែលទាមទារដោះស្រាយបញ្ហារបស់ពួកគេ ការចូលរួមវេទិកានានា និងការចុះទៅផ្ទាល់តំបន់ដែលមានបញ្ហាដើម្បីដោះស្រាយជូនប្រជាពលរដ្ឋ ដែលទង្វើទាំងនេះកម្រនឹងឃើញពីមុនណាស់ ជាពិសេសតំណាងរាស្ត្រស្ត្រីរបស់គណបក្សប្រជាជនកម្ពុជា ។

[6] តំណាងរាស្ត្រស្ត្រីមិនសូវមានភាពសកម្ម លើកលែងតែលោកជំទាវ មូរ សុខហួរមកពីគណបក្សប្រឆាំងដែលធ្លាប់ចេញលិខិតដាក់ទៅរដ្ឋាភិបាលដើម្បីអំពាវនាវជួយដោះស្រាយបញ្ហាមួយចំនួនជូនម្ចាស់ឆ្នោត ជាពិសេសលើករណីក្រុមហ៊ុនធី អាន ភីបង្ខាំងមនុស្សខុសច្បាប់ និងការចុះជួបផ្ទាល់ និងជួយធ្វើអន្តរាគមន៍អ្នកភូមិបុរីកីឡា និងបឹងកក់អំពីបញ្ហាដីធ្លី និងផ្ទះសំបែង ។(របាយការណ៍ខុមហ្វ្រែលសង្កេតសភា និងតំណាងរាស្ត្រឆ្នាំ២០១១-២០១២)

ជាក់ស្តែង កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៤[7] សមាជិកគណៈកម្មការទី១នៃរដ្ឋសភាចំនួន៤រូប ដឹកនាំដោយលោកជំទាវ **ឡោក ខេង** តំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាចុះប្រមូលព័ត៌មានបឋមលើវិវាទដីធ្លីរវាងក្រុមហ៊ុន**ខេ.ឌី.ស៊ី** (KDC)ជាមួយប្រជាពលរដ្ឋចំនួន៤៣គ្រួសារដែលទើបតវ៉ាថ្មីនៅភូមិឡពាង ឃុំឡពាង ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ លោកជំទាវបានអនុញ្ញាតឲ្យមានការជជែកដេញដោលគ្នារវាងអាជ្ញាធរ មន្ត្រីសិទ្ធិមនុស្ស និងតំណាងពលរដ្ឋទាំង៤៣គ្រួសារនៅក្នុងសាលាប្រជុំសាលាស្រុកកំពង់ត្រឡាច ។ ទោះបីតំណាងភាគីក្រុមហ៊ុនលោកស្រី **ជា ខេង** មិនទាន់អាចបញ្ជាក់បានថានឹងត្រូវដោះស្រាយយ៉ាងណាចំពោះពលរដ្ឋទាំង៤៣គ្រួសារនេះទេ ប៉ុន្តែសមាជិកគណៈកម្មការទី១នៃរដ្ឋសភាអះអាងថា ខ្លួននឹងជួយសម្របសម្រួលឲ្យមានការដោះស្រាយគ្រប់គ្រួសារ បន្ទាប់ពីស្វែងរកការពិត ។

លោកជំទាវ **កែ សុវណ្ណរតន៍** អ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ និងជាប្រធានគណៈកម្មការទី៨ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារីនៃរដ្ឋសភា និងលោកជំទាវ **ឡោក ខេង** សមាជិកគណៈកម្មការទី១សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹងអង្កេត និងទំនាក់ទំនងរដ្ឋសភា និងព្រឹទ្ធសភា និងជាតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា ចេញមកទទួលញត្តិពីប្រជាពលរដ្ឋកាលពីថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៤[8] ក្នុងឱកាសទិវាលំនៅឋានពិភពលោកលើកទី២៩ សហគមន៍រងគ្រោះដោយការបណ្តេញចេញបានប្រារព្ធឡើងនោះ បានប្រែក្លាយពីការអបអរសាទរទៅជាការទាមទារឲ្យមន្ត្រីពាក់ព័ន្ធក្នុងស្ថាប័នថ្នាក់ជាតិដោះស្រាយវិបត្តិអត់ផ្ទះសម្បែងដីធ្លីជូនពួកគាត់ បញ្ឈប់ការបណ្តេញចេញដោយបង្ខំ និងសុំឲ្យរដ្ឋាភិបាលធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង ។ អ្នកហែរក្បួនបានស្រែករង់ចាំជិតមួយម៉ោងនៅមុខមន្ទីររដ្ឋសភាទើបអ្នកតំណាងរាស្ត្រចេញមកទទួលញត្តិ ។លោកជំទាវ **ឡោក ខេង** បានថ្លែងទទួលស្គាល់ថាប្រជាពលរដ្ឋកំពុងជួបការលំបាកពិតប្រាកដ ។ លោកជំទាវថា នឹងរៀបចំយន្តការពិនិត្យតាមដានដោះស្រាយជូនប្រជាពលរដ្ឋទាំងអស់ដែលមាននៅក្នុងញត្តិនេះ៖ «*បើបងប្អូនជាប្រជាពលរដ្ឋឈឺចាប់នាងខ្ញុំជាតំណាងរាស្ត្រឈឺចាប់ជាងបងប្អូនទៅទៀត ។ អ្វីដែលបងបងប្អូនប្រជាពលរដ្ឋកំពុងតែជួបការលំបាក ទោះបីត្រូវច្បាប់ក្តី មិនត្រូវច្បាប់ក្តីយើងត្រូវពិនិត្យទៅតាមយន្តការទាំងអស់ដើម្បីដោះស្រាយ ។ សំណូមពរបងប្អូនទាំងអស់នៅថ្ងៃនេះ យើងនឹងយកទៅពិភាក្សានៅក្នុងគណៈកម្មការទី១ ហើយយើងតាមដានជំរុញនូវរាល់ការអនុវត្តទាំងអស់ ហើយយើងគាំទ្រចំពោះការអភិវឌ្ឍនៅនឹងកន្លែង*» ។

សមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិផងដែលភាគច្រើនជាស្ត្រី បានចេញមកទទួលញត្តិព្រមគ្នានៅមុខវិមានរដ្ឋសភា ហើយសន្យាដោះស្រាយបញ្ហានៅចំពោះមុខដូចអ្វីដែលក្រុមកម្មករកំពុងទាមទារនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៤[9] កម្មករជាច្រើនរយនាក់មកពីតាម

[7] ការផ្សាយរបស់វិទ្យុអាស៊ីសេរី (RFA) កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៤
[8] ការផ្សាយរបស់វិទ្យុអាស៊ីសេរី (RFA) កាលពីថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៤
[9] ការផ្សាយរបស់វិទ្យុអាស៊ីសេរី (RFA) កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៤

បណ្ដាខេត្ត និងរាជធានីភ្នំពេញ បានជួបជុំគ្នានៅទីលានប្រជាធិបតេយ្យ ដើម្បីទាមទារប្រាក់ឈ្នួលសមរម្យ ក្រោមការសម្របសម្រួលពីមេដឹកនាំសហជីពចំនួន៦ ហើយថែមទាំងផ្ដល់ឱកាសឲ្យមេដឹកនាំសហជីព ជួបពិគ្រោះយោបល់ក្នុងរឿងនេះបន្ថែមនៅព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ បន្ត ។

ថ្លែងក្រោយរំសាយក្បួននៅមុខវិមានរដ្ឋសភា កាលពីព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៤ លោក **ម៉ាច ស៊ីណា** ប្រធានសម្ព័ន្ធសហជីពចលនាកម្មករ ក្នុងចំណោមមេដឹកនាំសហជីព៥ផ្សេងទៀត និយាយថា «*យើងមិនដែលឃើញតំណាងគណបក្សទាំងពីរមកទទួលញត្តិពីកម្មករនិយោជិកទេ។ ប៉ុន្តែលើកនេះថ្មីសម្រាប់ក្រុមសហជីពដែលបានឃើញតំណាងគណបក្សទាំងពីរ ដែលមានអាសនៈនៅក្នុងរដ្ឋសភាចេញមកទទួលញត្តិ។ យើងរំពឹងថាពួកគាត់នឹងធ្វើការដោះស្រាយទៅនឹងបញ្ហាដែលលើកឡើងដោយសហជីពនេះឲ្យបាន ដែលហៅថាលទ្ធផលមួយដែលអាចទទួលយកបាន*» ។

តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ មណ្ឌលខេត្តបាត់ដំបង លោកជំទាវ **មូរ សុខហួរ** បានរៀបចំវេទិកាសាធារណៈតំណាងរាស្ត្រ ជួបជាមួយប្រជាពលរដ្ឋម្ចាស់ឆ្នោតមកពីស្រុកនានាប្រមាណជាង ២០០នាក់នៅទីស្នាក់ការតំណាងរាស្ត្រមណ្ឌលបាត់ដំបង នៅថ្ងៃទី២៨ តុលា ឆ្នាំ២០១៤[10] ។ វេទិកាសាធារណៈនេះជាលើកដំបូងហើយដែលបានរៀបចំដើម្បីប្រជាពលរដ្ឋនៅខេត្តបាត់ដំបង ក្នុងការផ្ដល់ឱកាសឲ្យម្ចាស់ឆ្នោតសម្ដែងមតិពីទុក្ខលំបាករបស់ខ្លួន ដែលបានជួបប្រទះនៅតាមមូលដ្ឋាននាពេលកន្លងមក ដើម្បីឲ្យតំណាងរាស្ត្រយកទៅដោះស្រាយបន្ត ។

លោកជំទាវ បានមានប្រសាសន៍ទៅកាន់ប្រជាពលរដ្ឋម្ចាស់ឆ្នោតនៅក្នុងវេទិកានោះថា «ប្រជាពលរដ្ឋ គឺជាម្ចាស់អំណាចដ៏សំខាន់ ដែលតំណាងរាស្ត្រ និងថ្នាក់ដឹកនាំចេញពីការបោះឆ្នោតទាំងអស់ត្រូវយកចិត្តទុកដាក់ទៅលើពួកគាត់» ។ លោកជំទាវបន្តថា បន្ទាប់ពីបញ្ចប់វេទិកានេះទៅ អ្នកស្រីនឹងនាំក្ដីកង្វល់របស់ប្រជាពលរដ្ឋដែលបានសម្ដែងមតិ នាំទៅឲ្យមន្ត្រីក្រុមប្រឹក្សាខេត្ត លើកជាប្រធានបទសំខាន់ដាក់ទៅក្នុងអង្គប្រជុំរបស់សាលាខេត្ត ដើម្បីដោះស្រាយបន្ត ។

គួរកត់សម្គាល់ថា ប្រជាពលរដ្ឋដែលចូលរួមក្នុងវេទិកា ភាគច្រើនលើកពីទុក្ខកង្វល់ពាក់ព័ន្ធនឹងការរំលោភដីធ្លីពីសំណាក់អាជ្ញាធរមានអំណាចមកលើប្រជាពលរដ្ឋ បញ្ហាសេវាសាធារណៈរបស់រដ្ឋមិនបានត្រឹមត្រូវ ដូចជាការធ្វើអត្តសញ្ញាណប័ណ្ណ និងការធ្វើផ្លូវថ្នល់ជាដើម ។ វេទិកាសាធារណៈតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះនឹងមានរៀបចំជារៀងរាល់ខែ ។

សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រីខាងលើ បានបង្ហាញឲ្យឃើញពីការផ្លាស់ប្ដូរឥរិយាបថក្នុងតួនាទីជាតំណាងរាស្ត្រ ដូចជា បានពាំនាំយកសំណូមពរ បញ្ហារបស់ប្រជាពលរដ្ឋយកមកពិភាក្សាដោះស្រាយជាមួយអ្នកពាក់ព័ន្ធ បើទោះបីជាពុំទាន់ចេញលទ្ធផលជាក់ស្ដែងនៅឡើយក៏ដោយ ។ ដោយឡែក អំណាច និងឥទ្ធិពលរបស់តំណាងរាស្ត្រស្ត្រីនៅមានកម្រិត ដោយសារពួកគាត់ស្ថិតក្រោមនៅក្រោមខ្សែបន្ទាត់គណបក្សនយោបាយ ។ ទោះបីជាយ៉ាងណាក៏ដោយសកម្មភាពរបស់ពួកគាត់បានលើកទឹក

[10] ការផ្សាយរបស់វិទ្យុអាស៊ីសេរី (RFA) កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៤

ចិត្តដល់ស្ត្រី ជនក្រីក្រ ជនរងគ្រោះក្នុងការតស៊ូដោយសន្តិវិធីដើម្បីដោះស្រាយបញ្ហា និងផ្តល់ជាគំរូដល់ស្ត្រីផ្សេងទៀត រួមទាំងស្ត្រីវ័យក្មេងអំពីភាពសកម្ម ភាពក្លាហានមោះមុត ការលះបង់ និងការតស៊ូនឹងបញ្ហាប្រឈមនានា ។

## ៤. ការបំពេញការសន្យារបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ឆ្នាំ២០០៩-២០១៣ ដែលត្រូវបានរដ្ឋសភាអនុម័តនាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ គឺជាផែនទីចង្អុលផ្លូវដែលត្រូវអនុវត្ត និងបន្តអនុវត្តសម្រាប់រយៈពេលខាងមុខ ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានបន្តអនុវត្តគោលនយោបាយយេនឌ័រ តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី២ ដោយ ផ្តោតជាសំខាន់ទៅលើវិស័យអាទិភាពទាំង៦ រួមមាន (១) ការអភិវឌ្ឍន៍សេដ្ឋកិច្ចដល់ស្ត្រី (២) ការបង្កើនការអប់រំ ដល់ស្ត្រី និងក្មេងស្រី (៣) ការការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី (៤) ការលើកកម្ពស់សុខភាពស្ត្រី និងក្មេង ស្រី (៥) ការបង្កើនចំនួនស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត (៦) ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីជាតិ ។ លើសពីនេះ ឯកសារគោលនយោបាយសំខាន់ៗជាច្រើនទៀត ដូចជា ផែនការសកម្មភាពអភិបាលកិច្ច សូចនាករតាមដានរួមរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ សុទ្ធតែបានលើកឡើងយ៉ាងច្បាស់ពីការយកចិត្តទុកដាក់លើការលើកកម្ពស់សមភាពយេនឌ័ររបស់រដ្ឋាភិបាល ។ ព្រមជាមួយនេះ កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ក៏បានផ្តោតជាសំខាន់ក្នុងការរៀបចំថវិកាជាតិ ដើម្បីឲ្យមានការឆ្លើយតប និងដោះស្រាយផលប្រយោជន៍របស់ស្ត្រី និងបុរស[11] ។

ថ្មីៗកន្លងទៅនេះ ក្រសួងកិច្ចការនារីបានធ្វើការបង្ហាញ និងផ្សព្វផ្សាយឯកសារ **នារីរតនៈទី៤**[12] គឺជាផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅកម្ពុជា រយៈពេល ៥ ឆ្នាំ (ឆ្នាំ២០១៤-២០១៨) ។ មូលដ្ឋានគ្រឹះនៃការរៀបចំផែនការយុទ្ធសាស្ត្រនេះបានផ្អែកលើលទ្ធផលនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្ររបស់នារីរតនៈទី៣ (២០០៨-២០១៣) និងឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ឆ្នាំ២០១៤ ។ នារីរតនៈទី៤ បានរួមចំណែកក្នុងការគាំទ្រកាបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជា កំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់ដីធ្លីផ្សាភ្ជាប់ជាមួយនឹងការអនុវត្តន៍គោលនយោបាយ និងផែនការជាតិសំខាន់ៗដូចជា គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ គោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នា ផែនការជាតិស្តីពីការទប់

[11] សុន្ទរកថា លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការនៃព្រះរាជាណាចក្រកម្ពុជាក្នុងឱកាសបើកសិក្ខាសាលាស្តីពី ការធ្វើឲ្យសម្រេចបាននូវគោលដៅទី៣នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ត្រឹមឆ្នាំ២០១៥ កាលពីខែកញ្ញា ឆ្នាំ២០១០

[12] ការផ្សព្វផ្សាយនារីរតនៈទី៤ របស់ក្រសួងកិច្ចការនារី កាលពីខែធ្នូ ឆ្នាំ២០១៤

ស្កាត់អំពើហិង្សាលើស្ត្រី ផែនការជាតិស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។ល។ និង។ល។

នារីរតនៈទី៤ ផ្តោតសំខាន់លើការពង្រឹង និងពង្រីកមុខងាររបស់ក្រសួងកិច្ចការនារី ពីរបៀបនៃការអនុវត្តការងារ ដើម្បីឈានទៅការអនុវត្តការងារតាមអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងឈានជាបណ្តើរៗពីភ្នាក់ងារអនុវត្តផ្ទាល់ឲ្យទៅជាអ្នកលើកកម្ពស់គណនេយ្យសង្គមសម្រាប់ស្ត្រី និងអ្នកផ្តល់សេវាពិគ្រោះយោបល់ផ្នែកគោលនយោបាយដល់ស្ថាប័នពាក់ព័ន្ធក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ។

## សមិទ្ធផលចម្បងៗ និងការប្រឈម

នៅក្នុងការអនុវត្តនារីរតនៈទី៣ (២០០៩-២០១៣)[13] រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធនានាទទួលបានជោគជ័យគួរជាទីកត់សម្គាល់ក្នុងការចូលរួមចំណែកលើកកម្ពស់គោលនយោបាយ ច្បាប់ និងកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យឆ្លើយតបនឹងយេនឌ័រ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី រួមទាំងការចូលរួមក្នុងការគ្រប់គ្រងបម្រែបម្រួលអាកាសធាតុ និងបរិស្ថាន ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី ការចូលរួមធ្វើឲ្យប្រសើរឡើងនូវសុខភាព និងអាហារូបត្ថម្ភសម្រាប់ស្ត្រី និងក្មេងស្រី ការទប់ស្កាត់ការរីករាលដាលជំងឺអេដស៍ ការលើកកម្ពស់ការចូលរួមរបស់កុមារី និងស្ត្រីក្នុងការអប់រំសិក្សា ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និងការបង្កើនការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចគ្រប់កម្រិត ។

### ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

កម្ពុជាទទួលបានសមិទ្ធផលគួរជាទីកត់សម្គាល់ ក្នុងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។ សន្ទស្សន៍វិសមភាពយេនឌ័រក្នុងឆ្នាំ២០១៣បានបង្ហាញថា ការចូលរួមរបស់ស្ត្រីក្នុងទីផ្សារការងារមាន៧៩,២០% ។ នៅក្នុងសន្ទស្សន៍គម្លាតយេនឌ័រសកលក្នុងឆ្នាំ២០១៣ទាក់ទងនឹងការចូលរួមក្នុងផ្នែកសេដ្ឋកិច្ច កម្ពុជាទទួលបានចំណាត់ថ្នាក់ខ្ពស់មធ្យមសម្រាប់ការចូលរួមរបស់ស្ត្រីក្នុងកម្លាំងពលកម្ម[14] ។ ការរីកលូតលាស់នៃវិស័យពាណិជ្ជកម្ម សេវាកម្ម ផលិតកម្ម កសិកម្ម សណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន បានផ្តល់ការងារប្រមាណ ៨៩%នៃការងារសរុបរបស់ស្ត្រី[15] ។ ឱកាសការងារមានទំហំ

[13] របាយការណ៍របស់ក្រសួងកិច្ចការនារី ស្តីពី «សមិទ្ធផលចម្បងៗ និងបញ្ហាប្រឈម» នៅក្នុងឯកសារនារីរតនៈទី៤ ទំព័រទី២

[14] វេទិកាពិភពលោក ស្តីពី សេដ្ឋកិច្ចក្នុងរង្វាស់គម្លាតយេនឌ័រ ឆ្នាំ២០១៤

[15] អង្កេតប្រជាសាស្ត្រចន្លោះជំរឿនកម្ពុជា ឆ្នាំ២០១៣ វិទ្យាសាស្ត្រជាតិស្ថិតិ

កាន់តែច្រើនសម្រាប់ស្ត្រី និងបុរស ចំណែកឯការងារដែលងាយរងគ្រោះក៏មានការថយចុះ ។ អាត្រានៃភាពក្រីក្រធ្លាក់ចុះពី ២៩,៩០% ក្នុងឆ្នាំ២០០៨ មកនៅត្រឹម ១៩,៨០% ក្នុងឆ្នាំ២០១១[16] ។

រាជរដ្ឋាភិបាលបានផ្តោតលើការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចដល់ស្ត្រី និងផ្តល់ការគាំទ្រដល់ស្ត្រីក្នុងការបង្កើនប្រាក់ចំណូលដល់គ្រួសារ រួមទាំងការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅក្នុងខេត្តចំនួន១៣ ក្នុងការផ្តល់នូវជំនាញវិជ្ជាជីវៈ និងសេវាអភិវឌ្ឍន៍អាជីវកម្មជូនស្ត្រី ។ ជាលទ្ធផល ស្ត្រីប្រមាណ ១៣ ១០២ នាក់ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ។ សមាគមសហគ្រិនស្ត្រីកម្ពុជា បានបង្កើតឡើងក្នុងឆ្នាំ២០១២ដែលមានសមាជិក១៥០នាក់ ក្នុងគោលបំណងជួយអភិវឌ្ឍមុខរបរស្ត្រី ព្រមទាំងពង្រឹងសំឡេងស្ត្រីសហគ្រិននៅក្នុងវិស័យឯកជន ។

ក្របខណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលផ្តោតលើការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រីក៏បានរៀបចំឡើងដើម្បីកៀរគរការចូលរួមពីបណ្តាដៃគូពាក់ព័ន្ធពីស្ថាប័នរដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ក្នុងការសម្រេចនូវយុទ្ធសាស្ត្របីសំខាន់ៗ គឺ *(១) ការពង្រឹងវិជ្ជាជីវៈដល់ស្ត្រីទៅតាមតម្រូវការទីផ្សារ (២) ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមសម្រាប់ស្ត្រី និង(៣) ការបង្កើនជីវភាពរស់នៅតាមជនបទ ជាពិសេសដល់ស្ត្រី។*

## ការអប់រំសម្រាប់ស្ត្រី និងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ

គម្លាតយេនឌ័រក្នុងវិស័យអប់រំបានកាត់បន្ថយគ្រប់កម្រិត តាមរយៈការបង្កើនចំនួនអាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រ ពិសេសស្ត្រី បង្កើនចំនួនគ្រឹះស្ថានអប់រំនៅមូលដ្ឋាន បង្កើនចំនួនអន្តេវាសិកដ្ឋានដែលផ្តល់សេវាសមរម្យ និងសុវត្ថិភាពសម្រាប់សិស្សស្រី ។

ចាប់តាំងពីឆ្នាំ២០០៨ យេនឌ័របានបន្តបញ្ជ្រាបទៅក្នុងគោលនយោបាយ កម្មវិធី និងផែនការក្នុងវិស័យអប់រំ យុវជន និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជាផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-២០១៣ ផែនការគោលស្តីពីការអភិវឌ្ឍន៍កម្មវិធីសិក្សាឆ្នាំ២០១០-២០១៤ ផែនការអភិវឌ្ឍន៍គ្រូបង្រៀនឆ្នាំ២០១០-២០១៤ ផែនការគោលសម្រាប់ការអភិវឌ្ឍន៍សមត្ថភាពក្នុងវិស័យអប់រំឆ្នាំ២០១១-២០១៥ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រឆ្នាំ២០១១-២០១៥ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ គោលនយោបាយស្តីពីសាលាកុមារមេត្រីសម្រាប់អប់រំមូលដ្ឋាន គោលនយោបាយស្តីពីគ្រូបង្រៀន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៤-២០១៨ និងយុទ្ធសាស្ត្រសមធម៌យេនឌ័រក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៤ ជាដើម ។

---

[16] បន្ទាត់អាត្រាភាពក្រីក្រថ្នាក់ជាតិថ្មីនេះ គឺជាការប៉ាន់ប្រមាណដ៏ទាបលើការចំណាយសម្រាប់ជីវភាពរស់នៅដោយផ្អែកលើការចំណាយសម្រាប់កាឡូរី ២ ២០០ និងការចំណាយតូចៗផ្សេងទៀតមិនមែនសម្រាប់អាហារ ។ បន្ទាត់ភាពក្រីក្រថ្មីរបស់ប្រទេសកម្ពុជា គឺ ៣ ៨៧២ រៀលក្នុងមួយថ្ងៃ (សម្រាប់មនុស្ស ម្នាក់)នៅឆ្នាំ២០០៩ អត្រានេះមានកម្រិតខ្ពស់ជាងនៅទីក្រុងភ្នំពេញ និងតំបន់ជុំវិញទីក្រុង និងទាបជាងសម្រាប់តំបន់ដាច់ស្រយាល (ក្រសួងផែនការឆ្នាំ២០១៣) ។

ច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រទាំងនេះ បាន និងកំពុងរួមចំណែកក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ និងបណ្តុះបណ្តាលតាមរយៈការផ្តល់បរិយាកាសល្អផ្នែករូបវន្ត ការបង្កើនកាលានុវត្តភាពក្នុងការទទួលបាននូវការអប់រំ និងបណ្តុះបណ្តាល ការកែប្រែឥរិយាបថសង្គមដែលរើសអើងលើស្ត្រី និងការផ្តល់បរិយាកាសអំណោយផលដល់ការចូលរួមរបស់ស្ត្រីនៅគ្រប់ផ្នែក និងកម្រិត ។ នៅកម្រិតមត្តេយ្យសិក្សា ការចូលរួមរបស់កុមារទាំងពីរភេទមានការកើនឡើងជាបន្តបន្ទាប់ ដែលបានរួមចំណែកក្នុងការបង្កើនភាពវៃឆ្លាត និងទំនុកចិត្តរបស់កុមារនៅពេលចូលរៀននៅថ្នាក់បឋមសិក្សា[17]។ នៅបឋមសិក្សា និងមធ្យមសិក្សា ឈ្មោះចូលរៀនសិស្សស្រីមានចំនួនប្រហាក់ប្រហែលគ្នានឹងសិស្សប្រុស[18]។ ក្នុងឆ្នាំ២០១២ កុមារីបានចុះឈ្មោះចូលរៀនច្រើនជាងកុមារា និងចំនួនសរុបច្រើនជាងកុមារានៅកម្រិតមធ្យមសិក្សាបឋមភូមិ[19]។ នៅឧត្តមសិក្សា សមាមាត្រនិស្សិតស្រីកំពុងមានការកើនឡើងជាបណ្តើរៗពី៣៣%ក្នុងឆ្នាំ២០០៨ ដល់ ៣៧,៦០%ក្នុងឆ្នាំ២០១១[20]។ ការចូលរួមរបស់ស្ត្រីនៅក្នុងការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក៏មានការកើនឡើងគួរឲ្យកត់សម្គាល់ផងដែរ ។

គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានអនុវត្តការងារតាមយុទ្ធសាស្ត្រពហុវិស័យលើការងារសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្នុងគោលបំណងថែរក្សាការងារវប្បធម៌ជាតិ ធានាដល់ការគោរពសីលធម៌សង្គម និងសុភមង្គលនៅក្នុងគ្រួសារ ដោយលើកកម្ពស់ស្ថានភាពតួនាទី និងសុខុមាលភាពស្ត្រីខ្មែរ ។ គ្រប់ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការអនុវត្តដើម្បីកាត់បន្ថយភាពអសីលធម៌សង្គម ឈានដល់ការបង្ក្រាបបទល្មើសរំលោភបំពានដល់សិទ្ធិស្ត្រី និងកុមារ អំពើហិង្សាគ្រប់រូបភាព ការជួញដូរមនុស្ស ការឆក់ប្លន់ និងការប្រព្រឹត្តគ្រឿងញៀន ។

## យេនឌ័រ និងសុខភាព

អត្រាមរណភាពមាតាមានការថយចុះច្រើនជាងពាក់កណ្តាល គឺពី ៤៧២ ក្នុងចំណោម ១០០ ០០០កំណើតរស់ក្នុងឆ្នាំ២០០៥ មកត្រឹម ២០៦ក្នុងចំណោម ១០០ ០០០កំណើតរស់ក្នុងឆ្នាំ២០១០[21]។ ជាមួយគ្នានេះដែរ ការទទួលបានការថែទាំសុខភាពមាតាក៏មានភាពប្រសើរឡើងជាលំដាប់ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ[22]។ និន្នាការវិជ្ជមានទាំងនេះបានបន្តដោយសារមានអន្តរាគមន៍ជាច្រើនរបស់ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ព្រមទាំងស្ថាប័ន និងដៃគូពាក់ព័ន្ធក្នុងការពង្រីកការផ្តល់សេវាថែទាំសុខភាពនៅតាមមណ្ឌលសុខភាព កម្មវិធីអប់រំ និងផ្សព្វផ្សាយដោយភ្នាក់ងារអប់រំសុខភាពភូមិ ។ អត្រាជំងឺក្រិន

[17] UIS online database UNESCO Institute for Statistic. Available online at: data.uis.unesco.org
[18] ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ២០០៨ ២០០៩ ២០១០ ២០១១
[19] ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ២០១២
[20] ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ២០០៨ ២០០៩ ២០១០ ២០១១
[21] អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១០
[22] Wang, Wenjuan (2013) Assessing Trends in Inequalities in Maternal and Child Health and Health Care in Cambodia. DHS Further analysis Report No. 86. Calverton, Maryland, USA: ICF International.

ចំពោះកុមារមានការថយចុះពី៥០%ក្នុងឆ្នាំ២០០០ មកត្រឹម ៤០%ក្នុងឆ្នាំ២០១០ ។ អត្រាស្គមស្គាំងថយចុះពី ១៧% ក្នុងឆ្នាំ២០០០ មកត្រឹម ១១% ក្នុងឆ្នាំ២០១០ ។ អត្រាកុមារមានជំងឺខ្វះទម្ងន់ថយចុះពី ៣៩% ក្នុងឆ្នាំ២០០០ មកត្រឹម ២៨% ក្នុងឆ្នាំ២០១០[23]។

ព័ត៌មានស្តីពី សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ គឺមានសារៈសំខាន់សម្រាប់ផ្តល់ដល់យុវវ័យឲ្យយល់ដឹងពីសិទ្ធិបន្តពូជ និងសិទ្ធិផ្លូវភេទរបស់ពួកគេ ។ ក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវកម្មវិធីសិក្សាដ៏ទូលំទូលាយមួយសម្រាប់យុវវ័យនៅថ្នាក់បឋម និងមធ្យមសិក្សា និងយុវវ័យនៅក្រៅសាលា ដោយរួមបញ្ចូលនូវព័ត៌មានស្តីពីសិទ្ធិសុខភាពបន្តពូជ និងសុខភាពផ្លូវភេទភ្ជាប់នឹងអាយុ យេនឌ័រ អំពើហិង្សាទាក់ទងនឹងយេនឌ័រ គ្រឿងញៀន ការអប់រំបំណិនជីវិត និងមេរោគអេដស៍ ជំងឺអេដស៍ ។

## យេនឌ័រ និងមេរោគអេដស៍

អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមបុរស និងស្ត្រីអាយុពី១៥ឆ្នាំ ទៅ ៤៩ឆ្នាំ បានថយចុះគួរឲ្យកត់សម្គាល់ពី ១,៧០%ក្នុងឆ្នាំ១៩៩៨ មកត្រឹមប្រមាណ ០,៧% ក្នុងឆ្នាំ២០១៤[24]។ ដោយសារមានការថយចុះនូវការឆ្លងថ្មីតាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការដែលមានគោលដៅច្បាស់លាស់ ជាពិសេសក្នុងចំណោមក្រុមដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ក្នុងការឆ្លងមេរោគអេដស៍ ការកើនឡើងអត្រាអ្នកធ្វើតេស្តឈាមរកមេរោគអេដស៍ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងភាពកាន់តែប្រសើរឡើងក្នុងការផ្តល់សេវាព័ត៌មាន និងទំនាក់ទំនងរបស់ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ។ កម្ពុជាសម្រេចបាននូវគោលដៅទាក់ទងនឹងលទ្ធភាពទទួលបានសេវាជាសកលសម្រាប់ព្យាបាលស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុសក្នុងអត្រាមួយខ្ពស់ គឺរហូតដល់ទៅ ៨៩,៥០% នៃក្រុមប្រជាជនដែលមានតម្រូវការ[25]។ ជាលទ្ធផលដែលកើតចេញពីសមិទ្ធផលនេះ ចំនួនអ្នកប៉ាន់ស្មានអ្នកស្លាប់ដោយសារជំងឺអេដស៍ និងការចម្លងមេរោគអេដស៍ពីម្តាយទៅកូនក៏មានការថយចុះគួរកត់សម្គាល់នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍លើកទី៣ ឆ្នាំ២០១១-២០១៥ រួមទាំងកម្មវិធីបណ្តុះបណ្តាល និងគោលការណ៍ណែនាំស្តីពី ការបញ្ជ្រាបយេនឌ័រទៅក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ។ ក្រសួងកិច្ចការនារីក៏បានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពី ស្ត្រី ក្មេងស្រី និងមេរោគជំងឺអេដស៍ ឆ្នាំ២០០៨-២០១២ និងកម្មវិធីបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ទៅក្នុងដំណើរការលើកកម្ពស់សមភាពយេនឌ័រ ។

---

[23] អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១០

[24] National Centre for HIV/AIDS, Dermatology and STIs, (2011). HIV Estimates and Projections of HIV/AIDS in Cambodia 2011-2015: Report of a Census Workshop, Phnom Penh: Ministry of Health Surveillance Unit, 2011.

[25] របាយការណ៍វឌ្ឍនភាព ឆ្នាំ២០១២របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍

## អំពើហិង្សាលើស្ត្រី និងក្មេងស្រី

តាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០០៥បង្ហាញថា ស្ត្រីដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តពីដៃគូរបស់ខ្លួន មានការថយចុះពី២៥%ក្នុងឆ្នាំ២០០០ មកត្រឹម ២២%ក្នុងឆ្នាំ២០០៥[26] ។ តាមទិន្នន័យឃុំ សង្កាត់ ចំនួនគ្រួសារ[27]ដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលស្វែងរកជំនួយពីអាជ្ញាធរមូលដ្ឋាន បានបង្ហាញថា ចំនួនគ្រួសារដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារបានថយចុះពី ១,៦៣%ក្នុងឆ្នាំ២០០៦ មកត្រឹម ០,៨៨%ក្នុងឆ្នាំ២០១០[28] ។ សរុបមកការប្រៀបធៀបការអង្កេតតាមដានដែលធ្វើឡើងដោយក្រសួងកិច្ចការនារី ឆ្នាំ២០០៥ និងឆ្នាំ២០០៩ បានបង្ហាញថា ប្រជាជនភាគតិចបានទទួលស្គាល់អំពើហិង្សាជាអំពើដែលអាចទទួលយកបាន និងប្រជាជនភាគច្រើនបានទទួលស្គាល់ថា ការប្រព្រឹត្តអំពើហិង្សាជាការល្មើសច្បាប់[29] ។

តាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០១០ បានបង្ហាញថា ស្ត្រីដែលយល់ស្របថាមានហេតុផលយ៉ាងតិចមួយដែលបុរសអាចវាយប្រពន្ធរបស់គាត់បានមានការថយចុះពី៥៥% ក្នុងឆ្នាំ ២០០៥ មកត្រឹម ៤៥,៧០% ក្នុងឆ្នាំ២០១០[30] ។ ក្របខណ្ឌគោលនយោបាយក្នុងការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រីកាន់តែមានភាពប្រសើរឡើងក្នុងរយៈពេលកន្លងមក ។ ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៤-២០១៨ បានរៀបចំឡើងដោយគ្របដណ្តប់លើវិស័យជាយុទ្ធសាស្ត្រចំនួនប្រាំ រួមមាន *(១) កិច្ចការពារបឋម (២) កិច្ចការពារពហុវិស័យ និងសេវាផ្នែកច្បាប់ (៣) ច្បាប់និងគោលនយោបាយ (៤)ការអភិវឌ្ឍន៍សមត្ថភាព និង(៥) ការត្រួតពិនិត្យ និងវាយតម្លៃ ។*

នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដែលនៅក្នុងចំណោមវិធានការសំខាន់ៗ មានចំណុចដែលពាក់ព័ន្ធនឹងគ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានការជួញដូរស្ត្រី និងកុមារ ។

ការយល់ដឹងពីភាពងាយរងគ្រោះរបស់ស្ត្រី និងកុមារីពីអំពើហិង្សា ឬបញ្ហាប្រឈមនានា និងការទទួលបាននូវកិច្ចការពារ និងសេវាសង្គមមានការកើនឡើងជាងមុន ។ កន្លងមក ការអង្កេតស្រាវជ្រាវជាច្រើនបានធ្វើឡើង និងបានជួយបង្កើនចំណេះដឹងពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅកម្ពុជា ។ ការយកចិត្តទុកដាក់បានបង្កើនតាមរយៈការផ្តល់នូវសេវាសង្គមពហុវិស័យ ក៏ដូចជាការគាំទ្រផ្នែកច្បាប់ ដើម្បីជួយដល់ស្ត្រី និងកុមារដែលជាជនរងគ្រោះដោយអំពើហិង្សា ។

---

[26] អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥

[27] The reports to the CDB are of families not individuals and therefore not disaggregated by type of violence, perpetrator or victim

[28] CDB Online. 2013. http://db.ncdd.gov.kh/cdbonline/home/index.castle (accessed November, December 2013).

[29] អង្កេតតាមដានអំពើហិង្សាលើស្ត្រី ឆ្នាំ២០០៩ ក្រសួងកិច្ចការនារី

[30] អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥

## ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច ក្នុងវិស័យសាធារណៈ និងនយោបាយ

ដើម្បីលើកកម្ពស់សមភាពយេនឌ័រ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការជាក់លាក់ជាច្រើនក្នុងការបញ្ជ្រាបយេនឌ័រ និងបង្កើនតួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេច រួមទាំងការបញ្ចូលទៅក្នុងច្បាប់ ក្របខណ្ឌគតិ យុត្តិ គោលនយោបាយ លិខិតបទដ្ឋាន និងកម្មវិធីផ្សេងៗ ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ បាននាំមកនូវការកើនឡើងជាបណ្តើរៗនូវសមាមាត្រស្ត្រីជាអ្នកដឹកនាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ឧបសគ្គនានាដែលរារាំងដល់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចត្រូវបានកំណត់ និងចងក្រងដោយអ្នកពាក់ព័ន្ធ ដើម្បីស្វែងរកដំណោះស្រាយរួមគ្នា ។

ក្នុងឆ្នាំ២០១២ សមាជិកព្រឹទ្ធសភាជាស្ត្រីទទួលបានអាសនៈ ១៤,៧៥% និងតំណាងស្ត្រីនៅក្នុងស្ថាប័នរដ្ឋសភាបានកើនឡើងច្រើនជាងបីដងក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ[31]។ ចំនួនស្ត្រីក្នុងមុខតំណែងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមានការកើនឡើងក្នុងឆ្នាំ២០១៣[32] ធៀបនឹងអណត្តិមុនៗ ។ ចំណែកឯសមាមាត្រស្ត្រីក្នុងស្ថាប័នតុលាការក៏មានការកើនឡើងផងដែរចាប់ពីឆ្នាំ២០០៨មក[33] ។ អភិបាលរងជាស្ត្រីនៃគណៈអភិបាលរាជធានី ខេត្ត កើនឡើង២០% ដែលលើសពីការរំពឹងទុកក្នុងគោលដៅទី៣នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ ស្ត្រីជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត មានការកើនឡើងពី១០%ក្នុងឆ្នាំ២០០៩ ដល់ ១៣,២៣% ក្នុងឆ្នាំ២០១៤ ។ ចំណែកឯស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌមានការកើនឡើងពី១២,២៣% ក្នុងឆ្នាំ២០០៩ ដល់ ១៣,៨៥% ក្នុងឆ្នាំ២០១៤ ។ អត្រាស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់កើនឡើងពី ១៤,៦៤% ក្នុងឆ្នាំ២០០៧ ដល់ ១៧,៧៨% ក្នុងឆ្នាំ២០១២[34] ។

សមាមាត្រស្ត្រីជាមន្ត្រីរាជការកើនឡើងពី៣២%ក្នុងឆ្នាំ២០០៧ ដល់ ៣៧%ក្នុងឆ្នាំ២០១៣[35]។ ក្រសួង ស្ថាប័នចំនួន២០ក្នុងចំណោមក្រសួង ស្ថាប័នទាំង២៧បានរាយការណ៍អំពីការកើនឡើងនូវចំនួនមន្ត្រីរាជការជាស្ត្រីពី ០,២៧% ក្នុងឆ្នាំ២០០៨ ដល់ ៧,៩០% ក្នុងឆ្នាំ២០១៣ ។ បន្ថែមពីនេះ ក៏មានព្រះរាជក្រឹត្យស្តីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការជាស្ត្រីដល់អាយុ ៦០ឆ្នាំ តាមការស្ម័គ្រចិត្ត ។

## ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងវិស័យពាក់ព័ន្ធ

ច្បាប់ និងគោលនយោបាយជាច្រើនបានអនុម័ត និងដាក់ចេញក្នុងការការពារសិទ្ធិរបស់ស្ត្រីមានដូចជា ក្រមព្រហ្មក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជាធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាដើម ។

---

[31] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប)

[32] ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

[33] តារាងស្ថិតិមន្ត្រីរាជការស៊ីវិល ឆ្នាំ២០១៣ ក្រសួងមុខងារសាធារណៈ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤

[34] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) ឆ្នាំ២០០៧ និងឆ្នាំ២០១២

[35] តារាងស្ថិតិមន្ត្រីរាជការស៊ីវិល ឆ្នាំ២០១៣ ក្រសួងមុខងារសាធារណៈ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ បានបញ្ចូលសូចនាករទាក់ទងនឹងសមភាពយេនឌ័រ និងជំរុញបន្ថែមទៀតដល់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការបញ្ជ្រាបយេនឌ័រនៅតាមវិស័យ ។

យេនឌ័របានបញ្ជ្រាបក្នុងកម្មវិធីកំណែទម្រង់ជាតិសំខាន់ៗ ដូចជា កំណែទម្រង់រដ្ឋបាលសាធារណ: កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ: និងនៅក្នុងកម្មវិធីជាតិ១០ឆ្នាំសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្ត៣ឆ្នាំដំបូង ។

ការរីកចម្រើនគួរជាទីកត់សម្គាល់ ក្នុងការពង្រឹងយន្តការក្នុងការបញ្ជ្រាបយេនឌ័រដែលរួមបញ្ចូលទាំងក្រុមការងារបច្ចេកទេសយេនឌ័រដែលជាផ្នែកមួយរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ និងដំណើរការរបស់ក្រុមការងារយេនឌ័រតាមក្រសួងស្ថាប័នពាក់ព័ន្ធ ។ ស្ទើរគ្រប់ក្រសួង ស្ថាប័នបានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ ។ នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅថ្នាក់រាជធានី ក្រុង ស្រុក ខណ្ឌ បានបង្កើត និងកំពុងដំណើរការ ។ គណៈកម្មាធិការនេះកំពុងដើរតួនាទីក្នុងការផ្តល់យោបល់ និងលើកជាអនុសាសន៍ជូនដល់ក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី និងកុមារ នៅក្នុងដែនសមត្ថកិច្ច មុខងារ និងសិទ្ធិអំណាចរបស់ខ្លួន ។

យន្តការទាំងនេះនៅពុំទាន់មានប្រសិទ្ធភាពនៅឡើយ ដោយខ្វះនូវកិច្ចសហការជាមួយស្ថាប័នដទៃទៀត និងអង្គការសង្គមស៊ីវិល ។ ចំណែកថវិកាក៏នៅមានតិចតួចសម្រាប់ការអនុវត្តសកម្មភាព ។ ជាក់ស្តែង ថវិកា១០០លានរៀល នៅឆ្នាំ២០១១ និង២០០លានរៀល នៅឆ្នាំ២០១៣ដែលទីស្តីការគណៈរដ្ឋមន្ត្រីទំលាក់ឲ្យគណៈមេធាវីដើម្បីជាជំនួយសេវាផ្នែកច្បាប់ដល់ស្ត្រី ក៏មិនអាចប្រើប្រាស់បានដោយសារមានភាពស្មុគស្មាញក្នុងការដកថវិកាមកប្រើប្រាស់ និងដោយសារថវិកានេះមិនបានទំលាក់ផ្ទាល់ឲ្យក្រសួងកិច្ចការនារី[36] ។

***ទន្ទឹមនឹងភាពរីកចម្រើនគួរកត់សម្គាល់ ក៏នៅមានបញ្ហាប្រឈមជាច្រើនក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅប្រទេសកម្ពុជា ។ ខាងក្រោមនេះ គឺជាបញ្ហាគន្លឹះមួយចំនួនក្នុងចំណោមបញ្ហាជាច្រើនដែលស្ត្រីបានប្រឈម ៖***

- ប្រាក់ឈ្នួលរបស់ស្ត្រីនៅមានកម្រិតទាបនៅឡើយ ហើយការងាររបស់ពួកគេនៅមិនទៀងទាត់ ។ ជាក់ស្តែង មានស្ត្រីប្រមាណ៧០% និងបុរសចំនួន៥៩%ដែលត្រូវបានជ្រើសរើសឲ្យបម្រើការងារ និងកំពុងបម្រើការងារមិនទៀងទាត់[37] ។ បន្ថែមលើនេះទៀត ស្ថានភាពសេដ្ឋកិច្ចមិនទៀងទាត់របស់ស្ត្រីជារឿយៗនាំឲ្យមានការធ្វើចំណាកស្រុក និង/ឬការធ្វើអាជីវកម្មផ្លូវភេទ ។

[36] របាយការណ៍របស់ក្រុមអង្គការសង្គមស៊ីវិលពេលជួបប្រជុំជាមួយប្រធានគណៈកម្មការទី៨ និងសមាជិកនៃរដ្ឋសភា នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៤

[37] វិទ្យាស្ថានស្ថិតិជាតិ ក្រសួងផែនការ ឆ្នាំ២០១២ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។

■ ខណៈដែលឱកាសការងារនៅក្នុងស្រុក និងវិស័យសហគ្រាសខ្នាតតូច និងមធ្យមមានការកើនឡើង ស្ត្រីកាន់តែច្រើនកំពុងចំណាកស្រុកពីជនបទមកទីក្រុង និងទៅក្រៅប្រទេស ដើម្បីស្វែងរកការងារ ។ ជាទូទៅ ពួកគាត់ជួបហានិភ័យច្រើនជាងបុរស រួមទាំងអំពើហិង្សាលើរាងកាយ ។

■ នៅមានវិសមភាពយេនឌ័រនៅឡើយនៅមធ្យមសិក្សាទុតិយភូមិ និងកម្រិតឧត្តមសិក្សា ។ ជាក់ស្តែង និស្សិតស្រីរៀននៅសាកលវិទ្យាល័យមានចំនួនតែ ៣៧,៥០%ប៉ុណ្ណោះ[38] ។

■ កិច្ចគាំពារដល់កុមារនៅមានកម្រិត ជាពិសេសសម្រាប់កុមារី ទាក់ទងនឹងការធ្វើដំណើរទៅមកដោយសុវត្ថិភាព និងសុខភាពអនាម័យ ។

■ បញ្ហាមួយចំនួននៅតែកើតមាន គឺការខ្វះខាតអ្នកផ្តល់សេវាដែលមានជំនាញនៅតំបន់ដាច់ស្រយាល ការខ្វះខាតឱសថ និសម្ភារៈបរិក្ខាទំនើបនៅក្នុងមូលដ្ឋានសុខាភិបាល និងការយល់ដឹង និងឥរិយាបថរបស់ស្ត្រីក្នុងការស្វែងរកព័ត៌មាន និងសេវាព្យាបាលមានកម្រិតទាប ដោយសារតែកត្តាសង្គមវប្បធម៌ និងសេដ្ឋកិច្ច ។

■ គោលនយោបាយ និងគោលការណ៍ណែនាំគ្លីនិកសម្រាប់ឆ្លើយតបនឹងអំពើហិង្សាដែលកើតមានដោយសារដៃគូរួមភេទ និងអំពើហិង្សាផ្លូវភេទកំពុងរៀបចំ ប៉ុន្តែបច្ចុប្បន្នពុំទាន់មានការយកចិត្តទុកដាក់លើការបង្ការ ការចម្លងមេរោគអេដស៍ទៅលើស្ត្រី ក្នុងករណីដែលមានការបំពានផ្លូវភេទ និងក្នុងចំណោមស្ត្រីដែលប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍។ សេវាជំនួយផ្លូវច្បាប់សម្រាប់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកដែលប្រឈមមុខខ្ពស់នឹងមេរោគអេដស៍នៅមានកម្រិត ។

■ ស្ត្រី និងក្មេងស្រីមួយចំនួនទទួលរងគ្រោះខ្លាំងនូវអំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងការរំលោភសេពសន្ថវៈ ហើយក៏ជាហេតុនាំឲ្យឆ្លងមេរោគអេដស៍ផងដែរ ។

■ ក្រុមគោលដៅមួយចំនួនងាយរងគ្រោះក្នុងការឆ្លង និងចម្លងមេរោគអេដស៍ ដូចជា ស្ត្រីបំរើការតាមកន្លែងកំសាន្ត ស្ត្រីប្រើប្រាស់ ឬចាក់គ្រឿងញៀន និងស្ត្រីជាប់ពន្ធនាគារ ក្រុមស្រឡាញ់ភេទដូចគ្នា និងក្រុមយុវវ័យ ។ កង្វះការយល់ដឹងទូលំទូលាយស្តីពីមេរោគអេដស៍ ការប្រព្រឹត្តរួមភេទប្រកបដោយគ្រោះថ្នាក់ ការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន រួមជាមួយនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានបង្កើនគ្រោះថ្នាក់នៃការចម្លងមេរោគក្នុងចំណោមក្រុមគោលដៅទាំងនោះ ។

■ ទិន្នន័យដែលផ្តល់ដោយជនរងគ្រោះទាក់ទងនឹងអំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទនៅមានកម្រិត ប៉ុន្តែរបាយការណ៍អំពីអំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទទាំងនៅក្នុងគ្រួសារ និងនៅកន្លែងផ្សេងទៀត គឺមានការកើនឡើងច្រើន ។

[38] ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ឆ្នាំ២០១១

■ ទោះបីក្របខណ្ឌច្បាប់កាន់តែមានភាពប្រសើរ ប៉ុន្តែមធ្យោបាយរបស់អាជ្ញាធរពាក់ព័ន្ធ រួមទាំងជំនាញ និងសម្ភារ:ស៊ើបអង្កេត និងគោលការណ៍ណែនាំក្នុងការអនុវត្តន៍ច្បាប់នៅមានកម្រិត ។

■ សេវាសង្គមកិច្ច និងផ្លូវច្បាប់សម្រាប់ជនរងគ្រោះច្រើនមាននៅតែទីប្រជុំជន និងមិនទាន់បាន ផ្តល់ជាលក្ខណ:ទូលំទូលាយ និងជាប្រព័ន្ធនៅឡើយ ហើយការផ្តល់សេវា និងការទទួលបានសេវាក៏នៅមានកម្រិតផងដែរ ។

■ មានការលំបាកខ្លះៗចំពោះស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងការទទួលបាននូវសេវា និងយុត្តិធម៌ ខណ:ពេលដែលជនល្មើសមួយចំនួនធំមិនប្រឈមនឹងការផ្តន្ទាទោសចំពោះបទល្មើសរបស់ពួកគេ ។

■ ចំនួនស្ត្រីដែលមានតួនាទីធ្វើសេចក្តីសម្រេចនៅមានកម្រិតក្នុងវិស័យនយោបាយ សាធារណ: និងតុលាការ ។

■ ការរើសអើងចំពោះស្ត្រីនៅបន្តកើតមាន និងជាឧបសគ្គដល់ការទទួលបានការតែងតាំងក្នុងមុខតំណែងនានា ។

■ មិនទាន់មានវិធានការវិជ្ជមានបណ្តោះអាសន្នសមស្របនៅឡើយ ដើម្បីពន្លឿនការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណ: និងនយោបាយ ។

■ ការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធក្នុងការបញ្ជ្រាបយេនឌ័រតាមវិស័យនៅមានកម្រិត ។

■ ទំនាក់ទំនងរវាងនាយកដ្ឋានជំនាញរបស់ក្រសួងកិច្ចការនារីជាមួយក្រុមការងារយេនឌ័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងៗទៀតនៅមានកម្រិត ។

■ ថវិកាសម្រាប់អនុវត្តការបញ្ជ្រាបយេនឌ័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ។

■ គោលនយោបាយ និងកម្មវិធីយេនឌ័រតាមក្រសួង ស្ថាប័នពុំសូវមានការត្រួតពិនិត្យ តាមដានវាយតម្លៃទៅតាមតម្រូវការបញ្ជ្រាបយេនឌ័រជាក់ស្តែង ។

■ នៅក្នុងគោលនយោបាយគ្រប់វិស័យ ក៏ដូចជាគោលនយោបាយ និងកម្មវិធីស្តីពីសមភាពយេនឌ័រនៅមិនទាន់បានលើកឡើងពីតម្រូវការឲ្យស៊ីជម្រៅរបស់ជនដែលងាយរងគ្រោះជាស្ត្រី និងក្មេងស្រីនៅឡើយ ។

## ៥. តំណែងសមាជិកសភាស្ត្រី

មានពីរករណីនៃសមាជិកសភាស្ត្រី គឺ **លោកជំទាវ ឃួន សុដារី** ត្រូវបានដកចេញពីតំណែង និង **លោកជំទាវ មួរ សុខហួរ** មិនបោះឆ្នោតគាំទ្រធ្វើជាប្រធានគណ:កម្មការនៃរដ្ឋសភា ។

សមាជិកសភាកម្ពុជាបានដកតំណែងរបស់ស្ត្រីជាអនុប្រធានទី២ឲ្យទៅបុរសវិញ ដែលជាផ្លែផ្កានៃកិច្ចព្រមព្រៀង[39]បញ្ចប់ជំលោះនយោបាយរវាងបុរស និងបុរសមកពីគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា ខណៈដែលតំណាងរាស្ត្រស្ត្រីមានតែ ២៥នាក់ ហើយតំណាងរាស្ត្របុរសមានដល់ ៩៨ នាក់ ។ ការជ្រើសតាំង**ឯកឧត្តម ខួន ញឹល** ជាអនុប្រធានទី២ នៃរដ្ឋសភា ជំនួស**លោកជំទាវ ឃួន សុដារី** គឺជាការបន្ថយតួនាទីដ៏សំខាន់របស់ស្ត្រីនៅក្នុងរដ្ឋសភា ។

រដ្ឋសភាកម្ពុជាមិនមាននីតិវិធីណាមួយក្នុងការដកតំណែងអ្នកដឹកនាំរបស់ខ្លួនទេ ប៉ុន្តែការដកតំណែងណាមួយ ឬ/និងសមាជិកសភាណាមួយត្រូវគោរពតាមការសម្រេចចិត្តរបស់គណបក្ស ឬប្រធានគណបក្សនយោបាយ ។ ការមិនមាននីតិវិធីនេះ បានធ្វើឲ្យប៉ះពាល់ដល់តួនាទីរបស់ស្ត្រីមុនគេ ។ យោងលើស្មារតីលើកស្ទួយដល់ការចូលរួមរបស់ស្ត្រីនៅថ្នាក់សម្រេចចិត្ត និងផ្អែកលើគោលគំនិតនៃយេនឌ័រ រដ្ឋសភាមិនត្រូវដកតំណែងលោកជំទាវ **ឃួន សុដារី** ចេញពីអនុប្រធានទី២ជាដាច់ខាត ដោយសារតែចំនួនស្ត្រីមានតែ១នាក់គត់ក្នុងចំណោម៣នាក់ (២នាក់ ជាបុរស និង១នាក់ជាស្ត្រី)ជាថ្នាក់ដឹកនាំកំពូល ។ បន្ថែមលើនេះទៀត រដ្ឋសភាគួរតែគោរពលើគោលការណ៍បង្កើនសមាមាត្រស្ត្រីតាមរយៈការរក្សាការពារចំនួនស្ត្រី ឬ/និងតំណែងរបស់ស្ត្រី និងផ្តល់ឱកាសដល់ស្ត្រីជំនួសបុរស ឬស្ត្រីជាប់ឆ្នោតដែលបានលាលែង ឬដកចេញពីតំណែង ។ នេះមានន័យថា បើករណីមានស្ត្រីជាប់ឆ្នាតណាមួយត្រូវបានលាលែង ឬដកចេញពីតំណែង គួរតែមានស្ត្រីផ្សេងមកជំនួស ផ្ទុយមកវិញ បើករណីបុរសត្រូវបានលាលែង ឬដកចេញពីតំណែងគួរតែយកស្ត្រីមកជំនួសផងដែរ ។

លោកជំទាវ **ឃួន សុដារី** ជាប់ឆ្នោតជាតំណាងរាស្ត្ររហូតមកដល់បច្ចុប្បន្នចំនួន៤អាណត្តិ ។ លោកជំទាវមានបទពិសោធការងារសំខាន់ៗមុនជាប់ឆ្នោតជាតំណាងរាស្ត្រ ដូចជា ធ្លាប់ជាសមាជិកគណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា ជាអគ្គនិពន្ធនាយកសារព័ត៌មានប្រជាជន និងជាអ្នកដឹកនាំថ្នាក់កំពូលសម្រាប់នីតិកាលទី៤នៃរដ្ឋសភា ដែលមានតួនាទីជាអនុប្រធានទី២ ។ ជាមួយគ្នាដែរ លោកជំទាវក៏ធ្លាប់បានចូលរួមពិភាក្សាក្នុងសិក្ខាសាលាស្តីពី «ការសម្រេចឲ្យបាននូវគោលដៅទី៣នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ត្រឹមឆ្នាំ២០១៥» កាលពីខែកញ្ញា ឆ្នាំ២០១០ ដែលរៀបចំដោយលេខាធិការដ្ឋានសម្របសម្រួលបច្ចេកទេសនៃសភាកម្ពុជា សហការជាមួយក្រសួងកិច្ចការនារី និងសហភាពអន្តរសភា (IPU) ។ គោលដៅទី៣នេះ គឺផ្តោតលើ «ការលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី»ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាកំណត់ចំណុចដៅរួមចំនួន៤ និងសូចនាករចំនួន២០ រួមមានការកាត់បន្ថយគម្លាតយេនឌ័រនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា លុបបំបាត់គម្លាតយេនឌ័រសម្រាប់ការងារមាន

[39] លទ្ធផលនៃកិច្ចព្រមព្រៀងនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ នៃថ្នាក់ដឹកនាំកំពូលគណបក្សជាប់ឆ្នោតទាំងពីរ តំណែងដឹកនាំកំពូលរួមមានប្រធានសភា និងអនុប្រធានទី២នៃអាណត្តិទី៥នឹងត្រូវគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា ។ ចំណែកឯអនុប្រធានទី១នៃរដ្ឋសភាគ្រប់គ្រងដោយគណបក្សសង្គ្រោះជាតិ

បៀវត្សរ៍នៅគ្រប់វិស័យសេដ្ឋកិច្ច លុបបំបាត់គម្លាតយេនឌ័រក្នុងស្ថាប័នសាធារណៈ និងកាត់បន្ថយរាល់ទម្រង់នៃអំពើហិង្សាចំពោះស្ត្រី និងកុមារ[40] ។

ករណីផ្សេងទៀត **លោកជំទាវ មួរ សុខហួរ** ត្រូវបានឃុំខ្លួនដោយសារតែគាត់បានព្យាយាមការពារសេរីភាពនៃការជួបប្រជុំគ្នា និងត្រូវបានសមាជិកសភានៃគណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា)បោះឆ្នោតទំលាក់(មិនគាំទ្រ)ធ្វើជាប្រធានគណៈកម្មការទី៨ទេ ដែលជាការបាត់បង់ធនធានដ៏មានសក្តានុពល ធ្លាប់មានបទពិសោធយ៉ាងសន្ធឹកសន្ធាប់ទាក់ទងនឹងការលើកស្ទួយស្ត្រី និងយេនឌ័រចូលរួមលើគ្រប់វិស័យ និងជាស្ត្រីដ៏ឆ្នើមមួយរូបនៅលើឆាកជាតិ និងអន្តរជាតិ ខណៈដែលសមាជិកសភាបោះឆ្នោតឲ្យអ្នកផ្សេងដែលមានការយល់ដឹង និងបទពិសោធបន្តិចបន្តួចអំពីយេនឌ័រ និងកិច្ចការស្ត្រី និងកុមារ ។ *មានមូលហេតុ***ចំបងបី***ដែលខុមហ្វ្រែលរកឃើញ ៖* **មូលហេតុទី១** លោកជំទាវធ្លាប់មានជំលោះយ៉ាងខ្លាំងក្លាជាមួយសម្តេចនាយករដ្ឋមន្ត្រី**ហ៊ុន សែន** កាលពីខែមេសា ឆ្នាំ២០០៩ ដោយលោកជំទាវប្រកាសថានឹងប្តឹងលោកនាយករដ្ឋមន្ត្រី**ហ៊ុន សែន**ពីបទប្រើប្រាស់ភាសាប្រមាថមើលងាយលោកជំទាវ ។ ជាការឆ្លើយតបលោកនាយករដ្ឋមន្ត្រី**ហ៊ុន សែន**បានធ្វើការចោទប្រកាន់ប្រឆាំងនៃបទបរិហាកេរ្តិ៍ប្រឆាំងនឹងលោកជំទាវដោយបានបញ្ជាក់ថា លោកជាជនរងគ្រោះដោយសារតែគាត់មិនបាននិយាយសំដៅទៅលោកជំទាវ **មួរ សុខហួរ** បន្ទាប់មកលោកជំទាវត្រូវបានសភាបោះឆ្នោតដកអភ័យឯកសិទ្ធិ ។ ករណីនេះ មានការប្តឹងគ្នាទៅវិញទៅមក ប៉ុន្តែតុលាការបានច្រានចោលបណ្តឹងរបស់លោកជំទាវ ខណៈដែលបណ្តឹងប្រឆាំងនឹងលោកជំទាវដោយលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន**ត្រូវបានអនុញ្ញាតហើយនៅតែបន្តរហូតដល់ឆ្នាំ២០១០ទើបត្រូវបានបញ្ចប់[41] ។ ដូច្នេះ ដោយសារលោកជំទាវធ្លាប់មានជំលោះបែបនេះ ព្រមទាំងមានការនិយាយរិះគន់បញ្ហានានា ដែលជាហេតុធ្វើឲ្យសមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជាមិនហ៊ានបោះឆ្នោតគាំទ្រ ។ **មូលហេតុទី២** ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ លោកជំទាវ **មួរ សុខហួរ**បានដឹកនាំយុទ្ធនាការដើម្បីលើកការហាមប្រាមនៅទីលានប្រជាធិបតេយ្យ និងការពង្រឹងសេរីភាពនៃការជួបប្រជុំគ្នា ។ **មូលហេតុទី៣** អាចគណបក្សកាន់អំណាច និងរដ្ឋាភិបាលព្រួយបារម្ភអំពីសកម្មភាព និងឥទ្ធិពលរបស់លោកជំទាវនៅក្នុងរដ្ឋសភា រួមផ្សំនឹងការខ្វះចន្លោះ និងភាពទន់ខ្សោយរបស់គណបក្សសង្គ្រោះជាតិក្នុងការជំរុញឲ្យមានការគាំទ្រលោកជំទាវបានជាប់ជាប្រធានគណៈកម្មការទី៨ ។

លោកជំទាវ **មួរ សុខហួរ** មានបទពិសោធយ៉ាងលើសលុប និងធ្វើការតស៊ូមតិយ៉ាងសកម្មបំផុតអំពីកិច្ចការស្ត្រី និងជាស្ត្រីដ៏ឆ្នើមនៅលើឆាកជាតិ និងឆាកអន្តរជាតិ ។ លោកជំទាវមានប្រវត្តិ និងបទពិសោធ

[40] សុន្ទរកថា លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការនៃព្រះរាជាណាចក្រកម្ពុជាក្នុងឱកាសបើកសិក្ខាសាលាស្តីពី ការធ្វើឲ្យសម្រេចបាននូវគោលដៅទី៣នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ត្រឹមឆ្នាំ២០១៥ កាលពីខែកញ្ញា ឆ្នាំ២០១០

[41] COMFREL-2010 Report on Cambodian Democracy, Elections and Reform

ទាក់ទងនឹងការងារលើកស្ទួយស្ត្រី ដូចជា ជារដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជនក្នុងឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៤ ជាអគ្គលេខាធិការគណបក្សសមរង្ស៊ីដោយការងារផ្តោតលើកិច្ចការស្ត្រីជាចំបង ជាតំណាងរាស្ត្រចំនួន៣អាណត្តិ ជាប្រធានស្ត្រីប្រជាធិបតេយ្យនៅប៉ែកអាស៊ី (CALD) Council of Asian Liberals and Democrats នៅឆ្នាំ២០០៩ និងជាអ្នកដឹកនាំចលនាស្ត្រីនៅក្នុងគណបក្សនយោបាយផងដែរ ។ លោកជំទាវបានយល់យ៉ាងស៊ីជំរៅ និងមានបទពិសោធតាមរយៈការធ្វើសកម្មភាពជាច្រើនទាក់ទងនឹងការការពារ ការដោះស្រាយបញ្ហាស្ត្រី និងលើកស្ទួយស្ត្រីចូលរួមក្នុងវិស័យនយោបាយ និងកិច្ចការសាធារណៈ ដូចជា បាននាំញត្តិជូនទៅលោកស្រីហ៊ីលឡារីគ្លីនតុន អំពីអ្នកបុរីកីឡា និងបឹងកក់ ដែលត្រូវក្រុមអាជ្ញាធរ ប៉ូលីសប៉េអឹមបានចាប់ស្ត្រីរងគ្រោះជាង ១០រូបទៅឃុំឃាំងដោយសារពួកគាត់ទាមទារអោយមានសំណងសមរម្យជាមួយក្រុមហ៊ុនផានអ៊ីម៉ិច ដែលបានរំលោភយកផ្ទះសម្បែងពួកគាត់ ។ ជួយអន្តរាគមន៍ និងទប់ស្កាត់ចំពោះក្រុមហ៊ុនដែលនាំពលការិនីទៅបម្រើការងារមេផ្ទះនៅប្រទេសម៉ាឡេស៊ី ប្រទេសអាហ្វ្រិកខាងត្បូង ដែលក្រុមហ៊ុនមិនខ្វាយខ្វល់ពីការលំបាកចំពោះពលករពេលជួបបញ្ហាធ្ងន់ធ្ងរនៅទីនោះ ហើយជាពិសេសពលករមិនទាន់គ្រប់អាយុត្រូវបានក្រុមហ៊ុនក្លែងឯកសារ ទង្វើទាំងនេះជាទង្វើខុសច្បាប់ទាំងស្រុង ។ លោកជំទាវតែងតែចុះសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ ស្តាប់ពីកង្វល់ និងដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រីដែលមានបញ្ហាដីធ្លីនៅមណ្ឌលរបស់ខ្លួនរួមទាំងតំបន់បឹងកក់ បុរីកីឡានៅរាជធានីភ្នំពេញ និងរៀបចំវេទិកាសាធារណៈតំណាងរាស្ត្រជួបជាមួយប្រជាពលរដ្ឋម្ចាស់ឆ្នោតដើម្បីផ្តល់ឱកាសឲ្យម្ចាស់ឆ្នោតសម្តែងមតិពីទុក្ខលំបាករបស់ខ្លួន ដែលបានជួបប្រទះនៅតាមមូលដ្ឋាននាពេលកន្លងមក ដើម្បីឲ្យតំណាងរាស្ត្រនាំទៅដោះស្រាយបន្ត ។ល។ និង។ល។

ឆ្លើយតបទៅនឹងករណីទាំងនេះ គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (គសន) និងក្រុមអង្គការសង្គមស៊ីវិលចំនួន១២អង្គភាព បានចេញនូវសេចក្តីថ្លែងការណ៍រួមមួយកាលពីថ្ងៃច័ន្ទ ទី២៥ ខែសីហា ឆ្នាំ២០១៤ដោយបានស្នើឲ្យរដ្ឋសភា ពិសេសគណបក្សប្រជាជនកម្ពុជាយកចិត្តទុកដាក់ ចំពោះសមភាពយេនឌ័រនៃថ្នាក់ដឹកនាំកំពូលរដ្ឋសភា ដោយបន្តរក្សាបេក្ខភាពស្ត្រី លោកជំទាវ **ឃួន សុដារី** ជាអនុប្រធានទី២របស់រដ្ឋសភាដដែល បន្ទាប់ពីក្រុមអង្គការសង្គមស៊ីវិលមើលឃើញថា ក្បាលម៉ាស៊ីនដឹកនាំរដ្ឋសភាអាណត្តិនេះមានសមាសភាពសុទ្ធតែបុរស[42] ។ *(សូមអានសេចក្តីថ្លែងការណ៍រួមនៅក្នុងឧបសម្ព័ន្ធ)*

**លោកស្រី ធីតា ឃីះ** នាយិកាអង្គការសីលការ និងជាប្រធានគណៈកម្មាធិការដឹកនាំនៃគ.ស.ន បានមានប្រសាសន៍ថា *«ការដកលោកជំទាវ **ឃួន សុដារី** គឺជារឿងមួយដែលពេលគណបក្សទាំងពីរបានធ្វើការដោះដូរតួនាទីគ្នា ធ្វើឲ្យបាត់តួនាទី ឬសម្រេចចិត្តដកតួនាទីរបស់លោកជំទាវ **ឃួន សុដារី** ដែលធ្វើឲ្យប៉ះស្ត្រីជាថ្នាក់ដឹកនាំកំពូល និងជាគំរូដល់ប្រជាពលរដ្ឋយើងទូទាំងប្រទេស និងជាពិសេសទៅដល់ស្ត្រីដែលមានចំនួនជាង៥២% »* ។

[42] ការផ្សាយរបស់វិទ្យុបារាំងអន្តរជាតិ(RFI) កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ស្តីពី ការដកតំណែងរបស់លោកជំទាវ ឃួន សុដារី អនុប្រធានទី២នៃរដ្ឋសភា

**លោកស្រី រស់ សុត្ថាព** នាយិកាប្រតិបត្តិនៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍កម្ពុជា (GADC) បានមានប្រសាសន៍ថា « *បើសិនមានកន្លែងតែមួយ(តំណែងតែមួយ)គឺគេសម្រេចឲ្យទៅបុរស នេះគឺជាការគិតជាទំលាប់ទៅហើយសម្រាប់សង្គមកម្ពុជា ។ ម្យ៉ាងវិញទៀត វាអាចពាក់ព័ន្ធនឹងរឿងផលប្រយោជន៍ជាច្រើនផ្សេងទៀត ពីព្រោះរឿងនយោបាយស្ត្រីមិនចំណាយលុយរបស់ខ្លួនសម្រាប់ធ្វើនយោបាយទេ ដែលនេះវាផ្ទុយនឹងចំណង់ចំណូលចិត្តរបស់បុរសទៅវិញ ។ តាមទស្សនៈខ្ញុំយល់ថា លោកជំទាវ* ***ឃួន សុដារី*** *កំពុងតែស្ថិតក្នុងវ័យសកម្ម មានសុខភាពល្អ មានការយល់ដឹងច្រើន ព្រមទាំងមានបទពិសោធអាចក្លាយជាអ្នកដឹកនាំដ៏ល្អដែលអាចជាគំរូដល់ស្ត្រីវ័យក្មេងជំនាន់ក្រោយ និងអាចជួយចូលរួមដោះស្រាយបញ្ហាស្ត្រីបាន»*

**លោកស្រី រស់ សុត្ថាព** នាយិកាប្រតិបត្តិនៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍កម្ពុជា (GADC) មានមតិថា « *គឺពាក់ព័ន្ធនឹងអារម្មណ៍របស់អ្នកនយោបាយ អ្នកសម្រេចចិត្តខ្ពស់ដែលភាគច្រើនជាបុរស មិនចង់បានទេ ដូចជា* ***លោកជំទាវ មួ សុខហួរ*** *គាត់ជាមនុស្សដែលហ៊ាននិយាយ អញ្ចឹងគេខ្លាចនូវវត្តមានរបស់គាត់ក្នុងតួនាទីខ្ពស់នេះ ដែលអាចនឹងធ្វើឲ្យប៉ះពាល់ដល់ការរក្សានូវអំណាច និងផលប្រយោជន៍របស់គេ គេមិនខ្វល់ថាអ្នកឯងធ្វើការដើម្បីជាតិ ឬដើម្បីអភិវឌ្ឍន៍សង្គមរីកចម្រើននោះទេ »* ។

សរុបសេចក្ដីមក រាល់ការសម្រេចចិត្តតែងតែស្ថិតនៅក្នុងកណ្ដាប់ដៃបុរស ដែលបង្កប់ទៅដោយអាកប្បកិរិយារើសអើងចំពោះស្ត្រី ហើយទីបំផុតស្ត្រីនៅតែជាជនរងគ្រោះ ។ នេះក៏ព្រោះតែបុរសមិនមានGender Sensitive និងខ្វះឆន្ទៈនយោបាយក្នុងការលើកស្ទួយ និងអនុវត្ត**អនុសញ្ញាអន្តរជាតិស៊ី-ដ** ស្ដីពី*ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* ដែលកម្ពុជាជាប្រទេសហត្ថលេខី និងគោលនយោបាយរបស់រដ្ឋាភិបាល ។ អនុសញ្ញានេះទាមទារឲ្យមានជាវិធានការពិសេសក្នុងការលើកស្ទួយដល់ការចូលរួមរបស់ស្ត្រីនៅគ្រប់លំដាប់ថ្នាក់។ **មាត្រា៣**ចែងថា« *ក្នុងគ្រប់វិស័យ ជាពិសេសវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមទាំងការធ្វើច្បាប់ផងដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចម្រើនពេញលេញរបស់ស្ត្រី ដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដោយសមភាពជាមួយបុរស»* ។

## II. ការសិក្សាលើក្រុមគោលដៅ ស្ដីពី ការផ្ដល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែល

ក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន ៥ខេត្ត ដូចជា ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តតាកែវ បច្ចុប្បន្នមានស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន **៥២៦នាក់ (១៥,៣៩%)**ក្នុងចំណោម**៣៤១៨នាក់** ក្នុងនោះមេឃុំស្ត្រីមានចំនួន **២៦នាក់** ។ សកម្មជនបណ្ដាញស្ត្រីខុមហ្វ្រែល (CWNA)នៃកម្មវិធីស្ត្រីអាចធ្វើបានចំនួន៣០នាក់ ត្រូវបានដាក់ពង្រាយនៅតំបន់គោលដៅខាងលើនេះ ដោយផ្ដោតលើ**ស្រុកចំនួន៨** និង**១៤ឃុំ** ។ សកម្មភាពជារួម គឺសង្កេត ឃ្លាំមើលលើស្ថានភាព និងដំណើរ

ការអនុវត្តកិច្ចការងារតាមតួនាទី ភារកិច្ចរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិទី៣(ឆ្នាំ២០១២-២០១៧)នេះ ជួបសម្ភាសន៍ផ្ទាល់ជាមួយស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ និងធ្វើករណីសិក្សាផងដែរ ។

# ១. ព័ត៌មានទូទៅទាក់ទងនឹងការចូលរួមនយោបាយរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

## ១.១. ព័ត៌មានទូទៅរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងចំណោមស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៣១នាក់ គឺមានអាយុ ស្ថានភាពគ្រួសារ និងមកពីប្រភពខុសៗគ្នា ក្នុងនោះស្ត្រីវ័យក្មេងអាយុចន្លោះពី២០ឆ្នាំដល់៣០ឆ្នាំមានចំនួន ១នាក់ ។ ស្ត្រីក្នុងវ័យកណ្តាលអាយុចន្លោះពី៣១ឆ្នាំដល់៤០ឆ្នាំមានចំនួន៣នាក់ ។ ស្ត្រីក្នុងបជ្ឈឹមវ័យអាយុចន្លោះពី៤១ឆ្នាំដល់៥០ឆ្នាំមានចំនួន៦នាក់ និងស្ត្រីវ័យចំណាស់អាយុលើសពី៥០ឆ្នាំមានចំនួនច្រើន២១នាក់ ។ ចំណែកឯស្ថានភាពគ្រួសាររបស់ស្ត្រីទាំងនោះ ១៩នាក់មានគ្រួសារ ៧នាក់ជាស្ត្រីមេម៉ាយ និង៥នាក់នៅលីវដែលមានប្រភពមកពីសមាជិកគណបក្សនយោបាយ ជនបង្គោលឃុំ ប្រធានភូមិ សមាជិកភូមិ សមាជិកគណៈកម្មការឃុំ ប្រធានសមាគមនារីឃុំ បុគ្គលិកអណ្តែតកិច្ចការនារីស្រុក ប្រជាពលរដ្ឋធម្មតា អ្នកស្ម័គ្រចិត្តភូមិផ្នែកសុខភាព សកម្មជនអង្គការសិទ្ធិមនុស្ស និងសមាជិកបំរុងឃុំ ។ តាមរយៈតួលេខខាងលើនេះ បង្ហាញឲ្យឃើញថា ស្ត្រីវ័យក្មេងមានតួនាទីជាក្រុមប្រឹក្សាឃុំ សង្កាត់មានចំនួនតិចតួច ខណៈដែលស្ត្រីវ័យចំណាស់បាន និងកំពុងមានវត្តមានដ៏ច្រើន និងបង្ហាញអំពីទំនាក់ទំនងយ៉ាងខ្លាំងក្លាក្នុងការចូលរួមក្នុងកិច្ចការនយោបាយ និងការចូលជាសមាជិកគណបក្សនយោបាយ និងបង្ហាញពីឆន្ទៈមោះមុតក្នុងការធ្វើឲ្យខ្លួនក្លាយជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទោះបីជាប្រជាពលរដ្ឋធម្មតាក៏ដោយ ។

## ១.២. ចំនួនអាណត្តិរបស់ស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងចំណោមស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៣១នាក់ មាន៥នាក់ដែលទើបតែជាប់ជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ នៅអាណត្តិទី៣ (១អាណត្តិ) ។ ១៤នាក់បានធ្វើជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ២អាណត្តិ ( អាណត្តិទី១ និងទី៣ចំនួន២នាក់ និង១២នាក់ក្នុងអាណត្តិទី២ និងទី៣) និង១២នាក់បានធ្វើជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៣អាណត្តិ ។ តួលេខបញ្ជាក់ឲ្យឃើញថា ស្ត្រីភាគច្រើនមិនអាចមានឱកាសបានធ្វើជាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៣អាណត្តិឡើយ ទោះបីពួកគេខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ហើយកាន់តែមានឱកាសតិចតួចទៅទៀតចំពោះស្ត្រីដែលនឹងត្រូវជាប់ឆ្នោតថ្មីជាក្រុមប្រឹក្សាឃុំ សង្កាត់ ។ នេះអាចមកពីខ្វះការយកចិត្តទុកដាក់ពីប្រធានគណបក្សនៅថ្នាក់ក្រោមជាតិ(ខេត្ត ស្រុក ឃុំ) ជាពិសេសប្រធានគណបក្សនៅថ្នាក់ឃុំ សង្កាត់ដែលភាគច្រើនមានតួនាទីជាមេឃុំ ចៅសង្កាត់បុរស និងខ្វះនូវគោលនយោបាយលើកស្ទួយស្ត្រីនៅក្នុងគណបក្សរបស់ខ្លួនផងដែរ ។

## ១.៣. តួនាទីរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់៣១នាក់ មាន១នាក់មានតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ/មេឃុំ ។ ៣នាក់មានតួនាទីជាជំទប់ទី១ ៣នាក់មានតួនាទីជាជំទប់ទី២ និង២៤នាក់មានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ ក្នុងនោះភាគច្រើនទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ ។ តួលេខបង្ហាញយ៉ាងច្បាស់ថាស្ត្រីមានឱកាសតិចតួចក្នុងការទទួលបានតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ឬជាមេឃុំ ចៅសង្កាត់។

## ១.៤. មូលហេតុនៃការចូលប្រឡូកក្នុងកិច្ចការនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់




សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៣១នាក់ បានបង្ហាញពីមូលហេតុដែលពួកគាត់ចូលប្រឡូកក្នុងកិច្ចការនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ មាន១០៩ចម្លើយក្នុងនោះ៣០ចម្លើយបង្ហាញថា ចង់លើកកម្ពស់ស្ត្រី ២៤ចម្លើយចង់ជួយសង្គមដោយផ្ទាល់ ២០ចម្លើយចង់ការពារផលប្រយោជន៍ស្ត្រី ១៨ចម្លើយគិតពីអនាគតកូនចៅ និង១៤ចម្លើយគិតពីជីវភាពគ្រួសារប្រចាំថ្ងៃ ។ ទោះបីចម្លើយមានផ្សេងៗគ្នាខ្លះក៏ដោយក៏ស្ត្រីទាំងអស់មានការប្តេជ្ញាចិត្តចូលរួមក្នុងកិច្ចការនយោបាយ ក្នុងគោលបំណងចូលរួមអភិវឌ្ឍន៍សង្គមជាតិដូចគ្នា ជាពិសេសជួយដោះស្រាយបញ្ហាស្ត្រី និងលើកស្ទួយស្ថានភាពស្ត្រីឲ្យមានភាពប្រសើរឡើង ។

## ២. ស្ថានភាពស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន

### ២.១. ការរើសអើងស្ត្រី

#### ២.១.១. អារម្មណ៍របស់អ្នកជិតខាង អ្នកស្គាល់ មិត្តភក្តិ និងគ្រួសារចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

ស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៣១នាក់ បានបង្ហាញថា បានទទួលការគាំទ្រទាំងស្រុងពីក្រុមគ្រួសារ និងមានការអបអរសាទរពីប្រជាពលរដ្ឋចំពោះពួកគាត់ ពេញចិត្តការងាររបស់ពួកគាត់ មានសមត្ថភាពជួយធ្វើការងារ ប្រជាពលរដ្ឋទុកចិត្ត ប្រជាពលរដ្ឋពេញចិត្តឲ្យធ្វើបន្ត ព្រោះប្រជាពលរដ្ឋអាចពឹងពាក់បាន ចង់ឲ្យមានវត្តមានស្ត្រីច្រើននៅក្នុងឃុំ សង្កាត់របស់គាត់ ។

ការឲ្យតម្លៃ និងការគាំទ្រយ៉ាងពេញទំហឹងពីប្រជាពលរដ្ឋ និងក្រុមគ្រួសារចំពោះសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីជាអ្នកដឹកនាំ និងក្នុងវិស័យនយោបាយនេះ ជាកំលាំងជំរុញលើកទឹកចិត្តដល់ការចូលរួមរបស់ស្ត្រីកាន់តែមានភាពសកម្មថែមមួយកម្រិតទៀត ។

#### ២.១.២. អាកប្បកិរិយាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបុរសដែលបំពេញកិច្ចការជាមួយស្ត្រី




ក្នុងចំណោមស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៣១នាក់ មាន២៥នាក់បញ្ជាក់ថា មានការគាំទ្រ និងលើកទឹកចិត្តពីបុរសជាក្រុមប្រឹក្សាឃុំ សង្កាត់ និងមានការផ្លាស់ប្តូរអាកប្បកិរិយាឲ្យតម្លៃស្ត្រីដោយយល់ថា

ស្ត្រីជា ដៃគូដ៏សំខាន់មិនអាចខ្វះបាន ស្ត្រីធ្វើការងារសម្រេចបានដូចបុរសដែរ ។ ៦នាក់ទៀតប្រាប់ថា បុរសនៅតែរើសអើង និងមិនចង់សហការជាស្ត្រីឡើយ ។ បច្ចុប្បន្ន យើងសង្កេតឃើញថា បុរសភាគច្រើន រួមទាំងផ្នត់គំនិតសង្គមផងដែរ ចាប់ផ្តើមប្តូរអាកប្បកិរិយារបស់ខ្លួនមកឲ្យតម្លៃស្ត្រី យល់ថាការចូលរួមរបស់ស្ត្រីពិតជាមានសារៈសំខាន់ ជាពិសេសការចូលរួមនៅថ្នាក់សម្រេចចិត្ត ។

### ២.២. ការទទួលបានភារកិច្ចការងារ សិទ្ធិអំណាចពេញលេញរបស់ស្ត្រីតាមច្បាប់

#### ២.២.១. ការប្រគល់តួនាទី ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ទៅសមាជិកស្ត្រីរបស់ខ្លួន




ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់៣១នាក់ មាន២៦នាក់ ឆ្លើយថាប្រធានក្រុមប្រឹក្សាបានប្រគល់ តួនាទី ភារកិច្ចជូនពួកគាត់ដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដូចមានចែងក្នុងច្បាប់ ។ ៥នាក់ ឆ្លើយថាមានការប្រគល់ភារកិច្ចជូនខ្លះៗដែរ ។ ខណៈដែលសមាជិកស្ត្រីភាគច្រើនទទួល បានតួនាទីភារកិច្ចត្រឹមត្រូវតាមច្បាប់ ចំណែកឯសមាជិកស្ត្រីមួយចំនួនទៀតបានទទួលភារកិច្ចខ្លះៗប៉ុណ្ណោះ ដែលនេះគឺជាការបង្ហាញនូវភាពរើសអើង និងនៅតែជាបញ្ហាដែលត្រូវតែយកចិត្តទុកដាក់ដោះស្រាយចំពោះសមាជិកក្រុមប្រឹក្សាណាដែលមិនបានទទួលតួនាទី ភារកិច្ចរបស់ខ្លួនពេញលេញដើម្បីអនុវត្តការងារស្របតាមច្បាប់ ស្តីពី « *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* » ដែលបានធានាដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវតែមានភារកិច្ចទៅតាមតួនាទីរៀងៗខ្លួន ។

### ២.២.២. តើនៅតំបន់របស់លោកស្រី នាងកញ្ញា ធ្លាប់ដឹងថា មានគេបញ្ឈប់សមាជិកស្ត្រីក្រុមប្រឹក្សាឃុំដែរឬទេ?

ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់៣១នាក់ មាន២៩នាក់ឆ្លើយថាមិនមានគេបញ្ឈប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីនៅក្នុងតំបន់របស់ពួកគាត់ទេ។ ២នាក់ឆ្លើយថា មិនដឹង ។

## ២.៣. ការបំពេញការងារទាក់ទងនឹងស្ត្រី និងកុមារ និងភាពសកម្មរបស់ស្ត្រី

ស្ថិតក្នុងតួនាទីរបស់ខ្លួន ក្រុមប្រឹក្សាឃុំ សង្កាត់ស្ត្រីទាំង៣១នាក់ កំពុងធ្វើការងារយ៉ាងសកម្មនាពេលបច្ចុប្បន្ន ។ ជាក់ស្តែង ស្ត្រីដែលមានតួនាទីជា**ជំទប់ទី១ និងទី២** កំពុងរវល់ជាមួយនឹងការដោះស្រាយបញ្ហាទំនាស់ក្នុងមូលដ្ឋានដូចជា អំពើហឹង្សាក្នុងគ្រួសារ ទំនាស់ដីធ្លី និងបញ្ហាអត្រានុកូលដ្ឋាន ។ ចំណែកឯស្ត្រីដែលមានតួនាទីជា**សមាជិកធម្មតា**ដែលភាគច្រើនទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ កំពុងជាប់រវល់ជាមួយនឹងការចុះសួរសុខទុក្ខស្ត្រីក្រីក្រ អ្នកមានជំងឺ ស្ត្រីឆ្លងទន្លេ ជួយជំរុញគ្រួសារក្រីក្រឲ្យបញ្ជូនកុមារទៅសាលារៀន ក្តាប់ស្ថិតិគ្រួសារស្ត្រីក្រីក្រ និងជួយសរសេរសំបុត្រកំណើត និងលិខិតផ្សេងៗ ។ ដោយឡែក ស្ត្រីដែលមានតួនាទីជា**ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់/មេឃុំ** កំពុងប្រតិបត្តិការដូចជា រៀបចំ ចាត់ចែងកិច្ចការសន្តិសុខក្នុងភូមិ ឃុំ រៀបចំអ្នកស្ម័គ្រចិត្តការពារភូមិ ចន្លោះពី ៤ ទៅ ៥នាក់ ឬ ៧ ទៅ៨នាក់ក្នុងមួយភូមិ ដោយមានការសហការជាមួយនគរបាលឃុំ សង្កាត់ និងការចូលរួមកម្មវិធីរបស់អង្គការមួយចំនួនដែលមានសកម្មភាពអភិវឌ្ឍន៍ភូមិ ឃុំ និងធ្វើការសហការគ្នាយ៉ាងជិតដិតដើម្បីដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ ។

## ២.៤. ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត

### ២.៤.១. ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ និងកិច្ចប្រជុំប្រចាំខែ

ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់៣១នាក់ មាន២៣នាក់បានចូលរួមប្រជុំមួយដងក្នុង១ខែជាទៀងទាត់ និង៨នាក់បានចូលរួមប្រជុំពីរដងក្នុង១ខែ ។ តាមតួលេខនេះបង្ហាញថា ស្ត្រីមានឱកាសចូលរួមប្រជុំដោយពេញលេញស្របតាមច្បាប់ និងបទបញ្ជាផ្ទៃក្នុងសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែយើងនៅតែមានការព្រួយបារម្ភ និងហាក់បីដូចជាពុំទាន់មានទំនុកចិត្តនៅឡើយអំពីការចូលរួមការបញ្ចេញមតិ យោបល់ និងការធ្វើសេចក្តីសម្រេចរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយបុរសភាគច្រើន ។ ជាទូទៅឃុំ សង្កាត់ទូទាំងព្រះរាជាណាចក្រកម្ពុជា ឃុំ សង្កាត់ខ្លះមានក្រុមប្រឹក្សាស្ត្រីជាអតិបរមា ៤នាក់ ឃុំ សង្កាត់ខ្លះមានស្ត្រី៣នាក់ ឃុំ សង្កាត់ខ្លះទៀតមានស្ត្រី២នាក់ ឃុំ សង្កាត់ខ្លះមានស្ត្រី១នាក់ និង ឃុំ

សង្កាត់ខ្លះទៀតពុំមានស្ត្រីសោះ ។ នេះជាកត្តាធ្វើឲ្យការចូលរួមសម្រេចចិត្តរបស់ស្ត្រីជួបនូវការលំបាក និងត្រូវរងឥទ្ធិពលពីការសម្រេចចិត្តរបស់បុរសដែលជាមតិភាគច្រើន ។

### ២.៤.២. ការបញ្ចេញមតិយោបល់ ឬ សំណើររបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំ

ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់៣១នាក់ដែលបានចូលរួមប្រជុំ មាន២៧នាក់ក្លាហានក្នុងការបញ្ចេញយោបល់ និងលើកសំណើរដើម្បីឲ្យមានការដោះស្រាយ និង៤នាក់ទៀតមិនធ្លាប់បានបញ្ចេញយោបល់ ឬសំណើរអ្វីសោះ ។ លទ្ធផលនេះបញ្ជាក់ថា ស្ត្រីចាប់ផ្តើមបង្ហាញពីឥទ្ធិពលរបស់ខ្លួនភាពជឿជាក់លើខ្លួនឯង និងភាពក្លាហានក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំដែលភាគច្រើនផ្តោតលើបញ្ហា ស្ត្រី កុមារ និងអំពើពុករលួយ ។ ទោះជាយ៉ាងនេះក្តី យើងចង់ឃើញស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ចូលរួមបញ្ចេញមតិ យោបល់ក្នុងអង្គប្រជុំឲ្យបានគ្រប់ៗគ្នា ដោយមានការលើកទឹកចិត្ត និងផ្តល់ឱកាសពីមេឃុំបុរស និងសមាជិកបុរសភាគច្រើន និងផ្តល់អំណាចឲ្យស្ត្រីចូលរួមដោយពេញលេញ ។

| សំណើ និងយោបល់របស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងអង្គប្រជុំ ដើម្បីដោះស្រាយ |
|---|
| ថវិកាសំរាប់ស្ត្រីមានផ្ទៃពោះ និងសំរាលបុត្រក្រីក្រ និងបញ្ហាស្ត្រីមានផ្ទៃពោះក្រីក្រ |
| អំពីគំពោងជួយស្ត្រីមានផ្ទៃពោះទៅមណ្ឌលសុខភាព |
| អំពីគំពោងជួយកុមារក្រីក្រ និងកុមារកំព្រាទៅសាលារៀន និងការឧបត្ថម្ភសម្ភារៈសិក្សា ដូចជា សៀវភៅ ប៊ិច ខ្មៅដៃ អង្ករ និងថវិកាមួយចំនួន។ |
| អំពីគំពោងថវិកាសំរាប់ជួយស្ត្រី និងកុមារគ្រួសារក្រីក្រ ប័ណ្ណក្រីក្រសំរាប់សំរាលបុត្រ ។ |
| អំពីការចូលរួមបញ្ចេញមតិយោបល់របស់សមាជិកក្រុមប្រឹក្សា ដើម្បីស្វែងរកគំនិតល្អសំរាប់អភិវឌ្ឍន៍ឃុំ សង្កាត់។ |
| អំពីគំពោងថវិកាដើម្បីលើកស្ទួយស្ត្រី ដូចជាកម្មវិធី ទិវានារីអន្តរជាតិ ។ |
| អំពីបញ្ហាធ្វើផ្លូវថ្នល់ មានការកិបកេងថវិកា (ពុករលួយ) ស្នើឲ្យមានការតាមដានស៊ើបអង្កេត ព្រោះគំពោងធ្វើផ្លូវតាមផែនការ ត្រូវធ្វើកំរាស់៣តឹក ប៉ុន្តែជាក់ស្តែង ធ្វើតែ១តឹកកន្លះ។ |
| អំពីបញ្ហាហឹង្សាក្នុងគ្រួសារ ស្ត្រីរងគ្រោះ ជនក្រីក្រ |
| អំពីបញ្ហាហឹង្សាក្នុងគ្រួសារ ស្ត្រីរងគ្រោះ ជនក្រីក្រ ជំងឺអេដស៍ឲ្យមានជំនួយ |
| អំពីអនាម័យ និងទឹកស្អាត |
| អំពីការផ្សព្វផ្សាយបន្ថែមពីបញ្ហាស្ត្រី និងកុមារ និង ធ្វើអគ្រានុកូលដ្ឋាន។ |

| |
|---|
| បញ្ហាសន្តិសុខ ភូមិឃុំមានសុវត្ថភាព |
| បញ្ហាស្ពាន សាលារៀន ផ្លូវថ្នល់ និងមន្ទីរសុខភាពដើម្បីងាយស្រួលដឹកភោគផលដំណាំ និងធ្វើដំណើរបានងាយស្រួល។ |

### ២.៤.៣. ការឆ្លើយតបទៅលើយោបល់ ឬសំណើរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអង្គប្រជុំ

ក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ២៧នាក់បានលើកសំណើ និងយោបល់ មាន២៤នាក់ឆ្លើយថា សំណើ និងយោបល់របស់ពួកគាត់ត្រូវបានគេសម្រេចក្នុងអង្គប្រជុំ និងយកទៅដោះស្រាយ ។ ១ នាក់ ឆ្លើយថា បានត្រឹមតែយកសំណើ និងយោបល់របស់គាត់ទៅទុកពិចារណាដើម្បីសម្រេចពេលក្រោយដោយពុំមានកំណត់ពេលវេលាច្បាស់លាស់ និង២នាក់ទៀត បញ្ជាក់ថា មិនបានយកសំណើ និងយោបល់របស់ពួកគាត់ទៅដោះស្រាយទេ ។

**សំណើ និងយោបល់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានសម្រេចក្នុងអង្គប្រជុំ និងដោះស្រាយ ៖**

| សំណើ និងយោបល់របស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ | ការសម្រេច និងដំណោះស្រាយ |
|---|---|
| ថវិកាសំរាប់ស្ត្រីមានផ្ទៃពោះ និងសំរាលបុត្រក្រីក្រ និងបញ្ហាស្ត្រីមានផ្ទៃពោះក្រីក្រ | -ព្រមឯកភាពឧបត្ថម្ភជាអង្ករ និងសម្ភារៈសិក្សាមួយចំនួនដល់កុមារក្រីក្រ កុមារកំព្រា ។ |
| គំរោងជួយកុមារក្រីក្រ និងកុមារកំព្រាទៅសាលារៀន និងការឧបត្ថម្ភសម្ភារៈសិក្សា ដូចជា សៀវភៅ ប៊ិច ខ្មៅដៃ អង្ករ និងថវិកាមួយចំនួន។ | -ជួយជាប័ណ្ណក្រីក្រសម្រាប់គ្រួសារក្រីក្រសំរាលកូនក្នុង១ដង ចំនួន៦ម៉ឺនរៀល និងផ្តល់ជាធុងចំពោះ ។ |
| គំរោងថវិកាសំរាប់ជួយស្ត្រី និងកុមារ គ្រួសារក្រីក្រ និងប័ណ្ណក្រីក្រសំរាប់សំរាលបុត្រ ។ | -ជួយជាថវិកាដល់ស្ត្រីមានផ្ទៃពោះក្រីក្រក្នុង១នាក់ ចំនួន ៥ម៉ឺនរៀល ។ |
| គំរោងសំរាប់ជួយស្ត្រីមានផ្ទៃពោះទៅមណ្ឌលសុខភាព | -បានចេញជាលិខិបញ្ជាក់ សំរាប់ជួយដល់ស្ត្រីមានផ្ទៃពោះទៅមណ្ឌលសុខភាព កុមារកំព្រា និងកុមារក្រីក្រ ទៅសាលារៀនក្នុងមួយគ្រួសារចំនួន ៤ម៉ឺនរៀល និងអង្ករចំនួន ១០គកក្នុង១ខែ។ |
| គំរោងថវិកាដើម្បីលើកស្ទួយស្ត្រី ដូចជាកម្មវិធី ទិវានារីអន្តរជាតិ ។ | យល់ព្រមផ្តល់ថវិកាដើម្បីរៀបចំតាមគំរោង |
| អំពីអនាម័យ និងទឹកស្អាត | យល់ព្រម និងចុះធ្វើស្ថិតិតាមភូមិក្រីក្រ ដើម្បីស្វែងរកជំនួយ ឬរកអង្គការជួយ។ល។ |
| អំពីការផ្សព្វផ្សាយបន្ថែមពីបញ្ហាស្ត្រី និងកុមារ និងធ្វើ អត្រានុកូលដ្ឋាន។ | យល់ព្រមតាមសំណើ |

| | |
|---|---|
| អំពីបញ្ហាហឹង្សាក្នុងគ្រួសារ ស្ត្រីរងគ្រោះ ជនក្រីក្រ ជំងឺអេដស៍ឲ្យមានជំនួយ។ | - យល់ព្រមផ្តល់ជំនួយជាថ្នាំ ថវិកា និងអង្ករ។ល។<br>- ចុះផ្សព្វផ្សាយប្រជាពលរដ្ឋតាមភូមិ ផ្សព្វ ផ្សាយច្បាប់ ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ |
| អំពីការចូលរួមបញ្ចេញមតិយោបល់របស់សមាជិកក្រុមប្រឹក្សា ដើម្បីស្វែងរកគំនិតល្អសំរាប់អភិវឌ្ឍន៍ឃុំ សង្កាត់។ | មិនមានការដោះស្រាយ |
| អំពីបញ្ហាស្មៀនមានលំនៅដ្ឋាននៅឃុំផ្សេងពីឃុំអនុវត្តការងារ នាំឲ្យមានការលំបាកក្នុងការងារដូចជា បោះត្រា ឯកសារផ្សេងៗ។ល។ | |
| អំពីបញ្ហាធ្វើផ្លូវថ្នល់ មានការកិបកេងថវិកា (ពុករលួយ) ស្នើឲ្យមានការតាមដានស៊ើបអង្កេត ព្រោះគំរោងធ្វើផ្លូវតាមផែនការ ត្រូវធ្វើកំរាស់៣តឹក ប៉ុន្តែជាក់ស្តែង ធ្វើតែ១តឹកកន្លះ។ | |
| បញ្ហាស្ពាន សាលារៀន ផ្លូវថ្នល់ និងមន្ទីរសុខភាព ដើម្បីងាយស្រួលដឹកភោគផលដំណាំ និងធ្វើដំណើរបានងាយស្រួល | ធ្វើស្ពានដែក ផ្លូវថ្នល់ អណ្តូង សាលារៀន មន្ទីរពេទ្យ |
| បញ្ហាសន្តិសុខ ភូមិឃុំមានសុវត្ថភាព | កំពុងដោះស្រាយបញ្ហាភូមិឃុំមានសុវត្ថិភាព |

## ៣. តម្លាភាពថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារនៅឃុំ សង្កាត់

របាយការណ៍ឃ្លាំមើលរបស់ខុមហ្វ្រែល បង្ហាញថា តម្លាភាពថវិកានៅមានកម្រិតសម្រាប់កិច្ចការស្ត្រី និងកុមារនៅឃុំ សង្កាត់ ។ ការមិនសូវមានតម្លាភាពថវិកានេះ ដោយសារកញ្ចប់ថវិកាទាំងនោះនៅមានការលាក់បាំងខ្លះៗ ដូចជា ការចំណាយរបស់ឃុំមិនបានឲ្យដឹងជាមុន ជាពិសេសស្ត្រីក្រុមប្រឹក្សាឃុំដែលមកពីគណបក្សប្រឆាំង គឺពេលដែលចំណាយរួចរាល់ហើយ ទើបស្នើឲ្យមានការចុះហត្ថលេខាដឹងឮតែប៉ុណ្ណោះដោយមិនមានការឆ្លងយោបល់អ្វីឡើយ ។ បន្ថែមលើនេះទៀត ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារមានការលំបាកក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវនៃការងារដោយនៅក្នុងឃុំ សង្កាត់ចំនួនស្ត្រី និងកុមារមានច្រើន ហើយបញ្ហារបស់ពួកគាត់ក៏មានច្រើនដែលតម្រូវឲ្យមានការដោះស្រាយជាចាំបាច់ រួមទាំងកត្តាភូមិសាស្ត្រពីភូមិមួយទៅភូមិមួយនៅឆ្ងាយដាច់ពីគ្នា។

របាយការណ៍រកឃើញទៀតថា ថវិកាសរុបប្រចាំឆ្នាំសម្រាប់កិច្ចការស្ត្រី និងកុមារដែលស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់បានដឹង គឺមានចំនួនខុសៗគ្នានៃឃុំនីមួយៗដោយផ្អែកលើកត្តាភូមិសាស្ត្រ និងប្រជាសាស្ត្រ ៖

- ១៤ ០៥០ ០០០ រៀល (ដប់បួនលាន ប្រាំម៉ឺនរៀល)
- ២ ៥០០ ០០០ រៀល (ពីរលាន ប្រាំសែនរៀល)
- ១ ៥០០ ០០០ រៀល (មួយលាន ប្រាំសែនរៀល)
- ៥០០ ដុល្លារ (ប្រាំរយដុល្លារអាមេរិក)
- ២០០ ដុល្លារ (ពីររយដុល្លារអាមេរិក)

សរុបសេចក្តីមក ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ចាប់ផ្តើមប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន មានភាពជឿជាក់លើខ្លួនឯង និងក្លាហានក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំនានាបើទោះបីជួបនូវឧបសគ្គខ្លះៗក៏ដោយ ។ កិច្ចការ និងមតិយោបល់របស់ស្ត្រីភាគច្រើនផ្តោតលើផលប្រយោជន៍ស្ត្រី និងកុមារជាសំខាន់ ខណៈដែលបុរសភាគច្រើនរួមទាំងផ្ទត់គំនិតសង្គម មានការប្តូរឥរិយាបថមកឲ្យតម្លៃស្ត្រី យល់ថាការចូលរួមរបស់ស្ត្រីពិតជាមានសារៈសំខាន់ ជាពិសេសការចូលរួមនៅថ្នាក់សម្រេចចិត្ត ជាមួយនឹងការគាំទ្រយ៉ាងពេញទំហឹងពីក្រុមគ្រួសារ និងប្រជាពលរដ្ឋ ដែលជាកំលាំងចលករក្នុងការជម្រុញ លើកទឹកចិត្តយ៉ាងខ្លាំងដល់ការចូលរួមរបស់ស្ត្រីឲ្យមានភាពកាន់តែសកម្មថែមមួយកម្រិតទៀត ។ លើសពីនេះ បញ្ហាស្ត្រី និងកុមារក៏ត្រូវបានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងបុរស ទាំងស្ត្រី ចាត់ជាបញ្ហាចម្បង និងត្រូវយកចិត្តទុកដាក់ដោះស្រាយជាបន្តបន្ទាប់ ។

ទោះជាយ៉ាងនេះក្តី ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅតែបន្តមាននៅឡើយដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ដោះស្រាយជាចាំបាច់ ។ រីឯថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារនៅមានការលំបាកក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវការនៃការងារព្រមទាំងតម្លាភាពថវិកាក៏នៅមានកម្រិត ។

## ៤. ករណីសិក្សា

### ៤.១ «សកម្មភាពលេចធ្លោរបស់ស្ត្រីនៅថ្នាក់មូលដ្ឋាន»

### ករណីសិក្សាទី១

លោកស្រី **កែវ សុផាត** ជាសមាជិកគណបក្សប្រជាជនកម្ពុជា និង**ជាប្រធានក្រុមប្រឹក្សា/ចៅសង្កាត់**កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង អាណត្តិទី៣ ដែលមានសមាសភាពសរុបចំនួន៧នាក់ មកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសម រង្ស៊ី ក្នុងនោះមានស្ត្រីចំនួន២នាក់ ។





លោកស្រីមានអាយុ៥៧ឆ្នាំ និងបានរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំ១៩៨១ មានកូន៥នាក់ ប្រុស១នាក់ ស្រី៣នាក់ ។ ចំណែកគ្រួសារជាមន្ត្រីរាជការចូលនិវត្តន៍ ។ លោកស្រីមានកំរិតវប្បធម៌ថ្នាក់ទី៧ (សម័យសង្គមចាស់ និងមានជំនាញជាជាងកាត់ដេរ) ។ លោកស្រីមានប្រវត្តិ និងបទពិសោធការងារដូចតទៅ៖

- ឆ្នាំ១៩៧៩ ចូលរួមប្រមូលផ្តុំគ្នានៅអង្គភាពមួយ រហូតដល់ឆ្នាំ១៩៨១
- ឆ្នាំ១៩៨៤ ជាអនុប្រធានសមាគមនារី ឃុំ រហូតដល់ឆ្នាំ១៩៨៩
- ឆ្នាំ១៩៩៧ ជាប្រធានសមាគមនារី ឃុំ រហូតដល់ឆ្នាំ២០០២
- ឆ្នាំ២០០២ ជាសមាជិកាក្រុមប្រឹក្សាសង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង (អាណត្តិទី១)
- ឆ្នាំ២០០៧ ជាសមាជិកាក្រុមប្រឹក្សាសង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង (អាណត្តិទី២)
- ឆ្នាំ២០១០-២០១១ ចូលរួមវគ្គបណ្តុះបណ្តាលនៃកម្មវិធីស្ត្រីអាចធ្វើបានរបស់អង្គការខុមប្រែល

មូលហេតុដែលលោកស្រីសម្រេចចិត្តចូលរួមក្នុងឆាកនយោបាយនៅថ្នាក់មូលដ្ឋាន ពីព្រោះគិតថា ស្ត្រីអាចធ្វើបានដូចបុរសដែរ ។ ក្នុងអំឡុងពេលកំពុងធ្វើសកម្មភាពនយោបាយ លោកស្រីបានទទួលចំណេះដឹងមួយចំនួនពីអង្គការខុមប្រែល ដូចជា តួនាទីយេនឌ័រ សមភាពយេនឌ័រ សមធម៌យេឌ័រ ហើយអ្វីដែលលោកស្រីមានចំណាប់អារម្មណ៍នោះ គឺការបញ្ជ្រាបយេនឌ័រទៅដល់បុរសក្នុងភូមិ ឃុំ ព្រោះថាបើសិនជាពួកគាត់មានការយល់ដឹង និងមានចំណេះដឹងអំពីយេនឌ័រ នោះនឹងអាចកាត់បន្ថយទំនាស់ហិង្សាក្នុងគ្រួសារក៏ដូចជាទំនាស់ផ្សេងៗ ហើយលោកស្រីបានធ្វើការផ្សព្វផ្សាយបន្តចំនួន៣ទៅ ៤វគ្គដែរ។

លោកស្រីបានមានប្រសាសន៍ថា *«ចំណុចខ្លាំងដែលបណ្តាលឲ្យខ្ញុំជាប់ឆ្នោតពីសមាជិកក្រុមប្រឹក្សាធម្មតា មកជាប្រធានក្រុមប្រឹក្សាឃុំ/មេឃុំ គឺ ដោយសារការចុះមូលដ្ឋាន ការដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ អ្វីដែលជាកង្វល់របស់ប្រជាពលរដ្ឋគឺខ្ញុំដោះស្រាយជូន»* ។ មូលហេតុដែលប្រធានក្រុមប្រឹក្សាឃុំ/មេឃុំជាបុរសបានធ្លាក់ទៅជាសមាជិកធម្មតា ហើយបែរជាលោកស្រីជាសមាជិកធម្មតា បាន

ជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាឃុំស្ត្រីនៅក្នុងអាណត្តិទី៣នេះអាចបណ្តាលមកពីចំណុចពីរយ៉ាង៖ (ទី១) បញ្ហាសុខភាពប្រធានក្រុមប្រឹក្សាសង្កាត់បុរសនោះមិនសូវល្អ មិនអាចចូលរួមធ្វើកិច្ចការងារបានពេញលេញ និង(ទី២)រាល់សកម្មភាពនានា ប្រធានក្រុមប្រឹក្សាសង្កាត់បុរសនោះតែងតែផ្តល់ឱកាសឲ្យលោកស្រីដើរតួជំនួសគាត់ជានិច្ច ។

តាមការយល់ឃើញផ្ទាល់របស់លោកស្រី អំពីភាពខុសគ្នារវាង ការដឹកនាំដោយបុរស និងការដឹកនាំដោយស្ត្រី (លោកស្រីសូមលើតែក្នុងសង្កាត់ខ្លួនផ្ទាល់) គឺថា សំរាប់គាត់ជាស្ត្រី គាត់ធ្វើការចុះមូលដ្ឋានជាញឹកញាប់ ចំណែកឯអតីតចៅសង្កាត់បុរស អត់សូវបានចុះមូលដ្ឋាន ។ ដូច្នេះ បញ្ហាដែលកើតមានចំពោះប្រជាពលរដ្ឋ ពេលខ្លះអាចដឹង ពេលខ្លះក៏អត់ដឹង ដោយសារតែអត់ចុះមូលដ្ឋាន អញ្ចឹងការដោះស្រាយបញ្ហាក៏ដូចជាការអភិវឌ្ឍន៍សង្កាត់ពេលខ្លះអត់ទទួលបានជោគជ័យ ។ លោកស្រីបានបង្ហាញការងារជាក់ស្តែងមួយថា « *ការបង្កើតកងកម្លាំងប្រជាការពារនៅក្នុងភូមិ ទាក់ទិននឹងភូមិ ឃុំមានសុវត្ថិភាពក្នុងអាណត្តិចៅសង្កាត់បុរស យើងត្រូវមានកំលាំងប្អូនៗប្រជាការពារចូលរួម ខ្ញុំធ្លាប់តែឮចៅសង្កាត់បុរសថា នៅភូមិនេះមានឈ្មោះនេះ ឈ្មោះនោះប៉ុណ្ណេះៗ ប៉ុន្តែជាក់ស្តែងដំណើរការសកម្មភាពអត់មាន* » ។

ក្នុងអាណត្តិទី៣នេះ ក្នុងតួនាទីជាចៅសង្កាត់ស្ត្រី លោកស្រីបានផ្តោតទៅលើសកម្មភាពចាស់ៗដែលមានស្រាប់ ។ ជាក់ស្តែង ដើម្បីបង្កើតកំលាំងប្រជាការពារឲ្យមានដំណើរការបានល្អ លោកស្រីបានដាក់ចេញនូវផែនការសកម្មភាពដែលមានប្រសិទ្ធភាពតាមរយៈការកោះប្រជុំសមាជិកក្រុមប្រឹក្សាសង្កាត់ដោយសហការជា មួយសមត្ថកិច្ចថ្នាក់ក្រុង ថ្នាក់សង្កាត់ ។ ជាលទ្ធផល ឥឡូវប្រជាការពារភូមិនៅសង្កាត់កំពង់ឆ្នាំងនេះ មានប្រាំមួយក្រុមហើយ ហើយក្នុងមួយភូមិ អាចមាន៤ក្រុម អាចមាន៥ក្រុម អាចមាន៦ក្រុមអាស្រ័យលើភូមិ និងកំពុងមានដំណើរការល្អគួរឲ្យកត់សម្គាល់។

លោកស្រីបានបញ្ជាក់យ៉ាងច្បាស់ថា ការបានជាប់ជាប្រធានក្រុមប្រឹក្សា/ចៅសង្កាត់ ដោយសារលោកស្រីឈរឈ្មោះនៅលេខរៀងទី១ និងមានការគាំទ្រច្រើន ។ លោកស្រីយល់ឃើញថា សម្រាប់អាណត្តិទី៤ខាងមុខ គឺអាស្រ័យទៅលើការគាំទ្ររបស់ប្រជាពលរដ្ឋ ក្នុងន័យថា បើប្រជាពលរដ្ឋនៅតែបោះឆ្នោតឲ្យលោកស្រីជាប់ជាចៅសង្កាត់ទៀត គឺ លោកស្រីនឹងខិតខំបំពេញកិច្ចការងារជូនប្រជាពលរដ្ឋវិញដោយមិនគិតពីថ្ងៃឈប់សំរាកទេ។

លោកស្រីមានសំណូមពរថា ដោយសារសមាជិកនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់នេះភាគច្រើនជាបុរសហើយមានវ័យចំណាស់ ដូច្នេះពាក់ព័ន្ធនឹងកិច្ចការមួយចំនួនដែលលំបាក គឺលោកស្រីមិនអាចប្រើពួកគាត់បានទេ អញ្ចឹងមានតែលោកស្រី ត្រូវទៅដោយខ្លួនឯង ឬសមាជិកណាដែលក្មេងៗទៅ ។ ចំណុចមួយទៀតគឺមានបំណងប្រាថ្នាចង់បានដីមួយកន្លែងដើម្បីសាងសង់សង្កាត់ ព្រោះបច្ចុប្បន្នជួលកន្លែងគេទេ។

## ករណីសិក្សាទី២

លោកស្រី **ជួប សុគីន** ជាសមាជិកគណបក្សសម រង្ស៊ី និង**ជាជំទប់ទី១**នៅឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងនៃក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ដែលមានសមាសភាពសរុបចំនួន៩នាក់មកពីគណបក្សប្រជាជនកម្ពុជា គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ក្នុងនោះមានស្ត្រីចំនួន៤នាក់ និងមេឃុំជាបុរស។





បច្ចុប្បន្នលោកស្រីមានអាយុ ៥២ឆ្នាំ ។ លោកស្រីបានរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំ១៩៨៥ មានកូនចំនួន៣នាក់ និងមានម្តាយចាស់ជរាអាយុ៨៣ឆ្នាំរស់នៅក្នុងបន្ទុក ចំណែកប្តីរបស់លោកស្រីមានមុខរបរជាគ្រូថ្នាំបុរាណខ្មែរកាប់សំបកឈើលក់ ។ លោកស្រីមានកំរិតវប្បធម៌ថ្នាក់ទី១០ (សម័យសង្គមចាស់) ។ លោកស្រីមានប្រវត្តិ និងបទពិសោធការងារដូចតទៅៈ

- ឆ្នាំ១៩៧៩ បំរើការក្នុងគណបក្សប្រជាជនកម្ពុជា ក្នុងតួនាទីជាប្រធានយុវជនភូមិ
- ពីឆ្នាំ១៩៨១ ដល់ ឆ្នាំ១៩៨៤ ជាអនុប្រធានសមាគមនារីឃុំប្រទាយព្រាល
- ឆ្នាំ២០០៧-២០១២ ជាជំទប់ទី២នៅឃុំក្រាំងស្គារ ស្រុកទឹកផុស ក្នុងអាណត្តិទី២នៃក្រុមប្រឹក្សាឃុំ សង្កាត់ មកពីគណបក្សសម រង្ស៊ី ។

មូលហេតុដែលបណ្តាលចិត្តឲ្យលោកស្រីចូលប្រឡូកក្នុងឆាកនយោបាយ លោកស្រីបានលើកឡើងថាៈ *«ខ្ញុំមើលទៅការងារដែលខ្ញុំធ្វើហ្នឹងអត់មានផលប្រយោជន៍អីសំរាប់ស្ត្រីខ្មែរទេ បើសិនជាអ្នកមានលុយក្តីជាមួយគេឈ្នះ អ្នកអត់លុយគឺត្រូវតែចាញ់គេ អញ្ចឹងហើយខ្ញុំតាមដានរហូតឃើញថាមិនមានតម្លាភាព»* ។ នៅឆ្នាំ២០០១លោកស្រីក៏បានមករស់នៅក្នុងឃុំក្រាំងស្គារ ដោយមើលឃើញថា គណបក្សសម រង្ស៊ីមានការជួយរាស្ត្រល្អ និងមានអង្គការសិទ្ធិមនុស្សមកស្នើឲ្យលោកស្រីចូលជាមួយអង្គការរបស់ខ្លួនដែលមានលោក កឹម សុខាជាប្រធាន ដូច្នេះហើយលោកស្រីក៏សំរេចចិត្តចូល និងបានទៅចូលរួមវគ្គបណ្តុះបណ្តាល និងទទួលបានវិញ្ញាប័ណ្ណបត្របញ្ជាក់ការសិក្សា។ បន្ទាប់មក លោកស្រីចាប់ផ្តើមជួយដល់ស្ត្រីរងគ្រោះ និងជនរងគ្រោះមួយចំនួនមិនថាស្ត្រី ឬបុរសទេ។ លោកស្រីបានបញ្ជាក់ថា « *ការជួយរបស់ខ្ញុំមិនមានជាតួនាទីអ្វីទេ តែខ្ញុំអាងថា ខ្ញុំមានឈ្មោះនៅក្នុងអង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្ស អញ្ចឹងហើយដែលខ្ញុំ*

*អាចជួយតាមរយៈអង្គការ ឬអាជ្ញាធរផងដែរ ទោះជាអាចជួយបានខ្លះ និងមិនបានខ្លះក៏ដោយ តែខ្ញុំនៅតែព្យាយាមជួយ។ ខ្ញុំមើលទៅការងាររបស់ក្រុមប្រឹក្សាឃុំ របស់មេឃុំ របស់ប៉ុស្តិ៍ របស់ប៉ូលីសអីហ្នឹង ដូចជាធ្វើការមិនមានតម្លាភាព មិនយុត្តិធម៌សោះ»។*

នៅចុងឆ្នាំ២០០៤ លោកស្រីត្រូវបានជាប់ឆ្នោតជាប្រធានតំណាងចលនាស្ត្រីរបស់គណបក្សសម រង្ស៊ី ដោយទទួលបានការចូលរួម និងសំលេងគាំទ្រពីប្រជាពលរដ្ឋលើសតម្រូវការ។ ចាប់ពីពេលនោះមក កេរ្តិ៍ឈ្មោះរបស់លោកស្រីចាប់ផ្ដើមល្បី និងមានការគាំទ្រពីប្រជាពលរដ្ឋយ៉ាងខ្លាំង ទោះបីមានការមើលងាយរិះគន់ខ្លះពីគណបក្សផ្សេងក៏ដោយ ។

ដោយមានការលើកទឹកចិត្តពីក្រុមស្ត្រីចលនាថ្នាក់ឃុំ ពីតំណាងគណបក្សសម រង្ស៊ីថ្នាក់ស្រុក និងពីប្ដីផង លោកស្រីក៏សម្រេចចិត្តឈរឈ្មោះជាបេក្ខជនជាបន្តបន្ទាប់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ អាណត្តិទី២ ឆ្នាំ២០០៧ និងអាណត្តិទី៣ ឆ្នាំ២០១២ ។ ក្នុងការឈរឈ្មោះជាបេក្ខជន លោកស្រីត្រូវជួបនូវឧបសគ្គខ្លះបើទោះបីអ្នកដឹកនាំគណបក្សសម រង្ស៊ីថ្នាក់ស្រុកចង់ឲ្យលោកស្រីឈរនៅលេខរៀងទី១ក៏ដោយ ប៉ុន្តែដោយសារបេក្ខជនបុរសម្នាក់តវ៉ាទាមទារឈរនៅលេខរៀងទី១ដែរ ទើបលោកស្រីត្រូវឈរនៅលេខរៀងទី២វិញនៅអាណត្តិទី២ ។ ជាលទ្ធផល បុរសនោះបានជាប់ជាជំទប់ទី២ តែមិនពេញចិត្តធ្វើក៏ផ្ទេរតួនាទីរបស់ខ្លួនឲ្យមកលោកស្រីក្នុងនាមជាជំទប់ទី២ សម្រាប់អាណត្តិទី២ (ឆ្នាំ២០០៧-២០១២) ។ លោកស្រីត្រូវទទួលនូវមតិរិះគន់ថា មិនអាចធ្វើបានទេក្នុងតួនាទីនេះ ដោយសារតែលោកស្រីមានជីវភាពក្រីក្រ រស់នៅក្នុងខ្ទមតូច ។ ប៉ុន្តែដោយសារតែលោកស្រីយល់ពីសិទ្ធិ និងចង់ចូលរួមជួយដោះស្រាយបញ្ហាប្រជាពលរដ្ឋ និងជួយអភិវឌ្ឍន៍នៅក្នុងឃុំរបស់ខ្លួនដែលជាកត្តាជំរុញឲ្យលោកស្រីត្រូវតែធ្វើនូវកិច្ចការនេះ ។ លោកស្រីក៏បានឈរឈ្មោះជាបេក្ខជននៅលេខរៀងទី១សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ដោយមានការឯកភាពគ្នាពីក្រុមស្ត្រីតាមរយៈការប្រជុំពិភាក្សាជ្រើសរើសតែងតាំង ។ លោកស្រីបានបញ្ជាក់យ៉ាងច្បាស់ថា *« ខ្ញុំបានឈរឈ្មោះនៅលេខរៀងទី១ ដោយសារមានការទុកចិត្តលើសកម្មភាពការងារកន្លងមករបស់ខ្ញុំ ខ្ញុំស្មោះត្រង់ជាមួយពួកគាត់ ដូចជាតម្លាភាពលើការប្រើប្រាស់ថវិកា លុយបក្សឲ្យមកមានចំនួនប៉ុន្មាន ខ្ញុំតែងតែហៅពួកគាត់មកប្រជុំ ពិភាក្សា និងបែងចែកកិច្ចការងារដោយមានបេឡាត្រឹមត្រូវ ចាយលើអី ចំណាយលើអី សាំងម៉ូតូ គោយន្ត។ល។»* ។ ទន្ទឹមនឹងការចូលរួមយ៉ាងសកម្មក្នុងកិច្ចការនយោបាយ លោកស្រីក៏ធ្លាប់ជួបនូវការគំរាមកំហែងដោយប្រយោលដូចជាការកាប់បំផ្លាញស្លាកសញ្ញាគណបក្ស ការនិយាយឌឺដងជាដើម ។

ពីការរស់នៅក្នុងខ្ទមតូច មករស់នៅក្នុងផ្ទះឈើសមរម្យ និងមានជីវភាពប្រសើរជាងមុន ដោយសារតែមានការខិតខំប្រឹងប្រែងទាំងពីរនាក់ប្ដីប្រពន្ធ តាមរយៈការពង្រឹងមុខរបររបស់ប្ដីដោយការលក់ និងព្យាបាលជំងឺតាមបែបថ្នាំខ្មែរបុរាណ និងការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ ដោយមិនមានអំពើពុករលួយក្នុងពេលបំពេញការងារឡើយ ។ ក្នុងតួនាទីជាជំទប់ទី១ នៅអាណត្តិទី៣នេះ លោកស្រីបំពេញកិច្ចការរបស់ខ្លួនយ៉ាងសកម្ម និងបានជួយកិច្ចការផ្សេងៗទៀតដោយមិនរើសអើងអំពីតួនាទី និងនិន្នាការគណ

បក្សនយោបាយតាមការស្នើសុំពីមេឃុំ និង សមាជិកនានានៅក្នុងឃុំ ។ ជាមួយគ្នានេះដែរ លោកស្រីបាន សហការយ៉ាងជិតស្និទជាមួយអង្គការសង្គមស៊ីវិល ដូចជា លេខាធិការខេត្តរបស់ខុមហ្វ្រែលលើករណីអំពើហឹង្សា និងរដ្ឋប្បវេណីតាមរយៈការប្រឹក្សាយោបល់ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋ និងថ្មីៗនេះលោកស្រីបានចូលរួមកម្មវិធីស្ត្រីអាចធ្វើបានរបស់ខុមហ្វ្រែល ដោយ លោកស្រីយកចំណេះដឹងទាំងនេះមកដោះស្រាយបញ្ហាប្រជាពលរដ្ឋផងដែរ ។

លោកស្រីបានសំដែងនូវស្នាដៃរបស់ខ្លួនថា *«អ្វីដែលខ្ញុំបានអនុវត្តលេចធ្លោ គឺដោយសារមានប្រជាពលរដ្ឋមកពឹងពាក់ខ្ញុំ ហើយខ្ញុំអាចដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋបាន ។ ចំណុចនេះហើយដែលបណ្តាលឲ្យមានការច្រណែនចំពោះខ្ញុំថា ខ្ញុំធ្វើការដើម្បីយកសំលេងឆ្នោត»*។ ជាមួយនឹងភាពជោគជ័យក្នុងការងាររបស់ខ្លួន លោកស្រីបានជួបប្រទះការលំបាកផងដែរសម្រាប់រកវិធីដោះស្រាយជំលោះ និងបញ្ហារបស់ប្រជាពលរដ្ឋដែលបានកើតឡើង ព្រោះមិនសូវមានគ្នាធ្វើការ និងខ្វះការរួមសហការពីមេឃុំ និងសមាជិកផ្សេងទៀត ជាពិសេសបុរស ។

លោកស្រីបានសំណូមពរថា *«ពេលយើងជាប់ឆ្នោតហើយ យើងកុំប្រកាន់ថាអ្នកនេះនៅគណបក្សនេះ អ្នកនោះនៅគណបក្សនោះ ខ្លាចមានប្រជាប្រិយភាពជាង ខ្លាចប្រជាជនគាំទ្រជាង គឺយើងបំរើក្នុងរាជរដ្ឋាភិបាលតែមួយ ។ ដូច្នេះ សូមសមាជិកក្រុមប្រឹក្សាឃុំ លោកមេឃុំ ធ្វើការដោយមានការពិភាក្សាគ្នា ចែកតួនាទីគ្នា ធ្វើការសហការគ្នា រួមគ្នាធ្វើការងារដើម្បីដោះស្រាយបញ្ហាជូនរាស្ត្រ ។ នៅពេលមានការងារអីដែលលំបាកៗយើងត្រូវជួយគ្នា មិនត្រូវព្រងើយកន្តើយ ហើយក្នុងការពិភាក្សាហ្នឹង គាត់ជាមេឃុំត្រូវចែកមុខសញ្ញាថា ឥឡូវអ្នកនេះត្រូវធ្វើនេះ អ្នកនោះត្រូវធ្វើនោះ»* ។

លោកស្រីបានសំណូមពរទៀតថា *«យើងគួរមានក្រុមរុករក ក្រុមស៊ើបអង្កេត ។ ជាក់ស្តែង ថ្មីៗនេះពេលមានបញ្ហាគ្រោះមហន្តរាយ បញ្ហាហ្នឹងទាក់ទងនឹងប្រជារាស្ត្រ ប្រជារាស្ត្រមានទុក្ខលំបាក តើគណៈកម្មការគ្រោះមហន្តរាយនៅឯណា? ទាក់ទងទៅមេឃុំៗនៅឯណោះ ដល់អញ្ចឹងយើងមិនមានក្រុមការងារសំរាប់ចុះ»* ។

នាពេលអនាគត លោកស្រីមានការតាំងចិត្តយ៉ាងមុតមាំថា *«ខ្ញុំធ្វើទាល់តែបានតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ/មេឃុំស្ត្រី បើមិនបានទេការងារនៅតែរយីករយាកដូចសព្វថ្ងៃអញ្ចឹង»* ។ នៅអាណត្តិក្រោយ ប្រសិនបើលោកស្រីជាប់ជាប្រធានក្រុមប្រឹក្សាឃុំ ជាមេឃុំស្ត្រី លោកស្រីមានផែនការជាច្រើនដូចជា រៀបចំរចនាសម្ព័ន្ធរបស់ឃុំឲ្យមានតួនាទី ការងាររៀងៗខ្លួន ការងារដែលលំបាកត្រូវតែរួមគ្នាជួយ បង្កើតគណៈកម្មការទ្រទ្រង់សាលា បង្កើតគណៈកម្មការទ្រទ្រង់ផ្លូវ ការពារផ្លូវដែលខូច បង្កើតគណៈកម្មការគ្រោះមហន្តរាយដើម្បីជួយរាស្ត្រ ពង្រឹងជនបង្គោលស្ត្រី និងកុមារ ត្រូវរៀបចំមើលមន្ទីរពេទ្យ មណ្ឌលសុខភាព ។

## ៤.២. « ភាពបរាជ័យរបស់ស្ត្រីបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន»

## ករណីសិក្សាទី៣





លោកស្រី **សៀខ ស៊ីណាន** ជាសមាជិកគណបក្សសម រង្ស៊ី និងជា**ជំទប់ទី២**ឃុំត្បូងក្រពើ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ អាណត្តិទី៣ ដែលមានសមាសភាពសរុបចំនួន ៥នាក់ មកពីគណបក្សសម រង្ស៊ី និងគណបក្សប្រជាជនកម្ពុជា ក្នុងនោះស្ត្រីមានចំនួន២នាក់ ។

លោកស្រីមានអាយុ៥៨ឆ្នាំ បានរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ១៩៧៣ មានកូនចំនួន២នាក់ ស្រី១ និងប្រុស១នាក់ ។ ចំណែកស្វាមីមានវ័យចំណាស់នៅផ្ទះ ។ លោកស្រីមានកំរិតវប្បធម៌ថ្នាក់ទី៧ (សម័យសង្គមចាស់) ។ លោកស្រីមានប្រវត្តិ និងបទពិសោធការងារដូចតទៅ៖

### ប្រវត្តិការងារ

១៩៧៩ ជាបុគ្គលិកពាណិជ្ជកម្មខេត្ត ខាងផ្នែកគណនេយ្យ

១៩៩០ ជាអាជីវករលក់អង្ករ

២០០០ អាជីករលក់ដូរមានបញ្ហា ធ្វើបាតុកម្មជាមួយអ្នកគ្រប់គ្រងផ្សារកំពង់ធំ ដែលក្នុងខណៈពេលនោះ លោកស្រីជាមេខ្យល់ជាអ្នកដឹកនាំធ្វើបាតុកម្ម ។

ពីប្រជាពលរដ្ឋធម្មតាក្លាយជាជំទប់ទី២នៃក្រុមប្រឹក្សាឃុំ លោកស្រីបានរៀបរាប់ពីដំណើរដើមហេតុដែលបណ្តាលឲ្យលោកស្រីចូលប្រឡូកក្នុងឆាកនយោបាយ គឺដោយសារលោកស្រីជាមនុស្សដែលមានភាពក្លាហាន ជាអ្នកហ៊ានក្រោកឈរតស៊ូ ទាមទារ និងដឹកនាំបាតុកម្ម តវ៉ាក្នុងនាមជាអាជីវករផ្សារកំពង់ធំដោយមានការសហការចូលរួមរបស់តំណាងរាស្ត្រមួយចំនួនពីគណបក្សសមរង្ស៊ីផងរហូតដល់មានការស្រលាញ់ពេញចិត្តពីគណបក្សសមរង្ស៊ីក៏សំណូមពរឲ្យលោកស្រីចូលជាសមាជិក និងឲ្យឈរឈ្មោះនៅលេខរៀងទី២ កាលពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០២ អាណត្តិទី១ ក្នុងឃុំកំពង់ធំ ប៉ុន្តែមិនបានជាប់ឆ្នោតទេ ។

លោកស្រីបានផ្លាស់ប្តូរទីលំនៅ ដោយបានឈរឈ្មោះនៅលេខរៀងទី១ និងបានជាប់ឆ្នោតជាជំទប់ទី២នៅឃុំត្បូងក្រពើ ស្រុកស្ទឹងសែន សម្រាប់អាណត្តិទី២ ឆ្នាំ២០០៧ (ដោយសារនៅទីនោះមិនមានអ្នក

ឈរឈ្មោះ) ។ អាណត្តិទី៣ ឆ្នាំ២០១២ លោកស្រីបានឈរឈ្មោះនៅលេខរៀងទី១ទៀត និងបានជាប់ឆ្នោតជាជំទប់ទី២ដដែល ។

លោកស្រីបានបញ្ជាក់ថា មូលហេតុលោកស្រីចូលប្រឡូកក្នុងនយោបាយ ដោយសារលោកស្រីមានការប៉ះទង្គិចផ្នែកសតិអារម្មណ៍ច្រើន ជាក់ស្តែង (ទី១) ពេលដែលលោកស្រីមានបញ្ហាអ្វីៗខាងរដ្ឋអំណាច (អាជ្ញាធរ) គេមិនបានដោះស្រាយជូនលោកស្រីទេ និង(ទី២) លោកស្រីជាអាជីវករលក់អង្ករនៅផ្សារ ។ ជាមួយគ្នានេះដែរ រដ្ឋអំណាចបានយកផ្សារនេះលក់ឲ្យក្រុមហ៊ុនដែលធ្វើអោយពួកគាត់ជាអាជីវករមិនមានទីកន្លែងលក់ ហើយចេញមុខតវ៉ាដល់អាជ្ញាធរខេត្ត រហូតដល់ផ្ទះសម្តេចហ៊ុន សែនដែលជាលទ្ធផលគឺទទួលបានដំបងឆក់ ។

លោកស្រីក៏បានបញ្ជាក់ផងដែរថា « *មូលហេតុដែលខ្ញុំមកឈរឈ្មោះ និងជាប់ឆ្នោតនៅឃុំត្បូងក្រពើនេះ ដោយសារតែខ្ញុំមានការតស៊ូដើម្បីប្រជាប្រិយភាពគឺ ខ្ញុំបានដើរសួរសុខទុក្ខប្រជាពលរដ្ឋតាមផ្ទះ បង្កើនទំនាក់ទំនងល្អក្នុងគោលបំណងសុំសន្លឹកឆ្នោតគាំទ្រ ហើយអ្វីដែលសំខាន់គឺថា ឃុំត្បូងក្រពើនេះ ជាស្រុកកំណើតរបស់ខ្ញុំ* » ។ អ្វីដែលភ្ញាក់ផ្អើលនោះគឺ នៅក្នុងឃុំត្បូងក្រពើនេះអាណត្តិទី១ គណបក្សសម រង្ស៊ី មិនទទួលបានសំលេងគាំទ្រទេ (ជាប់តែពីរគណបក្ស គឺគណបក្សប្រជាជនកម្ពុជា និង គណបក្សហ៊្វុនស៊ិនប៉ិច) ទើបតែអាណត្តិទី២ដែលលោកស្រីមកឈរឈ្មោះ មានការគាំទ្រពីអ្នកបោះឆ្នោតឈ្នះចំនួន១អាសនៈ ក្នុងតួនាទីជាជំទប់ទី២។

ការរើសអើងចំពោះលោកស្រីនៅឃុំត្បូងក្រពើនេះ គឺ អាជ្ញាធរធ្វើការបំភិតបំភ័យចំពោះប្រជាពលរដ្ឋណាដែលគាំទ្រលោកស្រី ដោយចោទថាពួកគណបក្សសមរង្ស៊ី និងលោកស្រីត្រូវបានគេមិនរាប់រកនៅពេលមានពិធីបុណ្យ ឬមង្គលការក្តី មិនមានការអញ្ជើញលោកស្រីឲ្យចូលរួមទេ។ ចំណែកឯរដ្ឋអំណាចវិញនៅពេលដែលឃើញមានប្រជាពលរដ្ឋណាចូលមកគាំទ្រខាងគណបក្សសមរង្ស៊ី គេលែងជួយដូចជាអំណោយ និងពេលមានការពឹងពាក់ម្តងម្កាលគេថាទៅឲ្យសមរង្ស៊ីជួយទៅ។

ក្នុងតួនាទីជាជំទប់ទី២មកពីគណបក្សសម រង្ស៊ី លោកស្រីទទួលនូវការរើសអើងគណបក្ស ដោយសារមេឃុំបុរសជាគណបក្សប្រជាជនកម្ពុជា ។ លោកស្រីបានបញ្ជាក់ថា ជាធម្មតាក្រុមប្រឹក្សាឃុំមានការប្រជុំប្រចាំខែជាទៀងទាត់ រួមជាមួយនឹងការប្រជុំគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គកនក)ដែលមានលោកស្រី និងស្ត្រីជាសមាជិកម្នាក់ទៀតមកពីគណបក្សប្រជាជនកម្ពុជាជាអ្នកទទួលបន្ទុក ក៏ប៉ុន្តែលោកស្រីផ្ទាល់មិនបានដឹងរឿងអ្វីទេ គឺគេបិទព័ត៌មានមិនឲ្យដឹង ជាក់ស្តែងគេធ្វើសកម្មភាពនៅកន្លែងណាៗ គឺគេមិនប្រាប់លោកស្រីឡើយ ។ លោកស្រីបញ្ជាក់ថា «*ធ្វើដូច្នោះគឺទីងមោងជាគ្នា ។ គ្មានបានការអីទេ គេផាត់ចោលហើយ*»។ លោកស្រីក៏បន្តទៀតថា **ចំពោះការតែងតាំងបានតែឈ្មោះ** «*ខ្ញុំត្រូវមេឃុំតែងតាំងជាអ្នកទទួលខុលត្រូវខាងមត្តេយ្យសហគមន៍ ។ ពេលទៅធ្វើមត្តេយ្យសហគមន៍ គេផ្សេងជាអ្នកទទួលខុសត្រូវ និងធ្វើសោះ ។ រឿងមួយទៀត លោកមេឃុំតែងតាំងខ្ញុំជាប្រធានសហគមន៍ ស្រូវ អង្ករពោត សណ្តែក ដល់ពេលទៅមើល ទៅធ្វើ គេផ្សេងជាប្រធានវិញ ហ្នឹងហើយបានថា មានសាលាថា តែ*

*សាលាធ្វើអត់មាន»*។ បន្ថែមលើនេះទៀត នៅពេលមានកិច្ចប្រជុំប្រចាំខែ មតិ យោបល់របស់លោកស្រីមិនត្រូវបានគេយកចិត្តទុកស្តាប់គឺគណបក្សប្រឆាំងដូចលោកស្រី គេឲ្យអំណាចតែ២០%ទេ។

ទាក់ទិននឹងបញ្ហាថវិកា ចំណូលចំណាយរបស់ឃុំ លោកស្រីថា គេមិនឲ្យដឹងទេ អ្វីដែលលោកស្រីដឹង គឺពេលដែលរួចរាល់ហើយ សូមឲ្យមានការព្រមព្រៀងចុះហត្ថលេខាតែប៉ុណ្ណោះ គឺមិនមានការឆ្លងយោបល់អ្វីឡើយ ។ រីឯ ថវិកាសំរាប់កិច្ចការស្ត្រី និងកុមារប្រចាំឆ្នាំ និងសំរាប់មួយអាណត្តិ លោកស្រីដឹងថា មានថវិកាឧបត្ថម្ភពីខាងយូនីសេហ្វ បាន១ឆ្នាំ ២ ០០០ដុល្លារអាមេរិក សម្រាប់កិច្ចការពារពិសេស កុមារជនរងគ្រោះ ឬ មានកុមារអេដ្វើស៊ី កើតជំងឺអេដស៍ កុមារអត់មានទីពឹង ចាស់អត់មានទីពឹង ស្ត្រីមានផ្ទៃពោះអត់មានថ្នាំព្យាបាល ចាស់ជរាអត់មានផ្ទះសំបែង ។ លោកស្រីបញ្ជាក់ថា ថវិកាទាំងនោះ យកទៅជួយអ្នកណា បាន ឬមិនបានលោកស្រីមិនបានដឹងទេ ដូចជាការដកថវិកាយកទៅប្រើប្រាស់ជាដើម ព្រោះថវិកានោះ ស្មៀនជាអ្នកកាន់ជាមួយមេឃុំ ហើយស្មៀនជាអ្នកធ្វើកិច្ចការនោះជាមួយជនរងគ្រោះផ្ទាល់ ។ លោកស្រីមានប្រសាសន៍ថា *«ការចាយថវិកាមិនមានតម្លាភាព រើសអើងបក្សពួកនិយម ចាយវាយរួចទើបរាយការណ៍តាមក្រោយ»* ។

ឧបសគ្គចំពោះលោកស្រីក្នុងពេលបំពេញការងារនៅក្រុមប្រឹក្សាឃុំគឺ ទី១ *គេគិតថាលោកស្រីជាស្ត្រីមិនអាចធ្វើអីកើត* ទី២ *គេថាលោកស្រីជាគណបក្សប្រឆាំង* ទី៣ *ការរើសអើងមិនចង់ឲ្យធ្វើកិច្ចការងារអ្វីៗ គឺចង់ឲ្យតែអង្គុយកៅអីគ្រប់គ្រប់ប្រជុំ កុំឲ្យគេមើលឃើញថា ឃុំនេះមានគណបក្សពីរ* ។ បញ្ហាទាំងនេះហើយ ធ្វើឲ្យលោកស្រីបាក់ទឹកចិត្ត មិនមានសតិអារម្មណ៍ធ្វើការ គឺចង់ដកខ្លួនទៅជាប្រជាពលរដ្ឋធម្មតាវិញ ។ ប៉ុន្តែដោយសារតែអាណិត ស្រឡាញ់គណបក្សសម រង្ស៊ីដែលតែងតែផ្តល់ឱកាសឲ្យលោកស្រីបានឈរឈ្មោះ និងជាប់ឆ្នោតជាជំទប់ទី២ និងចង់ប្រឡូកក្នុងកិច្ចការនយោបាយ ទើបលោកស្រីសម្រេចចិត្តធ្វើការបន្ត ។ ជាក់ស្តែង ពេលប្រជុំម្តងៗ លោកស្រីបានមានយោបល់ ឬមានសំណូមពរអី សមាជិកក្រុមប្រឹក្សាឃុំផ្សេងទៀតគ្រាន់តែស្តាប់ នៅស្ងៀមតែគេអត់ធ្វើតាម មិនដែលយកគំនិតរបស់លោកស្រីមកពិភាក្សាដេញដោល ឬពិចារណាអ្វីទេ ។ ជាមួយគ្នានេះដែរ ទាក់ទងនឹងផ្នែកសន្តិសុខក្នុងឃុំ លោកស្រីជាជំទប់ទី២ជាអ្នកទទួលបន្ទុកសណ្តាប់សាធារណ: និងកិច្ចការផ្សេងៗទៀត ប៉ុន្តែប្រធានក្រុមប្រឹក្សាឃុំមិនឲ្យលោកស្រីធ្វើទេ ។ ដូច្នេះ ក្នុងការរៀបចំប្រជាការពារភូមិ គេមិនអនុញ្ញាត និងមិនឲ្យលោកស្រីដឹងទេ ជាក់ស្តែង នៅពេលមានការអញ្ជើញមកដល់របស់គណៈប្រតិភូនានាលោកស្រីក៏អត់ដឹងជាមុន មិនឲ្យចូលរួមក្នុងគណ:កម្មការដោះស្រាយទំនាស់របស់ប្រជាពលរដ្ឋ ។ល។ និង។ល។

លោកស្រីបានធ្វើការប្តេជ្ញាចិត្តថា « *ក្នុងអាណត្តិនេះ ខ្ញុំនឹងខំប្រឹងប្រែងក្នុងវិស័យនយោបាយនេះឲ្យបានរីកចំរើនជាងមុន ហើយខ្ញុំយកការឈឺចាប់របស់ខ្ញុំនេះទុកមួយឡែកសិន ដើម្បីលើកស្ទួយស្ត្រីក្នុងឆាកនយោបាយ ។ ស្ត្រីយើងត្រូវងើបឈរឡើងដើម្បីប្រឆាំងនឹងការរើសអើង កុំបាក់ទឹកចិត្តទោះជួបឧបសគ្គក៏ដោយ យើងគាំទ្រគណបក្សដែលមានការគាំទ្រយើងឲ្យបានជាប់ឆ្នោត មានតួនាទីរហូតបានប៉ុណ្ណោះ* »។

លោកស្រីបានមានសំណូមពរដល់រដ្ឋាភិបាល សូមជួយស្ត្រីផង សូមជួយណែនាំដល់ភូមិ ឃុំ សង្កាត់ណាដែលមានស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់មកពីគណបក្សផ្សេងៗគ្នា ជាពិសេសស្ត្រីមកពីគណបក្សប្រឆាំង ដើម្បីផ្តល់ឱកាសឲ្យស្ត្រីមានលទ្ធភាពធ្វើការដោយពេញលេញ និងផ្តល់យុត្តិធម៌ដល់ស្ត្រីផង ពីព្រោះស្ត្រីបានជាប់ឆ្នោត ធ្វើការបំរើភូមិ ឃុំ សង្កាត់អត់មានប្រកាន់ ឬរើសអើងគណបក្សទេ គឺបម្រើប្រជាពលរដ្ឋខ្មែរតែមួយ ។

## III. ចំនួនស្ត្រីក្នុងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ (ស្ថិតិ និងតួនាទី)

ការកើនឡើងចំនួនស្ត្រីនៅថ្នាក់ធ្វើសេចក្តីសម្រេចនៅមានកម្រិត ខណៈដែលបុរសនៅតែមានចំនួនច្រើនលើសលុបក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត ។

### ១. ព្រឹទ្ធសភា

តំណាងស្ត្រីនៅក្នុងស្ថាប័នព្រឹទ្ធសភាមិនមានការប្រែប្រួលជាវិជ្ជមានទេ គិតចាប់ពីអាណត្តិទី១(ឆ្នាំ ១៩៩៩) អាណត្តិទី២ (ឆ្នាំ២០០៥) និងអាណត្តិទី៣ (ឆ្នាំ២០១២) គឺនៅតែមានចំនួនដដែល ៩នាក់ (១៤,៧៥%)នៃចំនួនសរុប ៦១នាក់ ។

### ២. រដ្ឋសភា

*តំណាងរាស្ត្រស្ត្រីមានការកើនឡើងច្រើនជាង៣ដងក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះ*

តំណាងរាស្ត្រស្ត្រី មានការកើនឡើងច្រើនជាង៣ដងក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះ គឺពី ៦%នៅនីតិកាលទី១ ឆ្នាំ១៩៩៣ ទៅ ២០,៣៣% នីតិកាលទី៥ ឆ្នាំ២០១៣ ដោយមានការកើនឡើងជាមធ្យម ៦,៨៤%សម្រាប់នីតិកាលនីមួយៗនៃរដ្ឋសភា។ ប៉ុន្តែសម្រាប់នីតិកាលទី៥ ចំនួនតំណាងរាស្ត្រស្ត្រីមានការថយចុះបន្តិច ០,៨១ (១%)បើធៀបនឹងចុងនីតិកាលទី៤ ស្មើនឹង២៦នាក់ ( ២១,១៤%)មកត្រឹម ២៥នាក់ (២០,៣៣%)នៅនីតិកាលទី៥ ឆ្នាំ២០១៣នៃអ្នកតំណាងរាស្ត្រសរុប១២៣នាក់។

ក្នុងចំណោមតំណាងរាស្ត្រស្ត្រីទាំង២៥នាក់ មានចំនួនតែ ១៨នាក់ (២០,៤៥%)ប៉ុណ្ណោះនៃចំនួនសរុបបុរស-ស្ត្រី៨៨នាក់ត្រូវបានដាក់បញ្ចូលទៅក្នុងគណៈកម្មការទាំង១០នៃរដ្ឋសភា នីតិកាលទី៥នេះ ក្នុងនោះមានតួនាទីជាប្រធាននៃគណៈកម្មការទី៨ និងទី៩ ចំនួន២នាក់ (២០%)នៃចំនួនសរុប១០នាក់ ។ តួនាទីជាអនុប្រធានចំនួន១នាក់(១០%)នៃចំនួនសរុប១០នាក់ និងមានចំនួនច្រើន ៦នាក់ (៦០%)នៃចំនួនសរុប១០នាក់មានតួនាទីជាលេខាធិការ ។

## ៣. រដ្ឋាភិបាល

*ចំនួនស្ត្រីក្នុងមុខតំណែងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ មានការកើនឡើងក្នុងឆ្នាំ២០១៣*

- ឧបនាយករដ្ឋមន្ត្រីស្ត្រីចំនួន**១នាក់ (១១,១១%)**ក្នុងចំណោម៩នាក់ ប៉ុន្តែមិនមានស្ត្រីក្នុងមុខតំណែងជាទេសរដ្ឋមន្ត្រី (សូន្យក្នុងចំណោមទេសរដ្ឋមន្ត្រីចំនួន១៥នាក់) ។
- រដ្ឋមន្ត្រីស្ត្រីចំនួន**៣នាក់ (១០,៣៤%)**ក្នុងចំណោម២៩នាក់ដែលមានការកើនឡើងពី ៧,១៤% (២នាក់)ក្នុងចំណោម២៨នាក់ ក្នុងឆ្នាំ២០០៨ ។
- មានការតែងតាំងស្ត្រីក្នុងតំណែងរដ្ឋលេខាធិការយ៉ាងតិចចំនួន១នាក់ និងអនុរដ្ឋលេខាធិការយ៉ាងតិចចំនួន ១នាក់នៅគ្រប់ក្រសួង ស្ថាប័ននីមួយៗ ។ ចំនួនរដ្ឋលេខាធិការស្ត្រីមានការកើនឡើង ១២,៤៦% (២២នាក់)ពី៨,០៨% (១៦នាក់)ក្នុងចំណោម១៩៨នាក់នៅឆ្នាំ២០០៨ ទៅ ២០,៥៤% (៣៨នាក់)ក្នុងចំណោម១៨៥នាក់ នៅឆ្នាំ២០១៣ ។ ចំណែកឯ ចំនួនស្ត្រីក្នុងតំណែងជាអនុរដ្ឋលេខាធិការមានការកើនឡើងប្រមាណ ២% (១៥នាក់) ពី ១៦,០៩% (៣៣នាក់)ក្នុងចំណោម២០៥នាក់ នៅឆ្នាំ២០០៨ ទៅ ១៧,៥៨% (៤៨នាក់)ក្នុងចំណោម២៧៣នាក់ នៅឆ្នាំ២០១៣ ។

## ៤. តុលាការ

*សមាមាត្រស្ត្រីក្នុងស្ថាប័នតុលាការមានការកើនឡើងចាប់ពីឆ្នាំ២០០៨ ប៉ុន្តែតំណែងស្ត្រីមានតិចក្នុងការគ្រប់គ្រងកម្រិតនៃស្ថាប័នតុលាការ*

- ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ចំនួនស្ត្រីមានការកើនឡើង ប៉ុន្តែបុរសនៅមានចំនួនច្រើនក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងស្ថាប័នតុលាការ។
- ក្នុងឆ្នាំ២០១៣ នៅស្ថាប័នតុលាការ មានចៅក្រមជាស្ត្រី ១៣,៩៦% (៣៧នាក់)ក្នុងចំណោម២៦៥នាក់ ដែលមានការកើនឡើងបន្តិចបន្តួចពី១៣,២០%ក្នុងឆ្នាំ២០១០។ ប្រទេសកម្ពុជាកំពុងឈាន

ទៅជិតសម្រេចបាននូវគោលដៅផែនការយុទ្ធសាស្ត្រនារីរតនៈទី៣ ដែលបានកំណត់ថា មានថៅក្រមជាស្ត្រីចំនួន ១៥%ក្នុងឆ្នាំ២០១៣។ ផ្ទុយទៅវិញ មិនមានតំណាងស្ត្រីជាប្រធានឡើយ ។

- ព្រះរាជអាជ្ញាជាស្ត្រីមាន១០,២០% (១៥នាក់) ក្នុងចំណោម១៤៧នាក់ ។ ដូចនេះ ចំនួនព្រះរាជអាជ្ញាជាស្ត្រីបានកើនឡើង៨% ចាប់ពីឆ្នាំ២០១០មក។
- ក្នុងចំណោមសមាជិកគណៈមេធាវី និងសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ សរុបចំនួន ២៧នាក់ (អាណត្តិឆ្នាំ២០១២-២០១៥) ។
- ក្នុងរយៈពេល៣ឆ្នាំកន្លងទៅចំនួនស្ត្រីដែលប្រកបវិជ្ជាជីវៈមេធាវីមានការថយចុះពី១៨% (៩៨នាក់) ក្នុងចំណោម៥៥១នាក់ នៅឆ្នាំ២០១០ មក ១៧,៦០% (១២៦នាក់)ក្នុងចំណោម៧១៦នាក់ នៅឆ្នាំ២០១៣ ។

## ៥. ថ្នាក់ក្រោមជាតិ

> *បុរសមានចំនួនច្រើនក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅតាមរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ*

- បច្ចុប្បន្ននេះ មិនទាន់មានស្ត្រីជាអភិបាលរាជធានី ខេត្ត នៅឡើយ
- អភិបាលរងរាជធានី ខេត្តជាស្ត្រីមានការកើនឡើង១៤,២៨% (២៤នាក់)ក្នុងចំណោម១៦៨នាក់
- ស្ត្រីជាអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួន ១,០៣% (២នាក់) ក្នុងចំណោម១៩៤នាក់
- ស្ត្រីជាអភិបាលរងក្រុង ស្រុក ខណ្ឌ ចំនួន ២៥% (១៩៤នាក់)ក្នុងចំណោម៧៧៦នាក់ នៅឆ្នាំ ២០១៣
- ស្ត្រីជាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានការកើនឡើងតិចតួច ចំនួន **១៣,៧៧% (៤៥៨នាក់)**ក្នុងចំណោម**៣៣២៤នាក់** សម្រាប់អាណត្តិទី២ ឆ្នាំ២០១៤ ក្នុងនោះក្រុមប្រឹក្សារាជធានីខេត្តជាស្ត្រី មានចំនួន ១៣,២៣% (៥២នាក់)ក្នុងចំណោម៣៩៣នាក់ បើធៀបនឹងអាណត្តិទី១(ឆ្នាំ២០០៩)មានចំនួនតែ ១០,១៦% (៣៨នាក់)ក្នុងចំណោម៣៧៤នាក់ ។ ចំណែកឯ ស្ត្រីជាក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានការកើនឡើងតិចតួចដែរ ១៣,៨៥% (៤០៦នាក់)ក្នុងចំណោម២៩៣១នាក់ សម្រាប់អាណត្តិទី២ ឆ្នាំ២០១៤ បើធៀបនឹងអាណត្តិទី១ ឆ្នាំ២០០៩ ស្ត្រីមាន ១២,៦៨% (៣៦៣នាក់)ក្នុងចំណោម២៨៦១នាក់ ។

## ៦. ក្រុមប្រឹក្សាឃុំ សង្កាត់

*ចំនួនបុរសច្រើនលើសលុប មានមុខតំណែងសំខាន់ៗ ក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅថ្នាក់ឃុំ សង្កាត់*

- ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី មានចំនួនតែ ២០៣៨នាក់ស្មើនឹង ១៧,៧៨%ក្នុងចំណោម១១ ៤៥៩ នាក់ នៅឆ្នាំ២០១៤
- ស្ត្រីនៅតែមានតំណាងតិចក្នុងមុខតំណែងធ្វើសេចក្តីសម្រេចសំខាន់ៗ ដូចជាមេឃុំ ចៅសង្កាត់ មាន ៥,៨១% (៩៥នាក់) ស្ត្រីជាជំទប់ទី១ មាន១១,៥៧% (១៨៩នាក់) និងជំទប់ទី២ មាន ១០,០៤% (១៦៤នាក់) ។

## IV. សេចក្តីសន្និដ្ឋាន និងសង្ខេប

**តំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិក្នុងកិច្ចប្រជុំពេញអង្គ**នៃរដ្ឋសភា មានចំនួនតិចជាងអ្នកតំណាងរាស្ត្របុរស ប៉ុន្តែអ្នកតំណាងរាស្ត្រស្ត្រីបានចុះមូលដ្ឋានច្រើនជាងអ្នកតំណាងរាស្ត្របុរស ។

ក្នុងឆ្នាំទី១ នីតិកាលទី៥នៃរដ្ឋសភានេះ ***បញ្ហាស្ត្រី និងកុមារ*** មិនត្រូវបានលើកយកមកដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំពេញអង្គរបស់សភាទេ ។ រាល់កិច្ចពិភាក្សាពុំបានឆ្លុះបញ្ចាំងពីផលប្រយោជន៍ និងផលប៉ះពាល់ដល់ស្ត្រី និងកុមារទេ រួមទាំងអ្នកតំណាងរាស្ត្រស្ត្រី ទាំងបុរសផងដែរ ។ លើសពីនេះទៀតពួកគាត់ក៏មិនបានលើកឡើងអំពីស្ត្រី និងកុមារដែលបាន និងកំពុងរងគ្រោះនូវគ្រប់ទម្រង់នៃការរើសអើងការរំលោភបំពានជារៀងរាល់ថ្ងៃ ជាពិសេសកើតចេញពីផែនការអភិវឌ្ឍន៍ បើទោះបីជាគណបក្សជាប់ឆ្នោតទាំងពីរបានសន្យាថា នឹងដោះស្រាយបញ្ហាស្ត្រី និងកុមារនៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក៏ដោយ ។ នេះបង្ហាញឲ្យឃើញថា ការដោះស្រាយបញ្ហាស្ត្រី និងកុមារ ពុំបានស្ថិតនៅក្នុងការចាប់អារម្មណ៍របស់អ្នកតំណាងរាស្ត្រឡើយ ហើយក៏ជាប្រធានបទដែលស្ថិតក្នុងការតម្កល់ទុកលើធ្នើចោលផងដែរ ។

**ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្ម** ច្រើនជាងភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម គឺ ៨៤% ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី២១នាក់ ក្នុងចំណោមសមាជិកសភាស្ត្រី២៥នាក់ ខ្ពស់ជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសដែលមានចំនួនតែ ៧៦,៥៣% ស្មើនឹង៧៥នាក់ ក្នុងចំណោមសមាជិកសភាបុរស៩៨នាក់ ។ នេះបង្ហាញឲ្យឃើញថា សមាជិកសភាស្ត្រីគឺមានភាពសកម្មក្នុងការចុះមូលដ្ឋានជាងសមាជិកសភាបុរស ។

ដោយធ្វើការ**ប្រៀបធៀបនៅក្នុងគណបក្ស** ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាបានចុះបេសកកម្មមានចំនួន ៨៣,៣៣% (១៥នាក់ក្នុងចំណោម១៨នាក់) ច្រើនជាងភាគរយរបស់អ្នកតំណាងរាស្ត្រប្រុសនៃគណបក្សរបស់ខ្លួនដែលមានចំនួនតែ៧០% (៣៥នាក់ក្នុងចំណោម៥០នាក់) ប៉ុណ្ណោះ ។ ដូចគ្នាផងដែរ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិក៏មានចំនួនច្រើនជាងភាគរយរបស់អ្នកតំណាងរាស្ត្រប្រុសនៃគណបក្សរបស់ខ្លួនដែលបានចុះបេសកកម្ម គឺ ភាគរយស្ត្រីស្មើនឹង ៨៥,៧១% (៦នាក់ ក្នុងចំណោម៧នាក់) និងភាគរយប្រុសមានចំនួនតែ៨៣,៣៣% (៤០នាក់ ក្នុងចំណោម ៤៨នាក់) ។

**គោលបំណងនៃការចុះបេសកកម្ម**របស់អ្នកតំណាងរាស្ត្រស្ត្រី បង្ហាញឲ្យឃើញថា មានការខុសគ្នាឆ្ងាយរវាងតួលេខនៃការចុះ*សំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលមានចំនួន១២២លើក (៥១,២៦%) ជាមួយនឹងចំនួន ១២លើក (៥,០៤%)នៃការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ ខណៈដែលសកម្មភាពគ្រាន់តែអមដំណើរអ្នកដឹកនាំសោះ មានចំនួនរហូតដល់ទៅ៧២លើក (៣០,២៥%) ។*

**សកម្មភាពតំណាងរាស្ត្រស្ត្រីនៅថ្នាក់ជាតិ និងតាមមណ្ឌល**នៅអាណត្តិទី៥នេះ មានភាពសកម្មគួរឲ្យកត់សម្គាល់ទាំងតំណាងរាស្ត្រមកពីគណបក្សប្រឆាំង និងគណបក្សកាន់អំណាច ជាពិសេសការចេញមកទទួលញត្តិពីក្រុមបាតុករដែលទាមទារដោះស្រាយបញ្ហារបស់ពួកគេ ការចូលរួមវេទិកានានា និងការចុះទៅផ្ទាល់តំបន់ដែលមានបញ្ហាដើម្បីដោះស្រាយជូនប្រជាពលរដ្ឋ ដែលទង្វើទាំងនេះកម្រនឹងឃើញពីមុនណាស់ ជាពិសេសតំណាងរាស្ត្រស្ត្រីរបស់គណបក្សប្រជាជនកម្ពុជា។

សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រី បានបង្ហាញឲ្យឃើញពីការផ្លាស់ប្តូរឥរិយាបថក្នុងតួនាទីជាតំណាងរាស្ត្រ ដូចជា បានពាំនាំយកសំណូមពរ បញ្ហារបស់ប្រជាពលរដ្ឋយកមកពិភាក្សា ដោះស្រាយជាមួយអ្នកពាក់ព័ន្ធ បើទោះបីជាពុំទាន់ចេញលទ្ធផលជាក់ស្តែងនៅឡើយក៏ដោយ ។ ដោយឡែក អំណាច និងឥទ្ធិពលរបស់តំណាងរាស្ត្រស្ត្រីនៅមានកម្រិត ដោយសារពួកគាត់ស្ថិតក្រោមនៅក្រោមខ្សែបន្ទាត់គណបក្សនយោបាយ។ ទោះបីជាយ៉ាងណាក៏ដោយ សកម្មភាពរបស់ពួកគាត់បានលើកទឹកចិត្តដល់ស្ត្រី ជនក្រីក្រ ជនរងគ្រោះក្នុងការតស៊ូដោយសន្តិវិធីដើម្បីដោះស្រាយបញ្ហា និងផ្តល់ជាគំរូដល់ស្ត្រីផ្សេងទៀត រួមទាំងស្ត្រីវ័យក្មេងអំពីភាពសកម្ម ភាពក្លាហានមោះមុត ការលះបង់ និងការតស៊ូនឹងបញ្ហាប្រឈមនានា ។

នៅក្នុង**ការអនុវត្តនារីរតនៈទី៣** (២០០៩-២០១៣) រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធនានាទទួលបានជោគជ័យគួរជាទីកត់សម្គាល់ក្នុងការចូលរួមចំណែកលើកកម្ពស់គោលនយោបាយ ច្បាប់ និងកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យឆ្លើយតបនឹងយេនឌ័រ ទន្ទឹមនឹងនេះក៏នៅមានបញ្ហាប្រឈមជាច្រើនក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅប្រទេសកម្ពុជាដែលចាំបាច់ត្រូវដោះស្រាយជាបន្ទាន់ ។

ការចូលរួមរបស់ស្ត្រីនៅក្នុង**វិស័យនយោបាយ និងការធ្វើសេចក្ដីសម្រេច**តម្រូវឲ្យមានការកែលំអបន្ថែមទៀត ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

មាន**ពីរករណីនៃសមាជិកសភាស្ត្រី** គឺ **លោកជំទាវ ឃួន សុដារី** ត្រូវបានដកចេញពីតំណែង និង **លោកជំទាវ មួរ សុខហួរ** មិនបោះឆ្នោតគាំទ្រធ្វើជាប្រធានគណៈកម្មការនៃរដ្ឋសភា ។

រាល់ការសម្រេចចិត្តតែងតែស្ថិតនៅក្នុងកណ្ដាប់ដៃបុរស ដែលបង្កប់ទៅដោយអាកប្បកិរិយារើសអើងចំពោះស្ត្រី ហើយទីបំផុតស្ត្រីនៅតែជាជនរងគ្រោះ។ នេះក៏ព្រោះតែបុរសមិនមានការយល់ដឹងយេនឌ័រ (Gender Sensitive) និងខ្វះឆន្ទៈនយោបាយក្នុងការលើកស្ទួយ និងអនុវត្ត**អនុសញ្ញាអន្តរជាតិស៊ី-ដ** ស្ដីពី *ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* ដែលកម្ពុជាជាប្រទេសហត្ថលេខី និងគោលនយោបាយរបស់រដ្ឋាភិបាល ។ អនុសញ្ញានេះទាមទារឲ្យមានជាវិធានការពិសេសក្នុងការលើកស្ទួយដល់ការចូលរួមរបស់ស្ត្រីនៅគ្រប់លំដាប់ថ្នាក់ ។

**ស្ត្រីមានឱកាសតិចតួច**ក្នុងការទទួលបានតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬជាមេឃុំ ចៅសង្កាត់ ។ ដូចនេះ សម្រាប់ការបោះឆ្នោតជ្រើសរើសអាណត្តិក្រោយ ឆ្នាំ២០១៧ ត្រូវការចាំបាច់ណាស់គ្រប់គណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងត្រូវដាក់បេក្ខជនស្ត្រី និងបុរសឈរឈ្មោះឆ្លាស់គ្នាតាមលំដាប់លេខរៀងពីលើដល់ក្រោម៥០/៥០ ដើម្បីធានាឲ្យមានសមភាពយេនឌ័រក្នុងភាពជាតំណាងអ្នកបោះឆ្នោត ។ ការបង្កើនចំនួនស្ត្រីជាថ្នាក់ដឹកនាំ និងថ្នាក់ធ្វើសេចក្ដីសម្រេច គឺជាផ្នែកមួយដ៏សំខាន់ក្នុងការអនុវត្តតាម អនុសញ្ញាស៊ី-ដ, ផែនការសកម្មភាពទីក្រុងប៉េកាំង [Beijing Platform for Action (BPfA)] និងស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ចាប់ផ្ដើមប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន** មានភាពជឿជាក់លើខ្លួនឯង និងក្លាហានក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំនានា បើទោះបីជួបនូវឧបសគ្គខ្លះៗក៏ដោយ ។ កិច្ចការ និងមតិយោបល់របស់ស្ត្រីភាគច្រើនផ្ដោតលើផលប្រយោជន៍ស្ត្រី និងកុមារជាសំខាន់ ខណៈដែលបុរសភាគច្រើនរួមទាំងផ្នត់គំនិតសង្គម មានការប្ដូរឥរិយាបថមកឲ្យតម្លៃស្ត្រី យល់ថាការចូលរួមរបស់ស្ត្រីពិតជាមានសារៈសំខាន់ ជាពិសេសការចូលរួមនៅថ្នាក់សម្រេចចិត្តជាមួយនឹងការគាំទ្រយ៉ាងពេញទំហឹងពីក្រុមគ្រួសារ និងប្រជាពលរដ្ឋ ដែលជាកំលាំងចលករក្នុងការជម្រុញ លើកទឹកចិត្តយ៉ាងខ្លាំងដល់ការចូលរួមរបស់ស្ត្រីឲ្យមានភាពកាន់តែសកម្មថែមមួយកម្រិតទៀត ។ លើសពីនេះ បញ្ហាស្ត្រី និងកុមារក៏ត្រូវបានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងបុរស ទាំងស្ត្រីចាត់ជាបញ្ហាចម្បង និងត្រូវយកចិត្តទុកដាក់ដោះស្រាយជាបន្តបន្ទាប់ ។

**ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់**មួយចំនួននៅតែបន្តមាននៅឡើយដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ដោះស្រាយជាចាំបាច់ ។

**ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ**នៅមានការលំបាកក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវការនៃការងារ ព្រមទាំងតម្លាភាពថវិកាក៏នៅមានកម្រិត ។

## V. អនុសាសន៍

ដើម្បីអនុវត្តកំណែទម្រង់រដ្ឋសភា ដែលព្រមព្រៀងដោយគណបក្សទាំងពីរថា ធានាឲ្យដំណើររដ្ឋសភាមានប្រសិទ្ធភាព និងតម្លាភាព ស្របតាមគោលការណ៍ប្រជាធិបតេយ្យ សេរី ពហុបក្ស ស្របតាមអនុសញ្ញាស៊ី-ដ និងរបបសភានិយមនៅកម្ពុជា អនុសាសន៍សំខាន់ៗចូលរួមលើការធ្វើវិសោធនកម្មកែប្រែ ឬការបន្ថែមខ្លឹមសារមាត្រាច្បាប់រដ្ឋធម្មនុញ្ញ និងប្រការបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងមាត្រា១២០ថ្មីនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា៩៩ថ្មីនៃច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដូចខាងក្រោម៖

### រដ្ឋសភា

◇ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ត្រូវចែងអំពីការបែងចែកអំណាចដឹកនាំរដ្ឋសភាសមាមាត្រ ក្នុងចំណោមគណបក្សមានអាសនៈក្នុងរដ្ឋសភារវាងគណបក្សប្រឆាំង និងគណបក្សកាន់អំណាច ខណៈដែលបញ្ចូលសមាសភាពបុរស និងស្ត្រី ដូចរូបមន្តកិច្ចព្រមព្រៀងដំណោះស្រាយនយោបាយ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។ (ប្រការ ០២ថ្មី (ពីរ) និង ១០ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)។

◇ គួរមានប្រធានគណៈកម្មការជំនាញជាស្ត្រីយ៉ាងហោច ៤០%នៃគណៈកម្មការទាំង១០របស់រដ្ឋសភា ។

◇ តំណែង តួនាទីរបស់តំណាងរាស្ត្រស្ត្រីនៅក្នុងរដ្ឋសភា ទាំងថ្នាក់កំពូល និងគណៈកម្មការជំនាញត្រូវមានការរក្សា ការពារឲ្យបាននូវចំនួនស្ត្រីជាអតិបរមា ។ ក្នុងករណីមានការដោះដូរ ឬលាលែងពីតំណែងណាមួយ ត្រូវដាក់ជំនួសតំណែងនោះដោយបេក្ខភាពស្ត្រី ។

◇ សមាជិករដ្ឋសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ដោយសារសាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា ហើយបញ្ជាក់ពីមូលហេតុ និងផ្សព្វផ្សាយជាសាធារណៈ។ សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ដែលមានការសម្រេចជាលាយលក្ខណ៍អក្សរ តែមិនមែនមូលហេតុដោយសារការបញ្ចេញមតិខុសឆ្គង។ (មាត្រា ១២០ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ)

◇ គណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការជំនាញនីមួយៗនៃរដ្ឋសភាត្រូវកំណត់ពេល ០១ (មួយ)ថ្ងៃក្នុង០១(មួយ)សប្តាហ៍ ដើម្បីធ្វើសវនាការសាធារណៈ ជជែកដេញដោល ដោយកោះហៅជនពាក់ព័ន្ធមកបំភ្លឺលើសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ និងការអនុវត្តច្បាប់ជាធរមាន។ គណៈ

កម្មាធិការអចិន្ត្រៃយ៍មានអំណាចទទួលពិនិត្យបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។ (ប្រការថ្មីបន្ថែមក្នុងជំពូក៣នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)

◇ រដ្ឋសភាត្រូវមានយន្តការដោះស្រាយបន្ទាន់លើការពិភាក្សាប្រធានបទ ស្តីពី បញ្ហាស្ត្រី និងកុមារ ស្របតាមកម្មវិធីនយោបាយរបស់គណបក្សជាប់ឆ្នោតទាំងពីរ ដែលជាការសន្យាអាទិភាពក្នុងចំណោមការសន្យាផ្សេងទៀត ព្រមទាំងអនុលោមតាមរដ្ឋធម្មនុញ្ញ និងអនុសញ្ញាស៊ីដ ។

◇ រដ្ឋសភាគួរផ្សព្វផ្សាយរបាយការណ៍ប្រចាំខែ និងប្រចាំត្រីមាសពីសកម្មភាពរបស់អ្នកតំណាងរាស្ត្រទាក់ទងនឹងការដោះស្រាយ ឬអន្តរាគមន៍ទៅលើបញ្ហាស្ត្រី និងកុមារ ។

## ក្រុមប្រឹក្សាឃុំ សង្កាត់

◇ រាជរដ្ឋាភិបាលគួរតែរៀបចំឲ្យមានកញ្ចប់ថវិកាដោយឡែកសម្រាប់កិច្ចការស្ត្រី និងកុមារ និងត្រូវមានតុល្យភាពនឹងតម្រូវការជាក់ស្តែង ។ កញ្ចប់ថវិកានេះត្រូវឲ្យទៅគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារដោយផ្ទាល់ ទាន់ពេលវេលា និងជាទៀងទាត់ ។

◇ រាជរដ្ឋាភិបាល តាមរយៈក្រសួងមហាផ្ទៃ គួរតែពង្រឹងយន្តការនៃការប្រើប្រាស់ថវិកាឲ្យមានតម្លាភាពនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ជាពិសេស គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ ។

◇ ត្រូវបង្កើនសមត្ថភាពដល់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ជាពិសេសស្ត្រីនៅឃុំដាច់ស្រយាលពីស្ថាប័ន និងអ្នកពាក់ព័ន្ធមួយចំនួន តាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលានានា ។

◇ គួរផ្តល់ឱកាសដល់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើទស្សនៈកិច្ចសិក្សានៅតំបន់ផ្សេងៗក្រៅពីខេត្តរបស់ខ្លួន ប្រយោជន៍រៀនសូត្រ និងចែករំលែកនូវបទពិសោធន៍ល្អៗពីគ្នាទៅវិញទៅមក។

◇ ត្រូវបង្កើនចំនួនស្ត្រីក្នុងតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬជាមេឃុំ ចៅសង្កាត់ និងសមាជិកស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ឲ្យបានច្រើន តាមរយៈការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជំពូកទី៧ មាត្រា ៩៩ថ្មី ដោយដាក់បេក្ខជនឈរឈ្មោះតាមលំដាប់លេខរៀង និងឆ្លាស់គ្នារវាងស្ត្រី និងបុរសពីលើដល់ក្រោម ដើម្បីធានាឲ្យមានសមភាពយេនឌ័រស្របតាមអនុសញ្ញាស៊ីដ, ផែនការសកម្មភាពទីក្រុងប៉េកាំង [Beijing Platform for Action (BPfA)] និងស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

# ផ្នែក
# ឧបសម្ព័ន្ធ

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
Committee for Free and Fair Elections in Cambodia (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កម្ពុជា
Central Office : #138, Street 122, Teuk Laak I, Toul Kork, Phnom Penh, Cambodia
P.O. Box 1145, Tel : (855)23-884-150 / 12-942-019, Fax : (855)23-883-750,
Email : comfrel@online.com.kh, comfrel@comfrel.org website : www.comfrel.org
ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

1.លោក ធន សារាយ
Mr. THUN Saray
ប្រធានគណៈកម្មាធិការនាយក និងជាប្រធាន ADHOC

2.លោក សុខ សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក និងជានាយកប្រតិបត្តិ CDP

3. លោក យង់ គីមអេង
Mr. YONG Kim Eng
អគ្គនាយក-នាយកប្រតិបត្តិ PDP-Center

4. លោក យឹម ពៅ
Mr. YIM Po នាយករង CPDEW

5.លោកស្រី ស៊ុន ចាន់សែន
Ms. SUN Chansen
ឥស្សរជន-Dignitary

6. លោក ម៉ាក់ ចំរើន
Mr. MAK Chamroeun
ប្រធាន KYA

7. លោកស្រី ប៉ុក បញ្ញាវិចិត្រ
Ms. POK Panhavichetr
នាយិកាប្រតិបត្តិ CWCC

8.លោក មុំ សារិន
Mr. MOM Sarin
នាយកប្រតិបត្តិ HRCDO

9.លោក គីម សុវណ្ណ
Mr. KIM Sovann
នាយកប្រតិបត្តិ VIGILANCE

10.លោក សេន សេត
Mr. SEN Set, Dignitary

11.លោក ជាង សុខា
Mr. CHEANG Sokha
នាយកប្រតិបត្តិ YRDP

ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

**គណៈកម្មាធិការខុមហ្វ្រែល** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក លោកស្រី អ្នកនាងកញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ និងអន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបថា គណៈកម្មាធិការខុមហ្វ្រែល នឹងរៀបចំកិច្ចពិភាក្សាតុមូល ស្តីពី **"ការដាក់បេក្ខជនស្ត្រីឈរឈ្មោះអោយបាន៥០% សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ អាណត្តិទី២ ឆ្នាំ២០១៤"** នៅក្នុងខេត្តគោលដៅចំនួន ៥ គឺ៖ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តកំពង់ធំ និងខេត្តព្រះវិហារ។

## គោលបំណង

- បង្កើនចំនួនស្ត្រីជាក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី២។
- បញ្ចុះបញ្ចូលដល់គណបក្សនយោបាយ ដាក់បេក្ខជនស្ត្រីឈរឈ្មោះអោយបាន៥០%សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ អាណត្តិទី២ ឆ្នាំ២០១៤ ។

## កាលបរិច្ឆេទ និងទីកន្លែង

| ល.រ | ខេត្ត/ក្រុង | កាលបរិច្ឆេទ | ទីកន្លែង | ឈ្មោះទំនាក់ទំនង | លេខទូរសព្ទ |
|---|---|---|---|---|---|
| ១ | **តាកែវ** | ១២ កុម្ភៈ ២០១៤ | ភូមិផ្សារតាកោ សង្កាត់រកាក្នុង ក្រុងដូនកែវ | លោកស្រី សេង សុន្ទរី | ០១២ ៨៩២ ៤៨៦ |
| ២ | **ព្រះវិហារ** | ១៤ កុម្ភៈ ២០១៤ | ភូមិអណ្តូងពោធិ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ | លោកស្រី លន់ ស៊ីថាន់ | ០១២ ៨៩១ ៦២៧ |
| ៣ | **កំពង់ចាម** | ១៧ កុម្ភៈ ២០១៤ | សង្កាត់វាលវង់ ក្នុងកំពង់ចាម | លោក ញ៉ឹក សុភី | ០១២ ៦៧៣ ៨៥៧<br>០១១ ៥៤៩ ២៧៩ |
| ៤ | **កំពង់ធំ** | ១៧ កុម្ភៈ ២០១៤ | ភូមិកំពង់ធំ សង្កាត់កំពង់ធំ ក្រុងស្ទឹងសែន | លោកស្រី វ៉ែន ម៉ាឌីណា | ០៩៧ ៧២៧៧ ៣២៣ |
| ៥ | **កំពង់ឆ្នាំង** | ១៨ កុម្ភៈ ២០១៤ | ភូមិកណ្តាល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង | លោក លាភ ប៊ុនលាង | ០១២ ៣៤២ ៤១៧<br>០៨១ ៩៣៩ ៦១៦ |

*សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់!*

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញដល់លោក លោកស្រី នាងកញ្ញាតំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ចូលរួមយកព័ត៌មានតាមការគួរ។

***សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖***

**១**. លោកស្រី **សឹនកេត សិរីលក្ខណ៍** អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រខុមហ្វ្រែល
ទូរសព្ទ: **០១៧ ៤៩ ៤០ ០៤**
**២**. លោក **នាង សុវណ្ណ** មន្ត្រីអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល
ទូរសព្ទ: **០១២ ៩៧៧ ២៣១**

**<u>បេសកកម្ម</u>** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្ត ប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
Committee for Free and Fair Elections in Cambodia (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កម្ពុជា
Central Office : #138, Street 122, Teuk Laak I, Toul Kork, Phnom Penh, Cambodia
P.O. Box 1145, Tel : (855)23-884-150 / 12-942-019, Fax : (855)23-883-750,
Email : comfrel@online.com.kh, comfrel@comfrel.org website : www.comfrel.org

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

1.លោក ធុន សារាយ
Mr. THUN Saray
ប្រធានគណៈកម្មាធិការនាយក និងជាប្រធាន ADHOC

2.លោក សុខ សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក និងជានាយកប្រតិបត្តិ CDP

3. លោក យង់ គិមអេង
Mr. YONG Kim Eng
អគ្គនាយក-នាយកប្រតិបត្តិ PDP-Center

4. លោក យឹម ប៉ូ
Mr. YIM Po នាយកនៃ CPDEW

5.លោកស្រី ស៊ុន ចាន់សែន
Ms. SUN Chansen
កិត្តិយស-Dignitary

6. លោក ម៉ក់ ចំរើន
Mr. MAK Chamroeun
ប្រធាន KYA

7. លោកស្រី ប៉ុក បញ្ញាវិចិត្រ
Ms. POK Panhavichetr
នាយិកាប្រតិបត្តិ CWCC

8.លោក មុំ សារិន
Mr. MOM Sarin
នាយកប្រតិបត្តិ HRCDO

9.លោក គីម សុវណ្ណ
Mr. KIM Sovann
នាយកប្រតិបត្តិ VIGILANCE

10.លោក សេន សែត
Mr. SEN Set, Dignitary

11.លោក ជាង សុខា
Mr. CHEANG Sokha
នាយកប្រតិបត្តិ YRDP

ភ្នំពេញថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន
# អត្ថបទ ស្តីពី
# ការរំលោភលើសិទ្ធិសំដែងមតិ និងនយោបាយរបស់ស្ត្រី

ក្រោយពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ សកម្មភាពរបស់រដ្ឋាភិបាល អាជ្ញាធរ កងកំលាំងប្រដាប់អាវុធ និងកងសន្តិសុខមិនផ្លូវការរាពាំងជាច្រើនសារដោយបង្កប្ញសម្ពាម ជេរប្រមាថមើលងាយ បៀតបៀនកេរ្តិ៍ខ្មាស់ បំភិតបំភ័យ បំបាក់ស្មារតី និងរហូតដល់មានការស្លាប់ បាត់បង់ជីវិតក៏មានទៅលើស្ត្រីដែលជាអ្នកនយោបាយ បេក្ខជនតំណាងរាស្ត្រជាប់ឆ្នោត សកម្មជនអង្គការសង្គមស៊ីវិល សកម្មជនការពារដីធ្លី កម្មការិនីដែលប្រមូលផ្តុំបញ្ចេញមតិ និងធ្វើកូតកម្មដោយសន្តិភាព។

សកម្មភាពរបស់រដ្ឋាភិបាល និងអាជ្ញាធរបានប្រព្រឹត្តិល្មើសយ៉ាងធ្ងន់ធ្ងរចំពោះអនុសញ្ញាស៊ី-ដ ***«ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ»*** មាត្រា៣ចែងថា *«ក្នុងគ្រប់វិស័យ ជាពិសេស វិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចំរើនពេញលេញរបស់ស្ត្រី ដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដោយសមភាពជាមួយបុរស»* និងមាត្រា ១៤ ចំណុច (ឆ) ចែងថា *«............និងការគិតគូរស្មើគ្នាក្នុងការកែទម្រង់ដីធ្លី និងកសិកម្ម ព្រមទាំងក្នុងគំរោងបែងចែកដីធ្លី»* និងចំណុច(ជ) ចែងថា *«អាស្រ័យផលលក្ខខណ្ឌរស់នៅគ្រប់គ្រាន់ ជាពិសេសទាក់ទងនឹងការមានផ្ទះសម្បែង អនាម័យ ការផ្គត់ផ្គង់អគ្គិសនី និងទឹក ការដឹកជញ្ជូន និងគមនាគមន៍»* ។ ទង្វើរខាងលើនេះ ក៏ជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលការពារសិទ្ធិធ្វើកូតកម្ម និងបាតុកម្ម មានចែងក្នុងមាត្រា ៣៧ *«សិទ្ធិធ្វើកូតកម្ម និងធ្វើបាតុកម្មដោយសន្តិវិធីត្រូវ យកមកអនុវត្តនៅក្នុងក្របខណ្ឌនៃច្បាប់»* និងបានការពារសិទ្ធិសេរីភាពបញ្ចេញមតិដែលមានចែងក្នុងមាត្រា៤១ *«ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។...»* ។ បន្ថែមលើនេះទៀត វាក៏ជាការរំលោភបំពានយ៉ាងខ្លាំងចំពោះកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៩ កថាខណ្ឌ២ ចែងថា *«ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាព ស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ ឬបោះពុម្ព តាមទំរង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តីតាមការជ្រើសរើសរបស់ខ្លួន»* ខណៈពេលដែលព្រះមហាក្សត្រ និងរដ្ឋាភិបាលកម្ពុជាមិនដែលបានប្រកាសអាសន្នជាផ្លូវការ ហើយដែលនាយករដ្ឋមន្ត្រីក៏បានមានប្រសាសន៍ថា ប្រទេសកម្ពុជាស្ថាប័នរដ្ឋមានដំណើរការជាធម្មតា។

ជាក់ស្តែងអំពើហឹង្សាទាំងនេះបានប្រព្រឹត្តិលើស្ត្រីដូចជា៖

លោកជំទាវ **មូរ សុខហួរ** ជាស្ត្រីដែលលេចធ្លោក្នុងវិស័យនយោបាយ និងជាបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រមកពីគណបក្សសង្គ្រោះជាតិ នាពេលអំឡុងពេលថ្មីៗនេះ ដែលបានតស៊ូចូលទៅកាន់ ទីលានប្រជាធិបតេយ្យជាច្រើនលើកច្រើនសារ ដើម្បីសំដែងយោបល់ និងបញ្ចេញមតិក្នុងនាមជាតំណាងប្រជាពលរដ្ឋ កម្មករ-កម្មការិនីដែលទាមទារការដំឡើងប្រាក់ខែគោល។ លោកជំទាវត្រូវបានកងកម្លាំងសន្តិសុខខណ្ឌដូនពេញ

រុញច្រានទាំងប្រើសំដីអសុរសប្រមាថមើលងាយ និងចាប់សែងទីណាត់ទីណែងចេញពីទីលានប្រជាធិបតេយ្យ ហើយថែមទាំងវាយដំជំនួយការរបស់លោកជំទាវ និងអ្នកសារព័ត៌មានប្រមាណជិត១០នាក់ ក្នុងនោះរបួសធ្ងន់ ៣នាក់ទៀតផង។

បើដូចការពន្យល់របស់រដ្ឋាភិបាល និងសភានៃគណបក្សប្រជាជនកម្ពុជា បានអះអាងពីភាពស្របច្បាប់របស់រដ្ឋសភា។ ក្នុងន័យនេះ លោកជំទាវ **មួរ សុខហួរ** ត្រូវបានចាត់ទុកជាតំណាងរាស្ត្រនៃសភាជាតិនីតិកាលទី៥។ ហេតុដូចនេះ លោកជំទាវត្រូវទទួលបានអភ័យឯកសិទ្ធិដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ មាត្រា ៨០ *«តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។ តំណាងរាស្ត្របណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនឡើយ។....»* និងច្បាប់វិសោធនកម្មនៃបទបញ្ញាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ប្រការ ៤ថ្មី ចែងថា *«តំណាងរាស្ត្រមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា។.....»* ។

ក៏ដូចគ្នាដែរព្រឹត្តិការណ៍ហិង្សាកើតមានឡើងជាបន្តបន្ទាប់ ទៅលើសកម្មជនស្ត្រីតវ៉ាទាមទារឲ្យមានដំណោះស្រាយបញ្ហាដីធ្លី ផ្ទះសំបែងរបស់ពួកគាត់ និងកម្មការិនីសំដែងមតិទាមទារតំឡើងប្រាក់ខែគោល១៦០ ដុល្លារ ក៏ត្រូវបានកងទ័ពពិសេសឆ័ត្រយោង កងកំលាំងប្រដាប់ដោយ អាវុធ ខែល ដំបងឆក់ និងក្រុមសន្តិសុខពាក់មួកឃ្លុំមុខ បានប្រើដំបងឈើ ដំបងដែក ដំបងឆក់ ចំពាមកៅស៊ូគ្រាប់ដែក វាយដំ បាញ់ បំបាក់ស្មារតី ធ្វើឲ្យមានការភ័យខ្លាច បង្កឲ្យមានរបួសស្នាម ចាប់ឃុំខ្លួនមួយរយៈខ្លី ចាប់ដាក់ពន្ធនាគារ និងមានការធ្វើឲ្យរលូតកូន ព្រមទាំងករណីខ្លះបានប្រើកាំភ្លើងគ្រាប់ពិតបាញ់ប្រហាររហូតដល់មានស្លាប់បាត់បង់ជីវិតទៀតផង។

លើសពីនេះទៀតសោត សូម្បីតែ លោកស្រី **ធីដា ឃឹះ** ដែលមានវ័យចំណាស់គួរជាទីគោរពជាថ្នាក់ដឹកនាំក្រុមស្ត្រីនៃអង្គការសង្គមស៊ីវិល ជាប្រធានដឹកនាំនៃគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ(CPWP) ក៏ត្រូវបានកងកំលាំងប្រដាប់ដោយដំបង និងពាក់មួកឃ្លុំមុខរាប់រយនាក់រាំង និងរុញច្រានមិនញញើតដៃបណ្តាលឲ្យរងរបួសជើងក្នុងពេលដែលលោកស្រីដឹកនាំក្រុមស្ត្រី បើទោះបីក្នុងអំឡុងទិវានារីអន្តរជាតិបំណងធ្វើគារវកិច្ចដឹងគុណ ថ្វាយផ្កាគោរពបូជាចំពោះរូបសំណាកលោកយាយពេញ កាលពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៤ ក៏ដោយ ។

ករណីខាងលើ ក៏បានបង្ហាញពីភាពមិនស្របច្បាប់ស្តីពីធ្វើបាតុកម្មដោយសន្តិភាពផងដែរ ដែលអាជ្ញាធររាជធានីភ្នំពេញបានហាមប្រាមក្នុងការជួបជុំនៅទីលានប្រជាធិបតេយ្យមិនឲ្យលើស១០នាក់ និងការប្រើប្រាស់កំលាំងសន្តិសុខអត់សមត្ថកិច្ចផ្លូវការមកបង្ក្រាបបាតុកម្ម ។ អាកប្បកិរិយារបស់កម្លាំងសន្តិសុខមិនគោរព និងឲ្យតម្លៃចំពោះសិទ្ធិស្ត្រី ដោយសារពួកគេជាកម្លាំងសន្តិសុខមិនស្របច្បាប់ ហើយគ្មានការបណ្តុះបណ្តាលពីសិទ្ធិមនុស្ស និងសិទ្ធិស្ត្រី។ រាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធររាជធានីភ្នំពេញត្រូវតែទទួលខុសត្រូវចំពោះការរំលោភបំពានលើសិទ្ធិស្ត្រី ដូចដែលបានរៀបរាប់ខាងលើ។

**អនុសាសន៍**

១. ក្រសួងមហាផ្ទៃត្រូវដកបំរាមជាបន្ទាន់អំពីការធ្វើបាតុកម្មដោយសន្តិវិធី ហើយរៀបចំកំលាំងសន្តិសុខរៀបរយដែលទទួលការហ្វឹកហ្វឺន រួមទាំងយល់ដឹងអំពីសីលធម៌យេនឌ័រ ។

២. ក្រសួងកិច្ចការនារី ត្រូវផ្តួចផ្តើមការអប់រំពិសេសអំពីសីលធម៌យេនឌ័រដល់កងកំលាំងសន្តិសុខ ដើម្បីការពារ លើកស្ទួយសិទ្ធិស្ត្រី រក្សាភាពថ្លៃថ្នូរ កិត្តិយសស្ត្រី តម្លៃស្ត្រី និងសីលធម៌សង្គមឲ្យបានជាដាច់ខាតប្រយោជន៍ដើម្បីរក្សាឲ្យបានកិត្តិយស កេរ្តិ៍ឈ្មោះ និងជាតិសាសន៍របស់សង្គមខ្មែរ។

៣. រដ្ឋាភិបាលគួរត្រូវធ្វើគោលនយោបាយច្បាស់លាស់ អំពី ការអនុវត្តសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំដោយសន្តិវិធី ភាពថ្លៃថ្នូរនៃកំលាំងសន្តិសុខ និងសីលធម៌សង្គមខ្មែរដែលកើតចេញពីការប្រព្រឹត្តិអំពើហិង្សាទៅលើស្ត្រីដោយសកម្មភាព។

ព័ត៌មានបន្ថែមសូមទាក់ទង៖

១. លោកស្រី **ស៊ីនគេត ស៊ីរីលែក្ខណ៍** អ្នកសំរបសំរួលកម្មវិធីអប់រំ និងយេនឌ័រ **ខុមហ្វ្រែល** (017 494 004)

២. លោក **នាង សុវណ្ណា** មន្ត្រីអប់រំ និងយេនឌ័រ **ខុមហ្វ្រែល** (012 977 231)

**បេសកកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្ត ប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។

ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

## ញត្តិទាមទារ

## ការដោះលែងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ

## សំដែងមតិនៅទីលានប្រជាធិបតេយ្យ

ក្រុមអង្គការសង្គមស៊ីវិល មានការខកចិត្ត និងសោកស្តាយយ៉ាងខ្លាំងចំពោះព្រឹត្តិការណ៍ប្រទូស្ត៉ាយគ្នាកាលពីព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ វេលាម៉ោង៩ព្រឹករវាងប្រជាពលរដ្ឋម្ចាស់ឆ្នោត បេក្ខជនតំណាងរាស្ត្រជាប់ឆ្នោត ដែលចង់បញ្ចេញមតិធ្វើកូដកម្មដោយសន្តិភាពជាមួយនឹងកងសន្តិសុខខណ្ឌដូនពេញនៅចំណុចស្ពាននាគ នឹងទីលានប្រជាធិបតេយ្យ នៃរាជធានីភ្នំពេញដែលជាកន្លែងបញ្ចេញមតិរបស់ម្ចាស់ឆ្នោត។ ការប្រទូស្ត៉ាយគ្នានេះបង្កឲ្យមានរបួសចំនួន៣១នាក់ ដែលក្នុងនោះខាងកងសន្តិសុខខណ្ឌមានចំនួន១៧នាក់ និងមានការឃាត់ខ្លួនមន្ត្រីគណបក្សសង្គ្រោះជាតិ១នាក់ និងបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោត៥នាក់ ជាពិសេសបេក្ខជនស្ត្រីជាប់ឆ្នោតជាអ្នកតំណាងតំណាងរាស្ត្រ លោកស្រី មូរ សុខហួរ ផងដែរ។ ទង្វើនៃការចាប់ឃាត់ខ្លួនទាំងនេះ វាមិនស្របនឹងស្ថានភាពបច្ចុប្បន្ន ខណៈពេលដែលមិនទាន់មានការប្រកាសអាសន្នជាផ្លូវការដោយព្រះមហាក្សត្រ និងរដ្ឋាភិបាលកម្ពុជានៅឡើយទេ។ ទន្ទឹមនឹងនេះដែរ នាយករដ្ឋមន្ត្រីក៏បានមានប្រសាសន៍ថា ប្រទេសកម្ពុជា ជាស្ថាប័នរដ្ឋដែលនៅមានដំណើរការជាធម្មតា។ វិធានការ បង្ក្រាបមិនមែនជាដំណោះស្រាយក្នុងបរិបទ «កម្ពុជា» ទេ។ រដ្ឋាភិបាលមានកាតព្វកិច្ចការពារដល់ប្រជាពលរដ្ឋក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ ក្នុងករណីនេះ ការបញ្ចេញមតិរបស់ក្រុមបក្សប្រឆាំង និងអ្នកដែលមានមតិ និងការព្រួយបារម្ភស្របផងដែរ។ ក្រុមអង្គការសង្គមស៊ីវិលបានឃើញ បានតាមដានសភាពការណ៍នេះយ៉ាងយកចិត្តទុកដាក់បំផុត និងយល់ថា លោកស្រី មូរ សុខហួរ មានគោលការណ៍នៃការទាមទារ និងតវ៉ាដោយអហឹង្សា។

ក្រុមអង្គការសង្គមស៊ីវិល ទាមទារឲ្យរដ្ឋាភិបាល និងអាជ្ញាធររពាក់ព័ន្ធទាំងឡាយ តុលាការមានសមត្ថកិច្ចធ្វើការដោះលែង និងដកការចោទប្រកាន់ដោយគ្មានលក្ខខណ្ឌចំពោះ លោកស្រី មូរ សុខហួរ និងបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតទាំងនោះជាបន្ទាន់។ បើដូចការបកស្រាយរបស់រដ្ឋាភិបាល និងរដ្ឋសភាថា រដ្ឋសភាអាណត្តិថ្មីត្រូវបានបង្កើត បច្ចុប្បន្នមានសុពលភាពនៃសមាជិកតំណារាស្ត្រ១២៣នាក់ នោះរដ្ឋាភិបាល អាជ្ញាធរ និងតុលាការត្រូវតែគោរព និងអនុវត្តតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៨០ «តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។ តំណាងរាស្ត្ររូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនឡើយ។...» និងច្បាប់វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ប្រការ៤ថ្មី ចែងថា «តំណាងរាស្ត្រមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា។...» និងការការពារសិទ្ធិធ្វើកូដកម្ម និងបាតុកម្ម មានចែងក្នុងមាត្រា៣៧ «សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខណ្ឌនៃច្បាប់» និងបានការពារសិទ្ធិសេរីភាពបញ្ចេញមតិ ដែលមានចែងក្នុងមាត្រា៤១ «ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។...» ។ បន្ថែមលើនេះទៀត យោងតាមកតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៩ កថាខណ្ឌ២ ចែងថា «ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មានទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ ឬបោះពុម្ព តាមទំរង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដ៏ទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន»។

ក្រុមអង្គការសង្គមស៊ីវិលបន្តស្នើឲ្យអាជ្ញាធរ និងរាជរដ្ឋាភិបាល ៖

- សូមឲ្យមានការស៊ើបអង្កេតឲ្យបានហ្មតចត់ តម្លាភាព និងយុត្តិធម៌ ទៅលើជនដែលបានបង្ករហេតុ និងបានប្រព្រឹត្តិពិតប្រាកដក្នុងហេតុការណ៍ហិង្សាកាលពីថ្ងៃទី១៥ កក្កដា ២០១៤
- ត្រូវបើកទីលានប្រជាធិបតេយ្យវិញ ហើយត្រូវគោរព និងអនុវត្តតាមរដ្ឋធម្មនុញ្ញ និងច្បាប់បាតុកម្មដោយសន្តិវិធី ព្រោះថាបើមិនការដោះលែងនោះទេអាចនឹងបណ្តាលឲ្យមានភាពរឹករវ និងអាចបង្កឲ្យមានអស្ថេរភាពនៅក្នុងសង្គមកម្ពុជាដែលនិងប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់សេដ្ឋកិច្ច និងជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។

**អង្គការសង្គមស៊ីវិលគាំទ្រញត្តិនេះ៖**

| | | |
|---|---|---|
| -លោក គល់ បញ្ញា | នាយកប្រតិបត្តិCOMFREL | 012 49 20 17 |
| -លោកស្រី ធីតា ឃឹះ | ប្រធានCPWP និងនាយិកា SILAKA | 012 38 84 64 |
| -លោកស្រី រស់ សុភាព | អនុប្រធានCPWP និងនាយិកា GADC | 012 62 78 57 |
| -លោក សួន ប៊ុនស័ក្តិ | ប្រធានលេខាធិការដ្ឋាន CHRAC | 092 34 43 57 |
| -លោក ម៉ម សម្បត្តិ | នាយកប្រតិបត្តិ DPA | 012 77 97 34 |
| -លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | 012 80 12 35 |
| -លោក យង់ គិមអេង | ប្រធាន PDP-Center | 016 82 82 11 |
| -លោក ហ៊ឹម យន់ | អ្នកសម្របសម្រួលអង្គការ CISA | 012 94 70 22 |

ភ្នំពេញ, ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៤

**សេចក្តីថ្លែងការណ៍រួម**
**ស្តីពី**
**សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា**
**នៃព្រះរាជាណាចក្រកម្ពុជា**

ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា និងអ្នកជំនាញឯករាជ្យ យល់ឃើញថា កិច្ចព្រមព្រៀងដំណោះស្រាយនយោបាយ កាលពីថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៤ រវាងគណបក្សប្រជាជកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានផ្តល់គោលការណ៍ជាមូលដ្ឋានមួយចំនួន ដើម្បីនាធាឲ្យដំណើររដ្ឋសភាមានប្រសិទ្ធិភាព និងតម្លាភាព ស្របតាមគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស និងរបបសភានិយមនៅកម្ពុជា។

កិច្ចព្រមព្រៀងដំណោះស្រាយនយោបាយនេះបានបញ្ជាក់ច្បាស់ថាត្រូវ «សិក្សា និងធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា» ដើម្បីធានា ១)ក្នុងការរៀបចំឲ្យមានការបែងចែកអំណាចដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ ដើម្បីឲ្យស្ថាប័នរដ្ឋសភាអាចបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវ និងកាន់តែមានប្រសិទ្ធិភាព ២)ការលើកកម្ពស់តួនាទី និងសិទ្ធិអំណាចរបស់គណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និង ៣) ការរៀបចំបែងចែកសិទ្ធិ និងអំណាចដឹកនាំស្ថាប័នរដ្ឋសភា ដោយបែងចែកតួនាទីដឹកនាំនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា តាមរូបមន្ត ០៧ ទល់ ០៦ ដែលគណបក្សដឹកនាំរាជរដ្ឋាភិបាលមានសមាសភាព០៧រូប និងគណបក្សមិនចូលរួមក្នុងរាជរដ្ឋាភិបាល ដែលមានអាសនៈក្នុងសភា មានសមាសភាព០៦រូប នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍។ គណបក្សដឹកនាំរាជរដ្ឋាភិបាល និងគណបក្សមិនចូលរួមក្នុងរាជរដ្ឋាភិបាលដែលមានអាសនៈក្នុងរដ្ឋសភាមានតួនាទីដឹកនាំគណៈកម្មការជំនាញចំនួន០៥ស្មើគ្នា។

ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា និងអ្នកជំនាញឯករាជ្យ យល់ឃើញថា កិច្ចព្រមព្រៀងដំណាក់កាលទី០១ ស្តីពីការចរចាធ្វើសេចក្តីព្រាងវិសោធកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៤ របស់ក្រុមការងារនៃគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ មិនទាន់បានអនុវត្តចំណុចសំខាន់ៗនៃកិច្ចព្រម ព្រៀងថ្ងៃទី២២ កក្កដា ២០១៤ ប៉ុន្តែក្រុមការងារនៃគណបក្សទាំងពីរ បានសន្យាថា និងបន្តការពិភាក្សានៅតំណាក់ទីពីរ។

ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា និងអ្នកជំនាញឯករាជ្យ សូមផ្តល់នូវអនុសាសន៍សំខាន់ៗបន្ថែមក្នុងការធ្វើវិសោធនកម្មកែប្រែ ឬការបន្ថែមខ្លឹមសារមាត្រាច្បាប់រដ្ឋធម្មនុញ្ញ និងប្រការបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងមាត្រា១២០ថ្មីនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដូចខាងក្រោម៖

- រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង«ថ្មី» ដោយមតិពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីមិនមានបទបញ្ជាផ្ទៃក្នុងថ្មី បទបញ្ជាផ្ទៃក្នុងនៃអាណត្តិចុងក្រោយត្រូវចូលជាធរមាន។ (មាត្រា៨២ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៨២ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ត្រូវចែងអំពីការបែងចែកអំណាច ដឹកនាំរដ្ឋសភាក្នុងចំណោមគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមានសមាសភាពបុរស និងស្ត្រី ដូចរូបមន្តកិច្ចព្រមព្រៀងដំណោះស្រាយនយោបាយថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។ (ប្រការ ០២ថ្មី (ពីរ) និង ១០ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- គណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការជំនាញនីមួយៗ នៃរដ្ឋសភាត្រូវកំណត់ពេល ០១ (មួយ) ថ្ងៃ ក្នុង ០១ (មួយ) សប្តាហ៍ ដើម្បីធ្វើសវនាការសាធារណៈ ជជែកដេញដោល ដោយកោះហៅជនពាក់ព័ន្ធមកបំភ្លឺលើសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ និង ការអនុវត្តច្បាប់ជាធរមាន។ ទោះបីជាយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។ គណៈកម្មាធិការអចិន្ត្រៃយ៍មានអំណាចទទួលពិនិត្យបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។ (ប្រការថ្មីបមន្ថែមក្នុងជំពូក៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- កំណត់ហេតុទាំងអស់ និងឯកសារដទៃទៀតរបស់រដ្ឋសភា ត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋាន និង ជាសាធារណៈ លើកលែងតែជាកំណត់ហេតុ និងឯកសារទាំងឡាយណាដែលសំរេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍ថា អាចប៉ះពាល់ដល់សន្តិសុខជាតិ។ (ប្រការ១៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)។ អគ្គលេខាធិការដ្ឋានត្រូវរៀបចំឲ្យមានបទបញ្ជារដ្ឋបាល ដើម្បីធានាសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន និងចូលរួមក្នុងព្រឹត្តិការណ៍សាធារណៈរបស់រដ្ឋសភា។( ប្រការថ្មី បញ្ចូលទៅក្នុងជំពូកទី ៤)។
- គណៈកម្មការជំនាញនៃរដ្ឋសភា ត្រូវកោះហៅអ្នកព្រាងច្បាប់ និងអ្នកស្នើច្បាប់មកសាកសួរអំពីសេចក្តីពង្រាង និងសេចក្តីស្នើរច្បាប់ ក្នុងសវនាការសធារណៈ។ អ្នកតែងព្រាងច្បាប់ ឬអ្នកតែងសេចក្តីស្នើច្បាប់ មានសិទ្ធិចូលរាយការណ៍ជម្រាបគណៈកម្មការដែលពិនិត្យសេចក្តីស្នើនោះ។ (ប្រការ២៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)

- ចម្លើយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រី ត្រូវធ្វើឡើងក្នុងរយៈពេលដប់ប្រាំថ្ងៃ បន្ទាប់ពីទទួលបានសំណួរ។ ចំពោះចម្លើយផ្ទាល់មាត់តំណាងរាស្ត្រដាក់សំណួរ និងរាជរដ្ឋាភិបាលមានសិទ្ធិទទួលបានពេលវេលាស្មើគ្នាក្នុងការជជែកដេញដោល។ ចំពោះចម្លើយជាលាយលក្ខណ៍អក្សរ តំណាងរាស្ត្រដាក់សំណួរមានសិទ្ធិឆ្លើយតបក្នុងរដ្ឋសភាក្នុងរយៈពេលស្មើគ្នានឹងការអានចម្លើយជាលាយលក្ខណ៍អក្សររបស់រាជរដ្ឋាភិបាល។ (ប្រការ៣២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបយ៉ាងតិច ទើបរដ្ឋសភាលើកយកមកពិភាក្សាបាន។ ប្រសិនបើមានញត្តិបន្ទោសសមាជិកគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាលពីរដង រដ្ឋសភាត្រូវបើកប្រជុំពេញអង្គពិភាក្សា និងអនុម័តជាសាធារណៈក្នុងការទម្លាកមាជិកសមាជិកគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាល។ (ប្រការ៣៥ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- គណបក្សដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាលនិងមានអាសនៈច្រើនជាងនៅក្នុងរដ្ឋសភា ត្រូវបានទទួលស្គាល់ ហើយមានសិទ្ធិបង្កើតអ្នកនាំពាក្យក្នុងការត្រួតពិនិត្យការងាររបស់រាជរដ្ឋាភិបាល ហើយ អាចស្នើសុំឲ្យមានកិច្ចពិភាក្សាតទល់លើគោលនយោបាយរបស់រដ្ឋាភិបាល និង មានសិទ្ធិឆ្លើយតប ដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរទៅនឹងចម្លើយរបស់រាជរដ្ឋាភិបាលទៅនឹងសំណួររបស់តំណាងរាស្ត្រ។ (ប្រការថ្មី បញ្ចូលទៅក្នុងជំពូកទី ៩)
- សមាជិករដ្ឋសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ដោយសារសាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា ហើយបញ្ជាក់ពីមូលហេតុ និងផ្សព្វផ្សាយជាសាធារណៈ។ សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ដែលមានការសម្រេចជាលាយលក្ខណ៍អក្សរ តែមិនមែនមូលហេតុដោយសារការបញ្ចេញមតិខុសឆ្គង។ (មាត្រា ១២០ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ)
- យ៉ាងយូរបី(០៣)ថ្ងៃក្រោយពេលការប្រកាសលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាស្ថាពរ គណៈកម្មាធិការជាតិសម្រាប់ការបោះឆ្នោត ត្រូវរៀបចំបញ្ជីសមាជិកតំណាងរាស្ត្រដែលមានយ៉ាងតិច១២០រូបថ្វាយព្រះមហាក្សត្រ។ (មាត្រាថ្មី នៃជំពូកអំពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៃរដ្ឋធម្មនុញ្ញ)
- គណៈបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាតិចជាងដប់ មានសិទ្ធិបង្កើតក្រុមរបស់ខ្លួនចំនួនមួយ(០១) ក្រុម។ (ប្រការ៤៨ថ្មី (ពីរ) បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)

ក្រុមអង្គការសង្គមស៊ីវិល និងអ្នកជំនាញឯករាជ្យ បានរៀបចំសេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងមាត្រា១២០ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដូចដែលមានភ្ជាប់ជាមួយសេចក្តីថ្លែងការណ៍នេះ។ ក្រុមអង្គការសង្គមស៊ីវិល និងអ្នកជំនាញឯករាជ្យត្រៀមរួចជាស្រេចក្នុងការចូលរួមបកស្រាយ សេចក្តីស្នើវិសោធនកម្មទាំងនេះ ទៅក្រុមការងារគណបក្សនយោបាយទាំងពីរ ឬក្រុមសមាជិកតំណាងរាស្ត្រ ឬក្រុមបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ ប្រសិនបើគណបក្សទាំងពីរផ្តល់ឱកាសឲ្យក្រុមអង្គការសង្គមស៊ីវិល និងអ្នកឯករាជ្យ។

**<u>ទំនាក់ទំនងព័ត៌មានបន្ថែម៖</u>**

| | | |
|---|---|---|
| • លោកបណ្ឌិត កែមឡី | អ្នកស្រាវជ្រាវសង្គមឯករាជ្យ | ០១២ ៧៨ ៧០ ៨៤ |
| • លោក អ៊ូ វីរៈ | ប្រធានក្រុមប្រឹក្សាភិបាល CCHR | ០១២ ៤០ ៤០ ៥១ |
| • លោក នី ចរិយា | ប្រធានផ្នែកស៊ើបអង្កេតADHOC | ០១១ ២៧ ៤៩ ៥៩ |
| • លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ០១២ ៩៤ ២០ ១៧ |
| • លោកស្រី រស់ សុភាព | នាយិកាអង្គការ GADC | ០១២ ៦២ ៧៨ ៥៧ |

**<u>អង្គការគាំទ្រ៖</u>**

1. សមាគមអាដហុក ADHOC
2. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum)
3. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
4. អង្គការ ខុមហ្វ្រែល (COMFREL)
5. វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(API)
6. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
7. អង្គការ GADC
8. អង្គការ និកហ្វិច
9. អគ្គលេខាធិការដ្ឋាន CHRAC
10. មជ្ឈមណ្ឌល PDP-Center
11. ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC)
12. អង្គការ KYSD
13. សម្ព័ន្ធ CISA

ភ្នំពេញ. ថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៤

# សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## សមភាពយេនឌ័រនៃថ្នាក់ដឹកនាំកំពូលរដ្ឋសភានីតិកាលទី៥

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និងក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា សូមអំពាវនាវដល់រដ្ឋសភា ជាពិសេសគណបក្សប្រជាជនកម្ពុជាសូមឲ្យយកចិត្តទុកដាក់ចំពោះសមភាពយេនឌ័រ នៃថ្នាក់ដឹកនាំកំពូលរដ្ឋសភា ដោយបន្តរក្សាបេក្ខភាពស្ត្រី ជាអនុប្រធានទីពីរនៃរដ្ឋសភាពនីតិកាលទី៥។

ផ្អែកលើលទ្ធផលនៃកិច្ចព្រមព្រៀងថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីដំណោះស្រាយនយោបាយរវាងថ្នាក់ដឹកនាំកំពូលនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ តំណែងដឹកនាំកំពូល រួមមានប្រធាន និងអនុប្រធានទីពីរត្រូវបានគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា អនុប្រធានទីមួយត្រូវបានគ្រប់គ្រងដោយគណបក្សសង្គ្រោះជាតិ។ គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និងក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា សូមស្នើរដ្ឋសភា ជាពិសេសគណបក្សប្រជាជនកម្ពុជាសូមជ្រើសរើសបេក្ខភាពស្ត្រី ឬ បន្តរក្សាបេក្ខភាពលោកជំទាវ ឃួន សុដារី ជាអនុប្រធានទីពីរនៃរដ្ឋសភាដដែល។

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និងក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា យល់ឃើញថា អង្គការលេខនៃថ្នាក់ដឹកនាំកំពូលរដ្ឋសភានៅចុងនីតិកាលទី៤ និងដើមនីតិកាលទី៥ មានសមភាពយេនឌ័រ ដោយសារថ្នាក់ដឹកនាំកំពូលរដ្ឋសភាមានសមាសភាពបុរស និងស្ត្រីនិងសូមឲ្យបន្តវប្បធម៌នេះ។

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និងក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា យល់ឃើញថា ការបោះឆ្នោតជ្រើសរើសបេក្ខភាពស្ត្រី ឬ បន្តរក្សាបេក្ខភាពលោកជំទាវ ឃួន សុដារី ជាអនុប្រធានទីពីរនៃរដ្ឋសភាពនីតិកាលទី៥ ពិតជាមានសារៈសំខាន់ណាស់ក្នុងការអនុវត្តន៍ស្របតាមអនុសញ្ញាស៊ី-ដ «លុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ» ដែលកម្ពុជាជាប្រទេសហត្ថលេខី។ អនុសញ្ញានេះទាមទារឲ្យមានជាវិធានការពិសេសក្នុងការលើកស្ទួយដល់ការចូលរួមរបស់ស្ត្រី។ មាត្រា៣ចែងថា ក្នុងគ្រប់វិស័យ ជាពិសេសវិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការ សមស្របទាំងអស់ រួមទាំងការធ្វើច្បាប់ផងដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចំរើនពេញលេញរបស់ស្ត្រី ដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដោយសមភាពជាមួយបុរស៕

**ទំនាក់ទំនងព័ត៌មានបន្ថែម៖**

| | | |
|---|---|---|
| -លោកស្រី ធីតា ឃឹះ | នាយិកានៃអង្គការសីលការ និងប្រធានCPWP | 012 38 84 64 |
| -លោកស្រី រស់ សុភាព | នាយិកានៃអង្គការ GADC និងអនុប្រធានCPWP | 012 62 78 57 |
| -លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិ NICFEC | 012 95 96 66 |
| -លោក យ៉ង់ គិមអេង | នាយកប្រតិបត្តិ PDP-Center | 016 82 82 11 |
| -លោកស្រី ជា ស៊ុនដាណែត | នាយិកា WMC | 016 71 37 14 |
| -លោក ជាង សុខា | នាយកប្រតិបត្តិ YRDP | 012 36 04 64 |
| -លោក កែប កាណារូ | នាយកប្រតិបត្តិ Padek | 012 85 87 33 |
| -លោក គាន ពន្លក | នាយកប្រតិបត្តិរង DHRAC | 012 55 14 66 |
| -លោកស្រី អរុណ រស្មី | នាយិកា Strey Khmer | 012 23 66 53 |
| -លោក ម៉ម សម្បត្តិ | នាយកប្រតិបត្តិ DPA | 012 77 97 34 |
| -លោកស្រី សីនកេត សិរីលក្ខណ៍ | អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រCOMFREL | 017 49 4004 |
| -លោក នាង សុវណ្ណ | មន្ត្រីអប់រំ និងយេនឌ័រ COMFREL | 012 977 231 |

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

អង្គការ សមាគមក្រៅរដ្ឋាភិបាល មានកិត្តិយសជម្រាបជូនដំណឹង និងគោរពអញ្ជើញលោក លោកស្រី អ្នកនាង កញ្ញា ដែលជាអ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបថា ក្រុមអង្គការ សមាគមក្រៅរដ្ឋាភិបាលរួមមាន គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (CPWP) មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) នឹងរៀបចំសន្និសីទកាសែត ស្តីពី"**ទិវាអន្តរជាតិប្រជាធិបតេយ្យ និងការបង្ហាញអំពីស្ថានភាពនៃដំណើរការប្រជាធិបតេយ្យទាក់ទិនទៅនឹងបញ្ហាចម្បងនៅប្រទេសកម្ពុជា**"

**សន្និសីទកាសែតនេះមានគោលបំណង៖**

១. ចូលរួមប្រារព្ធ "**ទិវាអន្តរជាតិប្រជាធិបតេយ្យ**"
២. ដើម្បីបង្ហាញអំពីស្ថានភាពនៃដំណើរការប្រជាធិបតេយ្យ ដែលទាក់ទិនទៅនឹងបញ្ហាចម្បងៗនៅប្រទេសកម្ពុជា

**កាលបរិច្ឆេទ:** ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ ចាប់ពីម៉ោង ៩ ព្រឹកដល់ម៉ោង ១១ព្រឹក
**ទីកន្លែង:** នៅសាកលវិទ្យាល័យ **ខេមរៈ** (អគារលេខ ៣៥៣ ស្ថិតនៅតាមបណ្តោយផ្លូវ ១៩៨៦(ផ្លូវសែនសុខ) បត់ចូលផ្លូវលំ ៧២ ចំងាយ២០ម៉ែត្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ)

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ អង្គការ សមាគមក្រៅរដ្ឋាភិបាលយើងខ្ញុំ សូមគោរពអញ្ជើញអស់លោក លោកស្រី អ្នកនាង កញ្ញា ដែលជាអ្នកសារព័ត៌មានទាំងអស់មេត្តាជ្រាប និងចូលរួមយកព័ត៌មានកុំបីខាន។

***សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង***
*លោកស្រី សឺនកេត សិរីវណ្ណា*
*ទូរស័ព្ទ: ០១៧ ៤៩៤ ០០៤ ឬ ០២៣ ៨៨៤ ១៥០*

សូមអរគុណ!



ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ ទូរសារ ០២៣ ៨៨៥ ៧៤៥

អ៊ីម៉ែល: comfrel@online.com.kh ; comfrel@comfrel.org

គេហទំព័រ: www.comfrel.org

ប្រអប់សំបុត្រលេខ ១១៤៥

**ឧបត្ថម្ភដោយ ៖**

British Embassy
Phnom Penh

Oxfam

Norwegian People's Aid

Open Society Foundations

diakonia
People changing the world